# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដី នៅក្នុងឃុំកំពង់ចិនជើង
# ស្រុកស្ទោង ខេត្តកំពង់ធំ
# ឆ្នាំ២០១៧ ដល់ ២០៣២






**រៀបចំដោយ** : ក្រុមហ៊ុនផ្តល់សេវាកម្មSBK R&D

**សម្របសម្រួលដោយ** : ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីស្រុកសន្ទុក

**គាំទ្របច្ចេកទេសដោយ** : អង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ(NIO-MLMUPC) និងថ្នាក់ខេត្ត(PIO)

**ឧបត្ថម្ភថវិកាដោយ** : រាជរដ្ឋាភិបាលកម្ពុជា (RGC), ADB_Loan , GAFSP_Grant និងSCF_ADB

# មាតិកា

**អារម្ភកថា** ..... VII

**សេចក្តីផ្តើម** ..... 1

**ជំពូក ១៖ ព័ត៌មានស្តីពីស្ថានភាពឃុំកំពង់ចិនជើង** ..... 3

**១.១. ស្ថានភាពឃុំ** ..... 3

១.១.១. ទីតាំងរដ្ឋបាលឃុំ ..... 3

១.១.២. ប្រជាសាស្ត្រ ..... 6

ក. ចំនួនប្រជាជន ..... 6

ខ. អត្រាកំណើន ដង់ស៊ីតេ និងរបាយប្រជាជន ..... 7

គ. ជនជាតិ ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់ ..... 8

ឃ. របររកទទួលទាន ..... 8

ង. ចំណាកស្រុក និងចំណូលស្រុក ..... 10

១.១.៣. ស្ថានភាពសេដ្ឋកិច្ច ..... 11

ក. ប្រភពចំណូលចម្បង និងបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋ ..... 11

ខ. កម្រិតជីវភាពរស់នៅ ចំណូល ចំណាយប្រចាំថ្ងៃ ប្រចាំឆ្នាំ ..... 11

គ .ស្ថានភាពបំណុលសរុប និងអត្រាការប្រាក់ ..... 13

ឃ. ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់ ឬក្រោមរូបភាពផ្សេងៗ ..... 14

ង. ជំនួយពីប្រភពផ្សេងៗ ..... 14

១.១.៤. ស្ថានភាពសិក្សាធិការ ..... 14

ក. ស្ថានភាពអប់រំ ..... 14

ខ .ស្ថានភាពអក្ខរកម្ម ..... 15

គ. ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត ..... 16

១.១.៥. ស្ថានភាពសុខាភិបាល ..... 17

១.១.៦. ស្ថានភាពយេនឌ័រ ..... 19

**១.២. ស្ថានភាពភូមិសាស្ត្រ** ..... 21

១.២.១. ទីតាំងភូមិសាស្ត្រ ..... 21

១.២.២. អាកាសធាតុ ..... 28

១.២.៣. ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន ..... 29

១.២.៤. បរិក្ខាសាធារណៈ ..... 31

ក. ស្ថានភាពប្រើប្រាស់ថាមពលអគ្គិសនី ..... 31

ខ. ប្រព័ន្ធទឹកស្អាត....31
**១.៣. ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន**....33
១.៣.១. ស្ថានភាពការកាន់កាប់ និងគ្រប់គ្រងដី....33
ក. ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ៖....35
ក.១. ដីលំនៅឋានភូមិ ៖....35
ក.២. ដីកប់ខ្មោច....36
ខ. ដីកសិកម្ម៖....37
ខ.១. ដីស្រែវស្សា៖....37
ខ.២. ដីស្រែប្រាំង និងស្រែវស្សា៖....38
ខ.៣ ដីចម្ការ....39
គ. ដីព្រៃ/គម្របព្រៃ៖....40
ឃ. ផ្ទៃទឹក និងខ្សែទឹក៖....41
១.៣.២. ផលិតកម្មកសិកម្ម....42
ក. ផលិតកម្មដំណាំស្បៀង....42
ខ. ផលិតកម្មដំណាំរួមផ្សំ....43
គ. ផលិតកម្មឧស្សាហកម្ម....44
១.៣.៣. ធនធានធម្មជាតិ....45
ក. ធនធានព្រៃឈើ....45
ខ. ធនធានជលផល....45
១.៣.៤. ធនធានដី....46
**១.៤. ទីផ្សារ និងខ្សែសង្វាក់ផលិតផល**....46
១.៤.១. ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ....46
១.៤.២. ខ្សែសង្វាក់ និងចរាចរផលិតផល....47
១.៤.៣. ឧបសគ្គ និងឱកាសនៃទីផ្សារ និងខ្សែសង្វាក់ផលិតផល....49
**ជំពូក ២៖ ការវិភាគ តម្រូវការ សក្តានុពល និងឧបសគ្គសម្រាប់អនាគត**....50
**២.១. តម្រូវការសម្រាប់អនាគត**....50
២.១.១. ផែនការអភិវឌ្ឍន៍ឃុំ....50
ក. ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ (២០១៨ ដល់ ២០២២)....50
ខ. គម្រោងអភិវឌ្ឍផ្សេងៗទៀតដែលបានអនុម័តរួច....53
២.១.២. ចំណោលប្រជាសាស្ត្រគិតទៅដល់ឆ្នាំ២០៣២....54

២.១.៣. តម្រូវការដីធ្លីជាមូលដ្ឋាន ..... 55
ក. ដីលំនៅឋាន ..... 55
ខ. ដីកសិកម្ម ..... 56
គ. ដីព្រៃឈើ ..... 57
ឃ. ធនធានទឹក ..... 57
ង.ហេដ្ឋារចនាសម្ព័ន្ធ និងការប្រើប្រាស់ជាសាធារណៈផ្សេងៗទៀត ..... 58
ង.១.វិស័យអប់រំ ..... 58
ង.២. វិស័យសុខាភិបាល ..... 60
ង.៣. អគ្គិសនី ..... 60
ង.៤. ទីលានចាក់សំរាម ..... 60
ង.៥. ដីកប់ខ្មោច ..... 61
ង.៦ . ស្រះ និងអណ្តូងទឹក ..... 61
**២.២. តំបន់សេរីម** ..... 62
២.៣. ការប្រឈម ..... 63
២.៣.១. ការប្រឈមដោយធម្មជាតិ ..... 63
ក. កំណើនប្រជាជន ..... 63
ខ. គ្រោះធម្មជាតិ ការវិចរិលនៃធម្មជាតិៈ ..... 63
២.៣.២. ការប្រឈមដោយ ការអភិវឌ្ឍដែលពុំមាននិរន្តរភាព ..... 63
**២.៤.ឱកាស** ..... 64
២.៤.១. ដោយអំណោយផលពីធម្មជាតិ ..... 64
**២.៥. បញ្ហា មូលហេតុ និងដំណោះស្រាយ** ..... 65
**ជំពូក ៣ៈ ផែនការប្រើប្រាស់ដីសម្រាប់ពេលអនាគតឆ្នាំ២០១៧-២០៣២** ..... 68
**៣.១. តម្រូវការ ស្ថានភាព និងសក្តានុពលដីជាក់ស្តែង** ..... 68
៣.១.១. តម្រូវការដីទៅតាមប្រភេទ ..... 68
៣.១.២. ស្ថានភាពនៃដីធ្លី និងសក្តានុពល ..... 68
**៣.២. ការបែងចែកដីទៅតាមតម្រូវការប្រើប្រាស់** ..... 69
៣.២.១. ការវិភាគអន្តរអំពើរវាងតំបន់ផ្សេងៗ ..... 69
៣.២.២. ផែនទីប្រើប្រាស់ដីអនាគត ..... 71
៣.២.៣. សេចក្តីអត្ថាធិប្បាយអំពីការប្រើប្រាស់ដីនាពេលអនាគត ..... 73
ក. ដីលំនៅឋាន ភូមិ ..... 73

ខ. ដីកប់ខ្មោច ........ 74
គ. ដីស្រែវស្សា ........ 74
ឃ. ដីស្រែប្រាំង និងស្រែវស្សា ........ 75
ង. ដីចម្ការ ........ 75
ច. ព្រៃតម្លោត និងឈើដុះរាយប៉ាយ ........ 76
ឆ. ព្រៃតាមដងស្ទឹង ........ 76
ជ. ស្ទឹងមានទឹកតាមរដូវ ........ 76
ឈ. អាងស្តុកទឹក ........ 77
ញ. ស្រះ ........ 78
**៣.៣. ដំណោះស្រាយផ្សេងៗ ក្នុងករណីខ្វះខាតដីធ្លី** ........ 78
**៣.៤. កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព** ........ 78
៣.៤.១. កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព ........ 78
ក. ការគ្រប់គ្រងប្រព័ន្ធកសិកម្ម ........ 79
ខ. ការគ្រប់គ្រងព្រៃឈើ ផលផល និងធនធានសំខាន់ៗផ្សេងៗទៀត ........ 80
៣.៤.២. គម្រោងគាំទ្រចាំបាច់ សម្រាប់គាំទ្រនិរន្តរភាព ........ 80
**៣.៥. សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់ ២០៣២)** ........ 81

## បញ្ជីតារាង

តារាង 1៖ ស្ថានភាពទូទៅនៃឃុំ ........ 3
តារាង 2៖ ទិន្នន័យគ្រួសារ និងចំនួនប្រជាជនតាមបណ្តាភូមិ ........ 6
តារាង 3៖ ស្ថិតិប្រជាជន ឆ្នាំ២០១៧ តាមក្រុមអាយុ ........ 7
តារាង 4៖ ស្ថិតិប្រជាជនតាមបណ្តាឆ្នាំ និងការគណនាអត្រាកំណើនមធ្យម ........ 7
តារាង 5៖ តារាងមុខរបរ ........ 8
តារាង 6៖ តារាងមុខរបរបន្ទាប់បន្សំ ........ 10
តារាង 7៖ ស្ថិតិប្រជាជនផ្លាស់ប្តូរទីលំនៅក្នុងឆ្នាំ២០១៧ ........ 10
តារាង 8៖ ស្ថិតិប្រជាជនចំណាកស្រុក ........ 11
តារាង 9៖ តារាងចំណាត់ថ្នាក់ទ្រព្យធននៅក្នុងឃុំឆ្នាំ២០១៧ ........ 12
តារាង 10៖ ស្ថិតិសាលារៀន ស្ថានភាពអប់រំ និងសិក្សាធិការក្នុងឃុំឆ្នាំ២០១៧ ........ 15
តារាង 11៖ ស្ថិតិអ្នកមិនចេះអក្សរ ........ 16
តារាង 12៖ ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត ........ 17
តារាង 13៖ សុខភាពមាតានិងទារក ........ 18
តារាង 14៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព ........ 19
តារាង 15៖ ការវិភាគលើតួនាទីយេនឌ័រ ឃុំកំពង់ចិនជើង ........ 20

តារាង 16៖ ដ្យាក្រាមពំនុះកាត់ទទឹង ឃុំកំពង់ចិនជើង ស្រុកស្ទោង ...... 24
តារាង 17៖ ប្រព័ន្ធធារាសាស្រ្ត...... 26
តារាង 18៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ ...... 28
តារាង 19៖ ប្រព័ន្ធផ្លូវដឹកជញ្ជូន ...... 29
តារាង 20៖ ស្ថិតិអ្នកប្រើប្រាស់អគ្គិសនី...... 31
តារាង 21៖ ស្ថិតិអ្នកប្រើប្រាស់ការប្រើប្រាស់ទឹក...... 32
តារាង 22៖ តារាងរាយលម្អិតតាមប្រភេទនៃការប្រើប្រាស់ដីបច្ចុប្បន្នឃុំកំពង់ចិនជើង...... 35
តារាង 23៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាសលើដំណាំស្បៀង ...... 43
តារាង 24៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ...... 44
តារាង 25៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ...... 44
តារាង 26៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ...... 45
តារាង 27៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ...... 46
តារាង 28៖ ស្ថិតិផលិតផលស្រូវ និងតម្លៃ...... 47
តារាង 29៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ...... 49
តារាង 30៖ ក្របខ័ណ្ឌនៃការអភិវឌ្ឍ និងជម្រើសនៃការប្រាស់ដីធ្លីអនាគត ...... 50
តារាង 31៖ ចំណោលប្រជាសាស្រ្តនៃចំនួនគ្រួសារ និងប្រជាជនសរុប (០៥ឆ្នាំ) ...... 54
តារាង 32៖ ចំណោលប្រជាសាស្រ្តតាមក្រុមអាយុ (០៥ឆ្នាំ)...... 55
តារាង 33៖ តម្រូវការដីសម្រាប់លំនៅឋានក្នុងឆ្នាំ២០៣២ ...... 56
តារាង 34៖ តម្រូវការដីសម្រាប់កសិកម្មក្នុងឆ្នាំ២០៣២...... 57
តារាង 35៖ កំណើនកុមារ  តម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១៨ ដល់ឆ្នាំ ២០៣២ ...... 59
តារាង 36៖ បញ្ហាប្រឈម និងសក្តានុពល (ផ្អែកលើការវិភាគ បញ្ហា/មូលហេតុ/ដំណោះស្រាយ)...... 65
តារាង 37៖ ការប្រើប្រាស់ដីនាពេលអនាគត...... 70
តារាង 38៖ តារាងផែនការផ្អែកហេដ្ឋារចនាសម្ព័ន្ធនាពេលអនាគត...... 71
តារាង 39៖ តារាងផែនការផ្អែកសេវាកម្មនាពេលអនាគត ...... 71

## បញ្ជីដ្យាក្រាម

ដ្យាក្រាម 1៖ ស្ថិតិប្រជាជនឆ្នាំ ២០១៧...... 6
ដ្យាក្រាម 2៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មន្ទីរពេទ្យបង្អែកស្រុកស្ទោង ...... 19
ដ្យាក្រាម 3៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ ...... 28
ដ្យាក្រាម 4៖ គំនូសតាងនៃការលំហូផលិតផលកសិកម្ម នៅក្នុងភូមិ និង ការប្រើប្រាស់ ...... 48

## បញ្ជីផែនទី

ផែនទី 1៖ ផែនទីទីតាំងឃុំកំពង់ចិនជើង ស្រុកស្ទោង ...... 4
ផែនទី 2៖ ផែនទីព្រំប្រទល់រដ្ឋបាលឃុំកំពង់ចិនជើង ...... 5
ផែនទី 3៖ ផែនទីសណ្ឋានដីឃុំកំពង់ចិនជើង...... 23
ផែនទី 4៖ ផែនទីបង្ហាញតំបន់គ្បេត-បរិស្ថាន ឃុំកំពង់ចិនជើង...... 24

ផែនទី 5៖ ប្រព័ន្ធធារាសាស្ត្រឃុំកំពង់ចិនជើង ..... 27
ផែនទី 6៖ ផែនទីហេដ្ឋារចនាសម្ព័ន្ធឃុំកំពង់ចិនជើង ..... 30
ផែនទី 7៖ ផែនទីប្រើប្រាស់ដីសាមញ្ញឃុំកំពង់ចិនជើង ..... 33
ផែនទី 8៖ ផែនទីប្រើប្រាស់ដីលម្អិត ឃុំកំពង់ចិនជើង ..... 34
ផែនទី 9៖ ផែនទីគម្រោងអាទិភាព ឃុំកំពង់ចិនជើង ..... 53
ផែនទី 10៖ ផែនទីតំបន់រសើប ឃុំកំពង់ចិនជើង ..... 62
ផែនទី 11៖ ផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ ឃុំកំពង់ចិនជើង ..... 67
ផែនទី 12៖ ផែនទីប្រើប្រាស់ដីពេលអនាគត ឃុំកំពង់ចិនជើង ..... 72

## បញ្ជីរូបភាព

រូបភាព 1៖ សាលារៀន ..... 15
រូបភាព 2៖ មន្ទីរពេទ្យបង្អែកស្ទោង ..... 18
រូបភាព 3៖ ប្រព័ន្ធធារាសាស្ត្រ ..... 26
រូបភាព 4៖ ប្រព័ន្ធគមនាគមន៍ ..... 29
រូបភាព 5៖ លំនៅឋានភូមិ ..... 36
រូបភាព 6៖ កន្លែងកប់ខ្មោច ..... 36
រូបភាព 7៖ ដីស្រែវស្សា ..... 38
រូបភាព 8៖ ដីស្រែប្រាំង និងស្រែវស្សា ..... 39
រូបភាព 9៖ ដីចម្ការ ..... 39
រូបភាព 10៖ ព្រៃគុម្ពោត ..... 40
រូបភាព 11៖ ព្រៃតាមដងស្ទឹង ..... 40
រូបភាព 12៖ ស្ទឹងមានទឹកតាមរដូវ ..... 41
រូបភាព 13៖ ស្រះទឹក ..... 41
រូបភាព 14៖ អាងស្តុកទឹក ..... 42
រូបភាព 15៖ ប្រភពធនធានជលផល ..... 46
រូបភាព 16៖ ផលិតផលកសិកម្ម ..... 48

## អារម្ភកថា

ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ គឺជាឧបករណ៍មួយដ៏សំខាន់ក្នុងការជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ផ្ទាល់ ក៏ដូចជាដល់អ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ ក្នុងការរួមចំណែកដល់ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងសមធម៌ ជាពិសេសការគ្រប់គ្រងនិងប្រើប្រាស់ដី ដែលជាកត្តាស្នូលនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងលើកស្ទួយដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។ ដូច្នេះក្រោយពេលមានផែនការប្រើប្រាស់ដីនេះអាជ្ញាធរគ្រប់ផ្នែកនៅថ្នាក់ក្រោមជាតិ ជាពិសេសអាជ្ញាធរដែនដី នឹងមានមូលដ្ឋានកាន់តែគ្រប់ជ្រុងជ្រោយ ក្នុងការរៀបចំបញ្ចូលផែនការប្រើប្រាស់នៅក្នុងឃុំសង្កាត់នេះទៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចថ្នាក់មូលដ្ឋាន ដោយធ្វើសមាហរណកម្មផែនការនៅថ្នាក់ស្រុក និងការអនុម័តនៅថ្នាក់រាជធានី ខេត្ត តាមនីតិវិធីដូចដែលធ្លាប់អនុវត្តក្នុងការកសាង ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច កន្លងមក ដោយមានគ្រប់ភាគីពាក់ព័ន្ធចូលរួមធ្វើការសម្រេច ។ ក្នុងទឹកចិត្តសោមនស្សរីករាយជាអនេក ខ្ញុំមានកិត្តិយសសូមបង្ហាញនូវរបាយការណ៍បច្ចេកទេស ស្តីពីផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់ចិនជើងមានចក្ខុវិស័យរហូតទៅដល់ឆ្នាំ២០៣២ ដែលក្រុមការងារបានប្រឹងប្រែងសិក្សាស្រាវជ្រាវ និងរៀបចំឡើងអស់រយៈពេលជាងពីរឆ្នាំកន្លងមកនេះ ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ធនាគារអភិវឌ្ឍអាស៊ី (ADB) និងកម្មវិធីកសិកម្មនិងសន្តិសុខស្បៀងពិភពលោក (GAFSP) ដែលបានគាំទ្រឧបត្ថម្ភថវិកា ក្រុមហ៊ុនផ្តល់សេវាកម្មមកជួយសិក្សារៀបចំផែនការនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលបានទទួលគ្រប់គ្រងគម្រោងនិងគាំទ្របច្ចេកទេស រដ្ឋបាលខេត្តកំពង់ធំ និងរដ្ឋបាលស្រុកស្ទោង ដែលបានសម្របសម្រួលដល់កិច្ចដំណើរការរបស់គម្រោងនិងអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមនៅក្នុងដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់ចិនជើងនេះ ។

ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់ចិនជើងនេះ នឹងបានចូលរួមចំណែកដល់ការអភិវឌ្ឍន៍ឃុំកំពង់ចិនជើងប្រកបដោយចីរភាព ថែមទាំងត្រូវបានប្រើប្រាស់ដោយមានការចូលរួមនិងគាំទ្រយ៉ាងពេញទំហឹងពីរដ្ឋបាលថ្នាក់ក្រោមជាតិនិងពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់៕

ថ្ងៃ ចន្ទ ១៤កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

កំពង់ចិនជើង ថ្ងៃទី...០៣.....ខែ..សីហា....ឆ្នាំ២០២០

ប្រធានក្រុមប្រឹក្សាឃុំ

ឈុន_ឆាត

# សេចក្តីផ្តើម

ស្ថិតនៅក្នុងបរិយាការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញ និងច្បាប់ រាជរដ្ឋាភិបាល ដែលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាល បានបន្តធ្វើការជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ នៅក្នុងគោលដៅបង្កើន និងកែលម្អការផ្តល់គុណភាពសេវាសាធារណៈប្រកបទៅដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

ផ្អែកតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ រាជរដ្ឋាភិបាលកម្ពុជា នៅក្រោមការដឹកនាំប្រកបទៅដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានដាក់ចេញនូវគោលនយោបាយជាតិ ស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជាសំដៅធានាថា ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍ តាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និងការធ្វើឱ្យរលូននូវវិធាន ឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ។

ឃុំកំពង់ចិនជើង ជាឃុំមួយក្នុងចំណោមឃុំចំនួន១៣ ស្ថិតក្នុងស្រុកស្ទោង ខេត្តកំពង់ធំ គឺជាតំបន់ជនបទមានផ្ទៃដីសរុបចំនួន ៣ ៨៨៩,៥ហិកតា មានព្រំប្រទល់ខាងជើងជាប់នឹងឃុំប្រឡាយ ស្រុកស្ទោង ខាងត្បូងជាប់នឹងឃុំកំពង់ចិនត្បូងស្រុកស្ទោង ខាងកើតជាប់នឹងឃុំទ្រាស្រុកស្ទោង និងខាងលិចជាប់នឹងឃុំម្សាក្រង ស្រុកស្ទោង ដែលមានប្រជាជនសរុបចំនួន ១០ ១២៨នាក់ នៅក្នុងនោះស្ត្រី ៥ ០៧៧នាក់ ហើយមានប្រជាពលរដ្ឋ ៧៩,១% ជាកសិករ។ ឃុំកំពង់ចិនជើងមានផ្ទៃដីស្រែសរុបទំហំ ៣ ២៣៩,៩ហិកតា គឺជាផ្ទៃដីដែលមានទំហំធំទូលាយមានវិសាលភាពស្រូបអស់ ៨៣,៥៤%នៃផ្ទៃដីសរុបរបស់ឃុំទាំងមូល ដែលជាបង្អែកដ៏មានសក្តានុពលតែមួយគត់សម្រាប់ការអភិវឌ្ឍន៍ឃុំកំពង់ចិនជើង ប្រកបដោយចីរភាព ។

ក្នុងគោលដៅធានាការគ្រប់គ្រងនិងអភិវឌ្ឍន៍ឃុំកំពង់ចិនជើង ប្រកបដោយចីរភាពនេះ គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ និងស្រុកស្ទោង ព្រមទាំងក្រុមប្រឹក្សាឃុំកំពង់ចិនជើងក្រោមការទទួលសិទ្ធិផ្តល់សេវាកម្មរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់ចិនជើងដោយក្រុមហ៊ុន SBK Co.LTd និងមានការគ្រប់គ្រងគាំទ្របច្ចេកទេសដោយអង្គភាពអនុវត្តគម្រោងថ្នាក់ខេត្ត (PIO) និងអង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ (NIO)នៃក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ព្រមទាំងមានការគាំទ្រនិងឧបត្ថម្ភថវិកាពីរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍអាស៊ី បានរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់ចិនជើង ចក្ខុវិស័យឆ្នាំ ២០៣២ សម្រាប់តម្រង់ទិសដល់ការអភិវឌ្ឍឃុំពាក់ព័ន្ធនឹងការប្រើប្រាស់ដីនៅក្នុងឃុំកំពង់ចិនជើង ឆ្លើយតបទៅនឹងកំណើនប្រជាសាស្ត្រ ដើម្បីជាមូលដ្ឋានជួយដល់ក្រុមប្រឹក្សាឃុំកំពង់ចិនជើងផ្ទាល់ ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ ក្នុងការរួមចំណែកដល់ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងសមធម៌ ដែលក្នុងនោះមានការគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី ដែលជាកត្តាស្នូលនៃការអភិវឌ្ឍឃុំ ធ្វើឱ្យជីវភាពប្រជាពលរដ្ឋមានភាពប្រសើរឡើងរួចផុតពីភាពក្រីក្រ ជាពិសេសការប្រើប្រាស់ដីកសិកម្មនៅក្នុងឃុំកំពង់ចិនជើង ឱ្យអស់ពីសក្តានុពលដែលមាន ក្នុងការផលិតស្រូវ ដើម្បីបង្កើនការនាំចេញអង្ករឱ្យបានច្រើននៅពេលខាងមុខឆ្លើយតបបានទៅនឹងគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្កររបស់រាជរដ្ឋាភិបាល ដែលនៅសល់ពីការហូបចុកតាមរយៈការប្រើប្រាស់ផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់ចិនជើងនេះ ធ្វើជាមូលដ្ឋានបង្អែកសម្រាប់រៀបចំផែនការអភិវឌ្ឍន៍ឃុំនៅតាមអណត្តិនីមួយៗរបស់ខ្លួន ។

ផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់ចិនជើង ត្រូវបានរៀបចំឡើងដោយមានការសិក្សាស្រាវជ្រាវច្បាស់លាស់ទៅលើកត្តាភូមិសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថាន ព្រមទាំងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការរៀបចំដែនដី និងនគរូបនីយកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានជាអាទិ៍ ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ និងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជនៗចំពោះនីតិវិធីនៃការរៀបចំផែនការនេះវិញត្រូវបានរៀបចំឡើងដោយផ្អែកទៅលើអនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ/សង្កាត់ ព្រមទាំងប្រកាសរួមស្តីអំពីនីតិវិធីលម្អិតសម្រាប់ការរៀបចំ និងអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ/សង្កាត់ និងឯកសារណែនាំអនុវត្តស្តីពីការរៀបចំផែនការប្រើប្រាស់ដីក្នុងឃុំ/សង្កាត់ ដែលមានដំណើរការរៀបចំផែនការដូចមានសង្ខេបក្នុងដ្យាក្រាមខាងក្រោម៖

ដ្យាក្រាម៖ ដំណើរការរៀបចំផែនការប្រើប្រាស់ដីធ្លីនៅក្នុងឃុំ សង្កាត់




សម្គាល់៖ [ ] ប្រអប់បង្ហាញទំហំការងារដែលត្រូវអនុវត្តតាមឯកសារណែនាំ

# ជំពូក ១៖ ព័ត៌មានស្តីពីស្ថានភាពឃុំកំពង់ចិនជើង

## ១.១. ស្ថានភាពឃុំ

កាលដើមឡើយមានការតំណាលតៗគ្នាមកថា នៅក្នុងទីរួមស្រុកស្ទោង នាសម័យមុនផ្សារស្ទោងស្ថិតនៅជាប់ដងស្ទឹងស្ទោង ហើយប្រជាជនមានការលក់ដូរយ៉ាងមមារញឹក កាលនោះមិនថាខ្មែរ ឬចិនទេឲ្យតែរកស៊ីលក់ដូរនៅក្នុងផ្សារ គេនិយមហៅថាចិនទាំងអស់ ។ ប្រជាពលរដ្ឋបានដឹកកសិផលកសិកម្មរបស់ពួកគាត់មកលក់នៅផ្សារស្ទោង តាមផ្លូវទឹកដោយទូកតូចធំពីតំបន់ផ្សេងៗ ហើយបានចតនៅនឹងកំពង់ទឹកក្នុងស្ទឹងស្ទោងជាប់នឹងផ្សារនោះ ហើយក្រោយមកក៏បានហៅកំពង់នោះថា 'កំពង់ចិន" រហូតមក ។ រហូតមកដល់សម័យសង្គមរាស្ត្រនិយមបានក្លាយទៅជា '**ឃុំកំពង់ចិន**" បន្ទាប់មកនៅសម័យរដ្ឋកម្ពុជារដ្ឋបាលស្រុកស្ទោងបានបែងចែកឃុំកំពង់ចិនជាពីរ គឺឃុំកំពង់ចិនត្បូង និងឃុំកំពង់ចិនជើង ដោយយកព្រំប្រទល់ឃុំម្ខាងស្ទឹងស្ទោងម្នាក់ ។ អំណើះតមកដល់រៀងបច្ចុប្បន្ននេះ ឃុំកំពង់ចិនជើងនៅតែរក្សាឈ្មោះថា '**ឃុំកំពង់ចិនជើង**" ដដែលតាមប្រកាសរបស់ក្រសួងមហាផ្ទៃលេខ៤៩៣ប្រ.ក ចុះថ្ងៃទី ៣០ មេសា ២០០១ ។

### ១.១.១. ទីតាំងរដ្ឋបាលឃុំ

ឃុំកំពង់ចិនជើង គឺជាឃុំមួយដែលស្ថិតនៅភាគខាងជើង និងមានចម្ងាយប្រហែល ៤,៥គីឡូម៉ែត្រពីរួមស្រុកស្ទោង ហើយស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលស្រុកស្ទោង ខេត្តកំពង់ធំ។ ឃុំនេះមានផ្ទៃដីសរុបចំនួន៣៨៨៩,៥ហិកតា (ប្រភពទិន្នន័យ៖ក្រុមការងារ GIS អេស ប៊ី ខេ)ដែលមានព្រំប្រទល់ជាប់នឹង៖

- ខាងជើង ជាប់នឹង ឃុំប្រឡាយ ស្រុកស្ទោង
- ខាងកើត ជាប់នឹង ឃុំទ្រា ស្រុកស្ទោង
- ខាងត្បូង ជាប់នឹង ឃុំកំពង់ចិនត្បូង ស្រុកស្ទោង
- ខាងលិច ជាប់នឹង ឃុំម្សាក្រង ស្រុកស្ទោង។ (ភ្ជាប់ជាមួយផែនទីរដ្ឋបាលឃុំ)

ឃុំនេះមានចំនួន០៦ភូមិគឺ ភូមិត្នោត ភូមិចេក ភូមិចក ភូមិរកា ភូមិនាងសល្វាច និង ភូមិត្រាច។

តារាង 1៖ ស្ថានភាពទូទៅនៃឃុំ

| | | |
|---|---|---|
| **ខេត្ត** | កំពង់ធំ | លេខកូដខេត្តៈ៦ |
| **ស្រុក** | ស្ទោង | លេខកូដស្រុកៈ ៦០៨ |
| **ឃុំ** | កំពង់ចិនជើង | លេខកូដឃុំៈ ៦០៨០៤ |
| ចំនួន៦ភូមិ | ១. ភូមិត្នោត | លេខកូដភូមិៈ ៦០៨០៤០១ |
| | ២. ភូមិចេក | លេខកូដភូមិៈ ៦០៨០៤០២ |
| | ៣. ភូមិចក | លេខកូដភូមិៈ ៦០៨០៤០៣ |
| | ៤. ភូមិរកា | លេខកូដភូមិៈ ៦០៨០៤០៤ |
| | ៥. ភូមិនាងសល្វាច | លេខកូដភូមិៈ ៦០៨០៤០៥ |
| | ៦. ភូមិត្រាច | លេខកូដភូមិៈ ៦០៨០៤០៦ |

ប្រភពទិន្នន័យ៖ *CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់ចិនជើង ខែមិថុនា ឆ្នាំ២០១៨*

ផែនទី 1៖ ផែនទីទីតាំងឃុំកំពង់ចិនជើង ស្រុកស្ទោង



ផែនទី 2៖ ផែនទីព្រំប្រទល់រដ្ឋបាលឃុំកំពង់ចិនជើង



## ១.១.២. ប្រជាសាស្ត្រ

### ក. ចំនួនប្រជាជន

នៅក្នុងឃុំកំពង់ចិនជើងចែកចេញជា ០៦ភូមិ ដែលមានគ្រួសារសរុបចំនួន ១ ៥៤៧គ្រួសារ ប្រជាជនសរុបចំនួន ១ ០១២៨នាក់ នៅក្នុងនោះស្រ្តី ៥ ០៧៧នាក់ ហើយប្រជាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅមានចំនួន ៦ ៨៣១នាក់ ស្រ្តីមានចំនួន ៣ ៤៧១នាក់ ។ នៅក្នុងឃុំកំពង់ចិនជើង ភូមិដែលមានប្រជាជនច្រើនជាងគេ គឺភូមិត្រាច មានគ្រួសារសរុបចំនួន ៤៣៩គ្រួសារ ស្មើនឹង ២៨,៣ ភាគរយ និងមានប្រជានជនសរុបចំនួន ៤ ៤៤៨នាក់ ក្នុងនោះស្រ្តីចំនួន ២ ២១៩នាក់ ប្រជាពលរដ្ឋមានអាយុចាប់ពី១៨ឆ្នាំឡើងទៅមាន ២ ៩៣៦នាក់ ក្នុងនោះស្រ្តី ១ ៤៦៨ នាក់ ចំណែកឯភូមិដែលមានប្រជាជនតិចជាងគេ គឺភូមិរកា មានប្រជាជន ១៤៨ គ្រួសារ ស្មើនឹង ៩,៥៧ភាគរយ ហើយមានប្រជាជនសរុបចំនួន ៧៧៣នាក់ ស្រ្តីចំនួន ៣៨៧នាក់ ចំណែកប្រជាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅមានចំនួន ៥២០នាក់ ក្នុងនោះស្រ្តីចំនួន ២៦៩នាក់ ។

តារាង 2៖ ទិន្នន័យគ្រួសារ និងចំនួនប្រជាជនតាមបណ្តាភូមិ

| ឈ្មោះភូមិ | គ្រួសារ | គិតជា% | ចំនួនមនុស្ស | | | ១៨ឆ្នាំឡើង | | |
|---|---|---|---|---|---|---|---|---|
| | | | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| ត្នោត | ៣១០ | ២០,០ | ១៦៤៤ | ៨២៩ | ៨១៥ | ១១២៥ | ៥៥៥ | ៥៧០ |
| ចេក | ៣១៦ | ២០,៤ | ១៤៩៦ | ៧២២ | ៧៧៤ | ១១០៥ | ៥១៣ | ៥៩២ |
| ចក | ២០៤ | ១៣,១ | ៩៧៦ | ៤៧៨ | ៤៩៨ | ៦១៨ | ៣០០ | ៣១៨ |
| រកា | ១៤៨ | ៩,៥៧ | ៧៧៣ | ៣៨៦ | ៣៨៧ | ៥២០ | ២៥១ | ២៦៩ |
| នាងសល្វាច | ១៣០ | ៨,៤០ | ៧៩១ | ៤០៧ | ៣៨៤ | ៥២៧ | ២៧៣ | ២៥៤ |
| ត្រាច | ៤៣៩ | ២៨,៣ | ៤ ៤៤៨ | ២ ២២៩ | ២ ២១៩ | ២ ៩៣៦ | ១ ៤៦៨ | ១ ៤៦៨ |
| **សរុប** | **១ ៥៤៧** | **១០០** | **១០ ១២៨** | **៥ ០៥១** | **៥ ០៧៧** | **៦ ៨៣១** | **៣ ៣៦០** | **៣ ៤៧១** |

ប្រភពទិន្នន័យ៖ *CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់ចិនជើង ខែមិថុនា ឆ្នាំ២០១៨*

ដ្យាក្រាម 1៖ ស្ថិតិប្រជាជនឆ្នាំ ២០១៧




ប្រភពទិន្នន័យ៖ *CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់ចិនជើង ខែមិថុនា ឆ្នាំ២០១៨*

តារាង 3៖ ស្ថិតិប្រជាជន ឆ្នាំ២០១៧ តាមក្រុមអាយុ

| ក្រុមអាយុ | ២០១៧ | | | ផ្សេងៗ |
|---|---|---|---|---|
| | សរុប | ប្រុស | ស្រី | |
| អាយុពី០-២ឆ្នាំ | ៤៩០ | ២៥២ | ២៣៨ | កុមារ |
| អាយុពី៣-៤ | ៤០៨ | ២១៩ | ១៨៩ | អាយុចូលរៀនសាលាមត្តេយ្យ |
| អាយុពី៥ឆ្នាំ | ២៣៤ | ១២០ | ១១៤ | អាយុចូលរៀនសាលាមត្តេយ្យ |
| អាយុពី៦ឆ្នាំ | ២៣៥ | ១១៧ | ១១៨ | អាយុចូលរៀនសាលាបឋម |
| អាយុពី៧-១១ឆ្នាំ | ៨៦៨ | ៤៤៣ | ៤២៥ | អាយុចូលរៀនសាលាបឋម |
| អាយុពី១២-១៤ឆ្នាំ | ៥៣១ | ២៧៥ | ២៥៦ | អាយុចូលរៀនអនុវិទ្យាល័យ |
| អាយុពី១៥-១៧ឆ្នាំ | ៥៣១ | ២៦៥ | ២៦៦ | អាយុចូលរៀនវិទ្យាល័យ |
| អាយុពី១៨-២៤ឆ្នាំ | ១៣៣៧ | ៦៦៥ | ៦៧២ | អាយុចូលរៀនមហាវិទ្យាល័យ |
| អាយុពី២៥-៣៥ឆ្នាំ | ២២០៧ | ១០៧៩ | ១១២៨ | អាយុពេញពលកម្ម |
| អាយុពី៣៦-៤៥ឆ្នាំ | ១២៤៨ | ៦១៥ | ៦៣៣ | អាយុពេញពលកម្ម |
| អាយុពី៤៦-៦០ឆ្នាំ | ១១៩២ | ៥៩៦ | ៥៩៦ | អាយុពេញពលកម្ម |
| អាយុពី៦១ឆ្នាំឡើង | ៨៤៧ | ៤០៥ | ៤៤២ | អាយុចូលនិវត្តន៍ |
| **សរុប** | **១០ ១២៨** | **៥ ០៥១** | **៥ ០៧៧** | |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ កំពង់ចិនជើង ខែមិថុនា ឆ្នាំ២០១៨*

## ខ. អត្រាកំណើន ដង់ស៊ីតេ និងរបាយប្រជាជន

ដោយយោងតាមអត្រាកំណើនគ្រួសារ និងប្រជាជនពីចន្លោះឆ្នាំ២០១៣ ដល់ ឆ្នាំ២០១៧ បង្ហាញឱ្យឃើញថា អត្រាកំណើនប្រជាជននៅក្នុងឃុំកំពង់ចិនជើង មានការធ្លាក់ចុះខ្លាំងនៅឆ្នាំ ២០១៥ ដែលមានចំនួន -៦,៩៧ ភាគរយ មូលហេតុនៃការធ្លាក់ចុះនេះ បើតាមការសិក្សាស្រាវជ្រាវបានបង្ហាញថា គ្រួសារខ្លះបានយល់ដឹងពីកម្មវិធីពន្យាកំណើត ជាបណ្តើរៗ ការធ្វើចំណាកស្រុក និងការផ្លាស់ប្តូរទីលំនៅរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ប៉ុន្តែយើងសង្កេតឃើញថានៅ ឆ្នាំ២០១៤ អត្រាកំណើននេះបានកើនឡើងខ្ពស់ ដែលមានចំនួន ២២,១០ ភាគរយ មូលហេតុនៃការកើនឡើងនេះ ដោយសារកម្រិតជីវភាពល្អប្រសើរ មានចំណូលស្រុក អត្រាកំណើតច្រើន និងអត្រាមរណៈទាប ។ នៅក្នុងឃុំមានអត្រា កំណើនគ្រួសារជាមធ្យម ៨៤ គ្រួសារ/ឆ្នាំ និងចំនួនអត្រាកំណើនប្រជាជនជាមធ្យម ៥៣៦នាក់/ឆ្នាំ ។ ឃុំកំពង់ចិនជើង មានដង់ស៊ីតេប្រជាជនគិតជាមធ្យម ២៦០នាក់/គ.ម$^{២}$ ។ ប្រជាជនភាគច្រើនចូលចិត្តរស់នៅជាលក្ខណៈប្រមូលផ្តុំ គ្នាតាមដងផ្លូវ ឬតាមទីប្រជុំជន ជាពិសេសនៅតាមបណ្តោយផ្លូវជាតិលេខ៦ និងផ្លូវសំខាន់ៗនៅក្នុងឃុំ ។

តារាង 4៖ ស្ថិតិប្រជាជនតាមបណ្តាឆ្នាំ និងការគណនាអត្រាកំណើនមធ្យម

| ចំនួន | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | កំណើន មធ្យម | កំណើន/ឆ្នាំ |
|---|---|---|---|---|---|---|---|
| ចំនួនប្រជាជនសរុប | ៨ ៤០០ | ១០ ២៥៦ | ៩ ៥៤១ | ៩ ៦០២ | ១០ ១២៨ | | ៥៣៦ |
| កំណើនមធ្យម(%) | ៥,២២ | ២២,១០ | -៦,៩៧ | ០,៦៤ | ៥,៤៨ | ៥,២៩ | |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ កំពង់ចិនជើង ខែកញ្ញា ឆ្នាំ២០១៨*

**៖ចំណាំ**

- អត្រាកំណើនសម្រាប់ចន្លោះឆ្នាំ ៖ (ឆ្នាំចុងក្រោយ-ឆ្នាំដំបូង)x១០០/ឆ្នាំដំបូង
- អត្រាកំណើនមធ្យមប្រចាំឆ្នាំ៖ (បូកសរុបអត្រាកំណើនតាមឆ្នាំនិមួយ/ចំនួនឆ្នាំ)

### គ. ជនជាតិ ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់

នៅក្នុងឃុំកំពង់ចិនជើង មានជនជាតិខ្មែរ និងខ្មែរកាត់ចិន ហើយភាគច្រើនកាន់សាសនាព្រះពុទ្ធ និងចំនួនតិចតួចកាន់សាសនាគ្រិស្ត ហើយប្រជាជនភាគច្រើននៅក្នុងឃុំគោរពប្រពៃណីនិងទំនៀមទម្លាប់បែបខ្មែរ ដូចជា ពិធីរៀបមង្គលការប្រារព្ធពីធីបុណ្យទាននៅតាមវត្តអារាមនិង និមន្តព្រះសង្ឃសូត្រមន្តតាមផ្ទះ ពិធីបូជាសព និងមួយចំនួនតិចមានទំនៀមទម្លាប់បែបចិន ដូចជាពិធីសែនព្រេនដូនតា ពីធីបញ្ចុះសព និងភាគតិចបំផុតមានទំនៀមទម្លាប់បែបសាសនាគ្រិស្ត ដូចជា មានប្រារព្ធពិធីចូលព្រះវិហារគ្រិស្តនៅរៀងរាល់ថ្ងៃអាទិត្យជាដើម។ល។ និយាយរួមប្រជាជនក្នុងឃុំ តែងតែប្រារព្ធពិធីបុណ្យទានតាមប្រពៃណីទំនៀមទំលាប់ពីបុរាណរៀងមក តាមជំនឿបែបខ្មែរ បែបចិន និងបែបគ្រិស្តសាសនា ។

### ឃ. របររកទទួលទាន

នៅឃុំកំពង់ចិនជើង មានប្រជាជន ៣៩៩៣នាក់ ស្មើនឹង ៧៩,១ភាគរយ ប្រកបមុខរបរកសិកម្មជាចម្បង នៅក្នុងនោះមុខរបរបន្ទាប់បន្សំផ្នែកកសិកម្មមានចំនួន ៧៨០នាក់ ស្មើនឹង ៧៩,៥ភាគរយ រីឯមុខរបរចម្បងផ្នែកសេវាកម្មមានចំនួន ១ ០៣៥នាក់ ស្មើនឹង ២០,៥ភាគរយ ក្នុងនោះបន្ទាប់បន្សំផ្នែកនេះមិនមានទេ ចំណែកមុខរបរសិប្បកម្មជាចម្បងមានចំនួន ១៨នាក់ ស្មើនឹង ០,៤ភាគរយ ហើយបន្ទាប់បន្សំមិនមាននោះទេ មុខរបរទាំងអស់នោះមានដូចជា៖ នេសាទត្រី ធ្វើស្រែ ចិញ្ចឹមសត្វ ចិញ្ចឹមក្រពើ ឡើងត្នោត ដាំដំណាំបន្លែ កម្មករសំណង់ ស៊ីឈ្នួលដកស្ទូងតិចតួច លក់ដូរ(បបរនំបញ្ចុក ចេក ចៀន) ជាងចម្លាក់ ជាងទង ជាងជួសជុលកង់ម៉ូតូ រថយន្ត ជាងកាត់ដេរ ជាងកាត់សក់ ជាមន្ត្រីរាជការ អាជីវកលក់ដូរ ធ្វើការជាមួយវិស័យឯកជន និងអង្គការនានា ហើយភាគច្រើនមានជំនាញច្បាស់លាស់ ។

តារាង 5៖ តារាងមុខរបរ

| **បរិយាយ** | | **២០១៧** |
|---|---|---|
| សរុបអ្នកមានមុខរបរចម្បង | | ៥ ០៤៦ នាក់ |
| **សរុបអ្នកមានមុខរបរចម្បងក្នុងផ្នែកកសិកម្ម** | | **៣ ៩៩៣នាក់** |
| %**អ្នកមានមុខរបរចម្បងផ្នែកកសិកម្ម(គិតក្នុងមុខរបរចម្បង)** | | **៧៩**,**១**% |
| %**ស្រីមានមុខរបរចម្បងផ្នែកកសិកម្ម(គិតក្នុងមុខរបរចម្បង)** | | **៣៥**,**៧**% |
| ក្នុងនោះ | %អ្នកមានមុខរបរធ្វើស្រែ | ៦៩,៥% |
| | %អ្នកមានមុខរបរដាំដំណាំចម្ការរយៈពេលវែង | ០,៦% |
| | %អ្នកមានមុខរបរដាំដំណាំចម្ការរយៈពេលខ្លី | ១,៨% |
| | %អ្នកមានមុខរបរដាំដំណាំបន្លែ | ១,៧% |
| | %អ្នកមានមុខរបរនេសាទ | ២,៤% |
| | %អ្នកមានមុខរបរចិញ្ចឹមសត្វ | ៣,១% |
| | %អ្នកមានមុខរបរពីអនុផលព្រៃឈើ | ០,០% |

| បរិយាយ | | ២០១៧ |
|---|---|---|
| **សរុបអ្នកបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសិប្បកម្ម** | | **១៨នាក់** |
| **%អ្នកបម្រើការងារក្នុងផ្នែកសិប្បកម្ម** | | **០,៤%** |
| **%ស្រីបម្រើការងារក្នុងផ្នែកសិប្បកម្ម** | | **០,១%** |
| ក្នុងនោះ | %អ្នកបម្រើការងារសិប្បកម្មត្បាញរវៃ | ០,០% |
| | %អ្នកបម្រើការងារសិប្បកម្មផលិតពីផ្ដៅ វល្លិ ល្ពាក់.. | ០,០% |
| | %អ្នកបម្រើការងារសិប្បកម្មផលិតគ្រឿងសង្ហារឹម | ០,៣% |
| | %អ្នកបម្រើការងារសិប្បកម្មចម្លាក់ធ្វើពីឈើ ថ្ម ស្លាន់.. | ០,០% |
| | %អ្នកបម្រើការងារសិប្បកម្មផលិតពីដែក អាលុយមីញ៉ូម | ០,០% |
| | %អ្នកបម្រើការងារសិប្បកម្មផលិតពីជ័រ ប្លាស្ទិក .. | ០,០% |
| | %អ្នកបម្រើការងារសិប្បកម្មកែច្នៃ ឬ វិចខ្ចប់គ្រាប់ធញ្ញជាតិ | ០,០% |
| | %អ្នកបម្រើការងារសិប្បកម្មផលិតផ្សេងៗ | ០,០% |
| **សរុបអ្នកបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសេវាកម្ម** | | **១ ០៣៥នាក់** |
| **%អ្នកបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសេវាកម្ម** | | **២០,៥%** |
| **%ស្រីបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសេវាកម្ម** | | **៩,៩%** |
| ក្នុងនោះ | %អ្នកបម្រើការងារលក់ដូរ និងជំនួញ | ៣,៧% |
| | %អ្នកបម្រើការងារជាជាងជួសជុល | ០,៧% |
| | %អ្នកបម្រើការងារក្នុងផ្នែកដឹកជញ្ជូន | ១,០% |
| | %អ្នកបម្រើការងារស៊ីឈ្នួលក្នុងវិស័យកសិកម្ម កម្មករសំណង់ | ៥,០% |
| | %អ្នកបម្រើការងារក្នុងវិស័យឯកជន(កម្មកររោងចក្រ បុគ្គលិកអង្គការ) | ៨,៨% |
| | %អ្នកបម្រើការងារជាមន្ត្រីរាជការ | ១,៣% |

ប្រភពទិន្នន័យ៖ *CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ កំពង់ចិនជើង ខែមិថុនា ឆ្នាំ២០១៨*

ប្រជាពលរដ្ឋនៅក្នុងឃុំកំពង់ចិនជើងបានបង្កើតមុខរបរបន្ទាប់បន្សំបន្ថែមទៀត ក្រៅពីមុខរបរចម្បង ដើម្បីទ្រទ្រង់ជីវភាពក្នុងគ្រួសារឲ្យកាន់តែប្រសើរឡើង យោងទៅតាមទិន្នន័យមន្ទីរផែនការឆ្នាំ២០១៧ បានបង្ហាញឱ្យឃើញថា ប្រជាជនដែលមានមុខរបរបន្ទាប់បន្សំផ្នែកសិកម្ម មាន ៧៨០នាក់ ស្មើនឹង ៧៩,៥ភាគរយ ក្នុងនោះមានស្ត្រីចំនួន ៤១៣នាក់ ស្មើនឹង ៤២,១ភាគរយ និងមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្ម មានចំនួន ២០,៥ភាគរយ មាន ស្រី ៨,៤ភាគរយ ។

ដូច្នេះតាមព័ត៌មានខាងលើបានបង្ហាញឱ្យឃើញថាប្រជាពលរដ្ឋនៅក្នុងឃុំកំពង់ចិនជើង ក្រៅពីប្រកបរបរធ្វើស្រែជាចម្បង មានប្រជាពលរដ្ឋប្រមាណជិតពាក់កណ្តាល បានខិតខំប្រកមុខរបរបន្ទាប់បន្សំថែមទៀត ដូចជាលក់ដូរ និងជំនួញ ផ្នែកដឹកជញ្ជូន និងកម្មករសំណង់។ល។ ចំណែកអ្នក ដែលមានរបរផ្នែកសេវាកម្ម ជាចម្បងស្ទើរតែទាំងអស់ បានខិតខំប្រកបរបរកសិកម្ម ដែលជាមុខរបរបន្ទាប់បន្សំបន្ថែមទៀតផងដែរ ដូចមានរៀបរាប់ក្នុងតារាងខាងក្រោមនេះ៖

តារាង 6៖ តារាងមុខរបរបន្ទាប់បន្សំ

| **បរិយាយ** | **២០១៧ (%)** | **២០១៧ ចំនួន(នាក់)** |
|---|---|---|
| %អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកកសិកម្ម | ៧៩,៥% | ៧៨០ នាក់ |
| %ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកកសិកម្ម | ៤២,១% | ៤១៣ នាក់ |
| %អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកសិប្បកម្ម | 0,0% | 0 នាក់ |
| %ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកសិប្បកម្ម | 0,0% | 0 នាក់ |
| %អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្ម | ២0,៥% | 0 នាក់ |
| %ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្ម | ៨,៤% | ៨២នាក់ |

ប្រភពទិន្នន័យ៖ *CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ កំពង់ចិនជើង ខែមិថុនា ឆ្នាំ២០១៨*

### ង. ចំណាកស្រុក និងចំណូលស្រុក

កត្តាដែលធ្វើឲ្យមានការផ្លាស់ប្តូរលំនៅឋាន គឺដោយសារតែនៅភូមិចាស់ដែលគាត់បានរស់នៅពិបាកក្នុងការរកស៊ី និងគ្មានការងារធ្វើនៅក្នុងភូមិ ព្រមទាំងមូលហេតុមួយចំនួនទៀតដូចជា៖ ស្ថានភាពដី នៅក្នុងតំបន់មូលដ្ឋានមួយចំនួនមានការប្រែប្រួលដោយដីខូច ងាប់សារធាតុបំប៉ុង ហើយឡើងខ្សោះ ឬហិរជាដើម ខ្វះប្រភពទឹក ធ្វើឲ្យទទួលបានទិន្នផលទាប តម្លៃផលិតផលកសិកម្មមិនទៀងទាត់ និងគ្មានទីផ្សារផលិតផល ចំណែកសមាជិកក្នុងគ្រួសារកើនឡើង និងមួយចំនួនទៀតជាប់បំណុលធនាគារនិងមីក្រូហិរញ្ញវត្ថុជាដើម។ល។ ការផ្លាស់ប្តូរលំនៅឋានប្រជាជនមួយចំនួនទៅរស់នៅទីប្រជុំជនឃុំ/សង្កាត់ ស្រុក/ក្រុង រាជធានី/ខេត្ត និងទៅធ្វើការងារនៅប្រទេសផ្សេងៗ មូលហេតុចម្បងនៃការធ្វើចំណាកស្រុកគ្រប់ប្រភេទ គឺក្នុងគោលបំណងលើកស្ទួយតម្លៃសេដ្ឋកិច្ចនៅក្នុងគ្រួសារ ។ តាមរបាយការណ៍របស់រដ្ឋបាលឃុំ នៅក្នុងឃុំកំពង់ចិនជើង គ្រួសារផ្លាស់លំនៅឋានចូលមានចំនួន ១៨គ្រួសារ មានមនុស្សសរុបចំនួន ៦៨នាក់ ក្នុងនោះស្រីចំនួន ៣៧នាក់ និងគ្រួសារផ្លាស់លំនៅឋានចេញមាន ១៥គ្រួសារ មនុស្សសរុបចំនួន ៥១នាក់ ក្នុងនោះស្រីចំនួន ២៨នាក់ ។

តារាង 7៖ ស្ថិតិប្រជាជនផ្លាស់ប្តូរទីលំនៅក្នុងឆ្នាំ២០១៧

| **ល.រ** | **បរិយាយ** | **ចំនួនគ្រួសារ** | **ចំនួនប្រជាជនសរុប** | |
|---|---|---|---|---|
| | | | **សរុប** | **ស្រី** |
| ១ | ចំនួនគ្រួសារផ្លាស់លំនៅឋានចូល | ១៨ | ៦៨ | ៣៧ |
| ២ | ចំនួនគ្រួសារផ្លាស់លំនៅឋានចេញ | ១៥ | ៥១ | ២៨ |

ប្រភពទិន្នន័យ៖ *ក្រុមប្រឹក្សាឃុំ កំពង់ចិនជើង ខែមិថុនា ឆ្នាំ២០១៨*

ដោយយោងទៅតាមទិន្នន័យមន្ទីរផែនការខេត្ត ឆ្នាំ២០១៧ បានបង្ហាញថា ប្រជាជនក្នុងឃុំកំពង់ចិនជើង បានធ្វើចំណាកស្រុកចេញទៅរកស៊ីនៅស្រុកផ្សេងៗ ឬ ទៅប្រទេសជិតខាងដូចជា៖ប្រទេសថៃ ម៉ាឡេស៊ីនិងកូរ៉េជាដើម ដោយពួកគាត់ទៅធ្វើការនៅទីនោះ តែមួយរយៈប៉ុណ្ណោះ និងត្រលប់មកស្រុកកំណើតវិញបន្ទាប់ពីចប់កុងត្រាការងារ។ នៅក្នុងឃុំកំពង់ចិនជើងទាំងមូលប្រជាពលរដ្ឋធ្វើចំណាក ស្រុកមានចំនួន ៥៩៩នាក់ ដែលមានស្រីចំនួន ៣១៨នាក់ នៅក្នុងនោះអ្នកធ្វើចំណាកស្រុកក្នុងប្រទេសមានចំនួន ៣៩៥នាក់ ស្រីចំនួន ២០៥នាក់ និងអ្នកធ្វើចំណាកស្រុកក្រៅប្រទេសមានចំនួន ២០៤ នាក់ ស្រី ១១៣នាក់ ។

ប្រជាជនធ្វើចំណាកស្រុកចេញទៅរកស៊ីនៅស្រុក និងខេត្តផ្សេងៗ ឬទៅប្រទេសជិតខាង ដោយសារកត្តាមួយចំនួនដូចខាងក្រោមៈ

- ដីបង្កបង្កើនផលសម្រាប់វិស័យកសិកម្មតិចតួច ធ្វើស្រែបានផលតិច
- ការធ្វើស្រែចម្ការបានតែមួយរដូវ និងគ្មានទីផ្សារគ្រប់គ្រាន់សម្រាប់លក់ផលិតផល
- មិនមានការងារគ្រប់គ្រាន់នៅក្នុងស្រុក
- ជំពាក់បំណុលធនាគារ ឬឯកជនមិនមានលទ្ធភាពសង
- គ្មានមុខរបរច្បាស់លាស់ និងមានប្រាក់ចំណូលប្រចាំថ្ងៃទាប។
- កំណើនសមាជិកគ្រួសារមានការកើនឡើង។
- ដោយធ្វើស្រែប្រើឧបករណ៍ពាក់កណ្តាលស្វ័យប្រវត្តិធ្វើឱ្យកម្លាំងពលកម្មថយចុះ។
- គ្រួសារមានដីតិចតួចមិនគ្រប់គ្រាន់ក្នុងការចិញ្ចឹមគ្រួសារ បន្ទាប់មកលក់ចេញទៅស្រុកផ្សេង។

តារាង ៩៖ ស្ថិតិប្រជាជនចំណាកស្រុក

| បរិយាយ | ២០១៦ | | | ២០១៧ | | |
|---|---|---|---|---|---|---|
| | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| ចំនួនអ្នកធ្វើចំណាកស្រុកក្នុងប្រទេស | ៣៧៩ | ១៩៤ | ១៨៥ | ៣៩៥ | ១៩០ | ២០៥ |
| ចំនួនអ្នកធ្វើចំណាកស្រុកក្រៅប្រទេស | ២០០ | ៩៦ | ១០៤ | ២០៤ | ៩១ | ១១៣ |
| សរុប | ៥៧៩ | ២៩០ | ២៨៩ | ៥៩៩ | ២៨១ | ៣១៨ |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ កំពង់ចិនជើង ខែមិថុនា ឆ្នាំ២០១៨*

### ១.១.៣. ស្ថានភាពសេដ្ឋកិច្ច

#### ក. ប្រភពចំណូលចម្បង និងបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋ

បើតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានត្រង់ចំណុចការវិភាគចំណាត់ថ្នាក់ទ្រព្យធនបានឱ្យដឹងថាគ្រួសារដែលមានជីវភាពគ្រាន់បើ មធ្យមនិងក្រមានប្រភពចំណូលទី១ គឺស្រូវ ប្រភពចំណូលទី២សម្រាប់អ្នកគ្រាន់បើវិញគឺចិញ្ចឹមសត្វ សម្រាប់អ្នកមធ្យមគឺដំណាំ ចំណែកអ្នកក្រនិងក្រីក្រគឺលក់កម្លាំងពលកម្ម និងប្រភពចំណូលទី៣ សម្រាប់អ្នកគ្រាន់បើគឺជួលគ្រឿងចក្រ និងអ្នកមធ្យមវិញគឺចិញ្ចឹមសត្វចំណែកអ្នកក្រវិញគឺចញ្ចឹមមាន់ ចំណែកគ្រួសារក្រីក្រវិញគឺលក់កម្លាំងពលកម្ម ។

#### ខ. កម្រិតជីវភាពរស់នៅ ចំណូល ចំណាយប្រចាំថ្ងៃ ប្រចាំឆ្នាំ

បើយោងទៅតាមតារាងចំណាត់ថ្នាក់ទ្រព្យធន នៅក្នុងឆ្នាំ ២០១៧ ដែលទទួលបានពីរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានខាងលើ បានបង្ហាញឱ្យឃើញថា ក្នុងឆ្នាំ២០១៧ ប្រជាពលរដ្ឋក្នុងឃុំកំពង់ចិនជើងមានកម្រិតជីវភាពរស់នៅ ដោយចែកចេញជាបួនកម្រិត គឺ ១)គ្រួសារបង្គួរ/គ្រាន់បើ មានចំនួន ៣,៣៦ ភាគរយដែលជាគ្រួសារ មានកម្រិតជីវភាពធូរធាជាងគេនៅក្នុងឃុំ មានដីកាន់កាប់ពី ០,៣០ ទៅ ៤,៧ហិកតា ២)គ្រួសារមធ្យមមានចំនួន ៥៦,៣៦ភាគរយ ជាចំនួនច្រើនជាងគេ (លើសពាក់កណ្តាល) មានដីកាន់កាប់ពី ០,២៥ ហិកតា ទៅ ២,៧៥ហិកតា ៣)គ្រួសារក្រមានចំនួន ២៧,២៧ ភាគរយ មានដីកាន់កាប់ពី ០,១៥ហិកតា ទៅ ០,៦ហិកតា

និង ៤)គ្រួសារក្រណាស់ ជាគ្រួសារក្រីក្របំផុត និងមានចំនួនតិចជាងគេត្រឹមតែ ១២,៩៩ភាគរយ មានដីកាន់កាប់ ០,១០ ហិកតា ចុះក្រោមរហូតដល់អ្នកគ្មានដី ។

ប្រជាពលរដ្ឋនៅក្នុងឃុំកំពង់ចិនជើងមានចំណូលប្រចាំថ្ងៃជាមធ្យម ៣០ ០០០-៤០ ០០០រៀល/គ្រួសារ និងប្រចាំឆ្នាំស្មើនឹង ១០៩៥០០០០-១៤ ៦០០០០០រៀល/គ្រួសារ ចំណែកការចំណាយប្រចាំឆ្នាំដូចជា ស្បៀងអាហារ សម្លៀកបំពាក់ ឧបករណ៍ប្រើប្រាស់ សម្ភារៈសិក្សានិងថ្នាំសង្កូវ ព្រមទាំងការចំណាយផ្សេងៗទៀតស្មើនឹង ៧៣០ ០០០-១០ ៩៥០ ០០០រៀល/គ្រួសារ ។

តារាង ១៖ តារាងចំណាត់ថ្នាក់ទ្រព្យធននៅក្នុងឃុំឆ្នាំ២០១៧

| ចំណាត់ថ្នាក់ធនធាន | បង្គួរ/គ្រាន់បើ | មធ្យម | ក្រ | ក្រណាស់/ គ្មានដី | សរុប |
|---|---|---|---|---|---|
| -តំបន់ I លំនៅឋាននិងដំណាំចម្រុះ | ២៥% | ៤៥% | ២០% | ១០% | ១០០% |
| តំបន់ទី II ទំនាបមធ្យមដំណាំស្រូវ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១០០% |
| តំបន់ទី III ទំនាបទាបលិចទឹករយៈពេលខ្លី | ២៥% | ៤៥% | ២០% | ១០% | ១០០% |
| ទូទាំងឃុំ | ៣,៣៦% | ៥៦,៣៦% | ២៧,២៧% | ១២,៩៩% | ១០០% |
| ចំនួនគ្រួសារ/ឃុំ | ៥២ | ៨៧២ | ៤២២ | ២០១ | |
| ទំហំគ្រួសារ | ៤នាក់ /គ្រួសារ | ៥នាក់ /គ្រួសារ | ៥នាក់ /គ្រួសារ | ៥នាក់ /គ្រួសារ | |
| កម្លាំងពលកម្ម | ២នាក់ /គ្រួសារ | ៣នាក់ /គ្រួសារ | ២នាក់ /គ្រួសារ | ២នាក់ /គ្រួសារ | |
| ទំហំដីកាន់កាប់សរុប(ហត) | ៥ | ៣ | ០,៧៥ | គ្មាន | |
| ចំនួន និងប្រភេទក្បាលដី | ៦កន្លែង(ផ្ទះ និងស្រែ) | ៣កន្លែង (ផ្ទះនិងស្រែ) | ២កន្លែង (ផ្ទះនិងស្រែ) | គ្មាន | |
| ដីលំនៅឋាន(ហត) | ០,៣០ | ០,២៥ | ០,១៥ | ០,១០ | |
| ដីស្រែ(ហត) | ៤,៧ | ២,៧៥ | ០,៦ | គ្មាន | |
| ដីផ្សេងៗទី១ (ហត) | គ្មាន | ០,៣០ ដាំបន្លែលើដីស្រែ | គ្មាន | គ្មាន | |
| ដីផ្សេងៗទី២ (ហត) | គ្មាន | គ្មាន | គ្មាន | គ្មាន | |
| ប្រភេទពូជស្រូវដាំដុះ | ផ្ការំដួល ពូជ៨៥ | ផ្ការំដួល ផ្កាម្លិះ ពូជ៨៥ ពូជក្រមួន | ផ្ការំដួល ផ្កាម្លិះ ពូជ៨៥ ពូជក្រមួន | គ្មាន | |
| ធនធានកសិដ្ឋាន | | | | | |
| ដំណាំទី១៖ ស្រូវ (ហត) | ៧,៧ | ២,៧៥ | ០,៦០ | គ្មាន | ១០០% |
| ដំណាំទី២៖ ពោត (ហត) | គ្មាន | ០,៣០ | គ្មាន | គ្មាន | ១០០% |

| | | | | | |
|---|---|---|---|---|---|
| ដំណាំទី៣៖ បន្លែ(សណ្តែកកួរ) | គ្មាន | គ្មាន | គ្មាន | គ្មាន | ១០០% |
| ការចិញ្ចឹមត្រី ក្រពើ | ក្រពើ២៥គ្រួសារ ត្រី២០គ្រួសារ | ៣០គ្រួសារ | គ្មាន | គ្មាន | ១០០% |
| ចំនួនគោ - ក្របី | ៣ក្បាល/គ្រួសារ | ២ក្បាល/គ្រួសារ | ១ក្បាល /គ្រួសារ | គ្មាន | ១០០% |
| ចំនួនជ្រូក | ៨គ្រួសារ | ១០គ្រួសារ | គ្មាន | គ្មាន | ១០០% |
| ការប្រើប្រាស់ឧបករណ៍នេសាទ | សាច់លប សាច់អួនចារាវ | សាច់អួន ចងសន្ទូច បង់សំណាញ់ ចងសន្ទូច | បង់សំណាញ់ អួន មង សន្ទូច | គ្មាន | ១០០% |
| ប្រភពចំណូលទី១៖ | ស្រូវ | ស្រូវ | ស្រូវ | លក់កម្លាំងពលកម្ម | |
| ប្រភពចំណូលទី២៖ | ចិញ្ចឹមគោ ក្របី ទា មាន់ | ដំណាំយកប្រាក់ (ពោតត្រសក់ ឪឡឹក) | លក់កម្លាំងពលកម្ម | លក់កម្លាំងពលកម្ម | |
| ប្រភពចំណូលទី៣៖ | ជួលគ្រឿងចក្រ | ចិញ្ចឹមមាន់ ទា | ចិញ្ចឹមមាន់ | ខ្ចីស្បៀង ខ្ចីអ្នកជិតខាង សងវិញពេល | |
| ការងារក្រៅពីកសិកម្ម (ប្រភេទពលកម្ម) | ជួលគ្រឿងចក្រ | កាត់ដេរ សំណង់ (តាមរដូវកាល) | កាត់ដេរ សំណង់ | កាត់ដេរ សំណង់ | |
| ការប្រើប្រាស់ឥណទាន | ACLEDA (៩០%) | ប្រាសាក់ អម្រុត អេអិមខេ ក្រេឌីត អេស៊ីលីដា (៨០%) | ខ្ចីពីធនាគារឬមីក្រូហិរញ្ញវត្ថុ (២០%) | ខ្ចីអ្នកភូមិឬជិតខាង(ក្រ ១ មិនហ៊ានជំពាក់ធនាគារទេ ដោយគ្មានទ្រព្យតម្កល់) | |

ប្រភពទិន្នន័យ៖ *របាយការណ៍ក្សេត្រ-បរិស្ថាន និងក្រុមប្រឹក្សាឃុំកំពង់ចិនជើង ខែមិថុនា ឆ្នាំ២០១៧*

### គ. ស្ថានភាពចំណុលសរុប និងអត្រាការប្រាក់

ប្រជាពលរដ្ឋនៅក្នុងឃុំកំពង់ចិនជើង មានចំនួន៣១២គ្រួសារ ស្មើនឹងប្រមាណ២០,១៦ភាគរយ ដែលជាប់បំណុលនៅ មីក្រូហិរញ្ញវត្ថុ និងធនាគារ ដូចមានរាយខាងក្រោម៖

- អ្នកបង្គួរ៖ មានលទ្ធភាពខ្ចីប្រាក់ពីធនាគារ យកមកចងការបន្ត និងពង្រីកមុខរបរដូចជា កសិកម្ម សិប្បកម្ម និងលក់ដូរ
- អ្នកមធ្យម៖ មានលទ្ធភាពខ្ចីប្រាក់ពីធនាគារយកមកចងការបន្ត និងពង្រីកមុខរបរដូចជា កសិកម្ម សិប្បកម្ម និងលក់ដូរ

- អ្នកក្រ៖ ពុំមានលទ្ធភាពខ្ចីប្រាក់ពីធនាគារ/ឯកជន គ្មានទ្រព្យប្រចាំ
- អ្នកក្រណាស់៖ លក់ពលកម្ម និងចំណាកស្រុក

នៅក្នុងឃុំកំពង់ចិនជើង មានទីតាំងមីក្រូហិរញ្ញវត្ថុឬសាខាចំនួន១កន្លែង និងធនាគារ ០១កន្លែង។ ហើយក្នុងនោះដែរ ប្រជាពលរដ្ឋបានទទួលសេវាកម្ចីលុយពីមីក្រូហិរញ្ញវត្ថុ និងធនាគារមួយចំនួននៅក្រៅឃុំមានដូចជា៖ ធនាគារអេស៊ីលីដា ធនាគារស្ថាបនា ធនាគារប្រៃសណីយ៍ និងមីក្រូហិរញ្ញវត្ថុអម្រឹត មីក្រូហិរញ្ញវត្ថុហត្ថាកសិករ មីក្រូហិរញ្ញវត្ថុប្រាសាក់ មីក្រូហិរញ្ញវត្ថុអេអឹមខេ មីក្រូហិរញ្ញវត្ថុវីសិនហ្វាន់ មីក្រូហិរញ្ញវត្ថុក្រេឌីត មីក្រូហិរញ្ញវត្ថុសហគ្រិន មីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី និងសហគមន៍សន្សំប្រាក់ ០៣ភូមិ អត្រាការប្រាក់ ០៣% ហើយសម្រាប់អត្រាការប្រាក់ អាស្រ័យលើចំនួនទឹកប្រាក់ដែលខ្ចី បើចំនួនប្រាក់កាន់តែច្រើន អត្រាការប្រាក់កាន់តិច ០,៩៩ភាគរយ តែបើទឹកប្រាក់កាន់តិច អត្រាការប្រាក់កាន់តែច្រើន ១,៨ ភាគរយ ។

### ឃ. ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់ ឬក្រោមរូបភាពផ្សេងៗ

ជាទូទៅនៅឃុំកំពង់ចិនជើងមានការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់សុទ្ធ ដើម្បីយកទៅប្រើប្រាស់ពង្រីកមុខរបរ ចងការបន្ត ទិញសម្ភារៈកសិកម្ម ទិញជី និងប្រើប្រាស់តាមតម្រូវការចាំបាច់ផ្សេងៗទៀត ក៏នៅមានក្រោមរូបភាពប្រជាពលរដ្ឋមួយចំនួនទៅទទួលយកជីដាក់ស្រូវមុន និងសន្យាសងប្រាក់នៅពេលប្រមូលផលស្រូវផងដែរ ។

### ង. ជំនួយពីប្រភពផ្សេងៗ

ប្រជាពលរដ្ឋនៅក្នុងឃុំកំពង់ចិនជើង ពួកគាត់អាចទទួលបាននូវប្រភពចំណូលពីប្រភពផ្សេងៗដូចជា៖

- ចំណាកស្រុកក្រៅប្រទេស(ពលករផ្នែក កសិកម្ម ឧស្សាហកម្ម) ដូចជាប្រទេសថៃ កូរ៉េជាដើម
- និងចំណូលមួយចំនួនតូចទៀត គឺបានមកពីគ្រួសារ ឬបងប្អូនរស់នៅជាអចិន្ត្រៃយ៍នៅបរទេស ដែលពួកគាត់បានផ្ញើមកដើម្បីផ្គត់ផ្គង់គ្រួសារនៅស្រុកខ្មែរ ។

## ១.១.៤. ស្ថានភាពសិក្សាធិការ

### ក. ស្ថានភាពអប់រំ

បើយោងតាមផែនការអភិវឌ្ឍន៍ឃុំកំពង់ចិនជើង៥ឆ្នាំ (២០១៧-២០២២) បានឱ្យដឹងថា ជារៀងរាល់ឆ្នាំកុមារា កុមារីគ្រប់អាយុចូលរៀនបានចុះឈ្មោះចូលរៀនគ្រប់គ្នា ទោះបីជាកុមារស្ថិតនៅក្នុងស្ថានភាពគ្រួសារក្រីក្រ គ្រួសារដែលជាស្ត្រីមេម៉ាយ ឬក្មេងកំព្រា កុមារពិការក៏ដោយក្តី ។ មកដល់ពេលបច្ចុប្បន្ន វិស័យអប់រំនៅក្នុងឃុំកំពង់ចិនជើង មានការរីកចម្រើនជាងមុនដូចជា៖ អគារសិក្សាត្រូវបានសាងសង់ថ្មីៗ និងមានការកែលម្អបន្ទប់រៀនថែមទៀតនៅតាមសាលារៀនគ្រប់កម្រិត ដែលផ្តល់លទ្ធភាពឱ្យសិស្សបានរៀនសូត្រគ្រប់ពេល ពុំមានការខ្វះខាតឡើយ ។ ចំណុចអវិជ្ជមានក៏មាននៅក្នុងឃុំផងដែរដូចជា៖ ខ្វះគ្រូបង្រៀន មិនទាន់មានសាលាមត្តេយ្យសហគមន៍គ្រប់គ្រាន់នៅតាមភូមិនៅឡើយ មានអ្នកមិនចេះអក្សរ(អនក្ខរជន) ជាពិសេសមនុស្សវ័យចំណាស់ពួកគាត់ពុំសូវមានស្មារតីសិក្សារៀនសូត្រ ទោះបីមានការយកចិត្តទុកដាក់ជម្រុញលើកទឹកចិត្តពីអាជ្ញាធរមូលដ្ឋានយ៉ាងណាក៏ដោយ ។

រូបភាព 1៖ សាលារៀន


សាលាបឋមសិក្សា


សាលាបឋមសិក្សា

នៅក្នុងឃុំកំពង់ចិនជើង មានកម្រិតសិក្សាចាប់ពីមត្តេយ្យសិក្សារហូតដល់អនុវិទ្យាល័យសម្រាប់វិទ្យាល័យវិញមិនទាន់មាននោះទេ តែមាននៅខាងក្រៅឃុំ ។ សាលាមត្តេយ្យមានចំនួន ០៤ កន្លែង ដែលមានបន្ទប់រៀនចំនួន០៤ និងថ្នាក់រៀនមានចំនួន ០៤ថ្នាក់ គ្រូបង្រៀនមានចំនួន ០៤នាក់ជាស្ត្រី ហើយសិស្សកំពុងរៀនមានចំនួន ១៦៩នាក់ ក្នុងនោះមានស្រីចំនួន ៨៦នាក់ ។ សាលាបឋមសិក្សាវិញមានចំនួន ០៥កន្លែង ដែលមាន ៣៥បន្ទប់ថ្នាក់រៀនចំនួន ៣៥ថ្នាក់ គ្រូបង្រៀនជាបុរសចំនួន ០៨នាក់ ជាស្ត្រី ១២នាក់ ហើយសិស្សដែលកំពុងរៀនមានចំនួនសរុប ៨៦៥នាក់ ដែលមានសិស្សស្រីចំនួន ៤១៤នាក់ ។ ចំណែកឯសាលាអនុវិទ្យាល័យវិញមាន០១កន្លែង ០៥បន្ទប់ និង ០៤ថ្នាក់ ហើយគ្រូដែលបង្រៀនមានចំនួន ១០នាក់ ក្នុងនោះស្ត្រី ០៦នាក់ និងសិស្សដែលកំពុងរៀនចំនួន ១៥០នាក់ មានស្រីចំនួន ៨២នាក់ ។

តារាង 10៖ ស្ថិតិសាលារៀន ស្ថានភាពអប់រំ និងសិក្សាធិការក្នុងឃុំឆ្នាំ២០១៧

| ស្ថានភាពសាលា | ចំនួនសាលារៀន | | | ចំនួនសិស្ស | | គ្រូបង្រៀន | |
|---|---|---|---|---|---|---|---|
| | សាលា | បន្ទប់ | ថ្នាក់ | សរុប | ស្រី | សរុប | ស្រី |
| ១.សាលាមត្តេយ្យ | ៤ | ៤ | ៤ | ១៦៩ | ៨៦ | ៤ | ៤ |
| ២.សាលាបឋមសិក្សា | ៥ | ៣៥ | ៣៥ | ៨៦៥ | ៤១៤ | ២០ | ១២ |
| ៣.អនុវិទ្យាល័យ | ១ | ៥ | ៤ | ១៥០ | ៨២ | ១០ | ៦ |
| ៤.វិទ្យាល័យ | 0 | 0 | 0 | 0 | 0 | 0 | 0 |
| **សរុបរួម** | **១០** | **៤៤** | **៤៣** | **១១៨៤** | **៥៨២** | **៣៤** | **២២** |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ កំពង់ចិនជើង ខែមិថុនា ឆ្នាំ២០១៨*

### ខ .ស្ថានភាពអក្ខរកម្ម

នៅក្នុងឃុំកំពង់ចិនជើង ប្រជាពលរដ្ឋដែលមានអាយុពី១៥ទៅ៤៥ឆ្នាំ មានចំនួន ៥ ៣២៣នាក់ ហើយក្នុងអ្នកដែលមិនចេះអក្សរមានចំនួន១,៣ភាគរយ ។ អ្នកមិនចេះអក្សរមានអាយុពី១៥ ទៅ២៤ឆ្នាំមិនមាននោះទេ ហើយអាយុពី ២៥ ទៅ៤៥ឆ្នាំ មានចំនួនសរុប ៧០នាក់ ស្មើនឹង ០២ភាគរយ ។

ប្រជាជនភាគច្រើនមិនបានចូលរៀនដោយសារកត្តាខ្លួនឯង ជីវភាព និងការធ្វើចំណាកស្រុកតាមឪពុកម្តាយ ។ ប្រជាពលរដ្ឋនៅតែមានកង្វះមធ្យោបាយធ្វើដំណើរទៅសាលារៀន ខ្វះឱកាសសម្រាប់ទិញសម្ភារៈ សិក្សា សម្លៀកបំពាក់ និងផ្នត់គំនិតរបស់ឪពុក ម្តាយចាស់គំរឹលឬមិនជឿនលឿន ។ ទោះបីយ៉ាងនោះក្តី នៅក្នុងឃុំនៅមានថ្នាក់អក្ខរកម្មជាប្រចាំ តែពួកគាត់ពុំទាន់មានពេលចូលសិក្សា ព្រោះជាប់រវល់ប្រកបរបរចិញ្ចឹមជីវិត ជាហេតុនាំមកនូវការភ្លេចអក្សរ នៅក្នុងចំណោមអ្នកដែលបានចូលមកសិក្សាក្នុងថ្នាក់អក្ខរកម្មកន្លងមក ។

**-អនុវិស័យអប់រំក្រៅប្រព័ន្ធ**

ក្របខ័ណ្ឌស្ថាប័ន និងគោលនយោបាយ បានពង្រឹងតាមរយៈការពិនិត្យឡើងវិញ នូវគោលនយោបាយអប់រំក្រៅប្រព័ន្ធ ការបង្កើតអនុក្រុមការងារអប់រំក្រៅប្រព័ន្ធ និងមានភារកិច្ចច្បាស់លាស់ ការវាយតម្លៃសមត្ថភាពអប់រំក្រៅប្រព័ន្ធ និងការកសាងផែនទី ក៏ដូចជាការពិនិត្យឡើងវិញនូវកម្មវិធីចូលរៀនឡើងវិញ ព្រមទាំងការរៀបចំសេចក្តីណែនាំស្តីពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ និងកម្មវិធីសមមូល ។ ដើម្បីធ្វើការជម្រុញឱ្យផែនការយុទ្ធសាស្ត្រអនុវិស័យអប់រំក្រៅប្រព័ន្ធបានទទួលជោគជ័យ ត្រូវបន្តអនុវត្តសកម្មភាពដូចខាងក្រោម៖

១.បន្តពង្រឹងសកម្មភាពមជ្ឈមណ្ឌលសិក្សាសហគមន៍ បណ្ណាល័យ និងមណ្ឌលអានដែលមានស្រាប់

២. បន្តពង្រឹងការអនុវត្តកម្មវិធីសមមូលបឋមសិក្សា និងមធ្យមសិក្សា

៣. អនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ

៤. បន្តអនុវត្តការងារអក្ខរកម្មតាមការជាក់ស្តែង

៥. បន្តអនុវត្តកម្មវិធីចូលរៀនឡើងវិញ។

តារាង 11៖ ស្ថិតិអ្នកមិនចេះអក្សរ

| បរិយាយ | ២០១៦ | ២០១៧ |
|---|---|---|
| ចំនួនអ្នកមិនចេះអក្សរអាយុ១៥-២៤ឆ្នាំ | ២ នាក់ | ០០នាក់ |
| %អ្នកមិនចេះអក្សរអាយុ១៥-២៤ឆ្នាំ | ០,១% | ០០% |
| ចំនួនអ្នកមិនចេះអក្សរអាយុ២៥-៤៥ឆ្នាំ | ៨៥នាក់ | ៧០នាក់ |
| %អ្នកមិនចេះអក្សរអាយុ២៥-៤៥ឆ្នាំ | ២,៨% | ២% |
| សរុបមនុស្សអាយុ១៥-៤៥ឆ្នាំ | ៤ ៨៤៩នាក់ | ៥ ៣២៣នាក់ |
| %អ្នកមិនចេះអក្សរអាយុ១៥-៤៥ឆ្នាំ | ១,៨% | ១,៣% |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ កំពង់ចិនជើង ខែមិថុនា ឆ្នាំ២០១៨*

## គ. ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត

បើយោងទៅតាមប្រភពទិន្នន័យមន្ទីរផែនខេត្តឆ្នាំ២០១៧បានបង្ហាញឱ្យឃើញថាលទ្ធភាពក្នុងការបន្តការសិក្សារបស់សិស្សនៅក្នុងឃុំកំពង់ចិនជើងទៅថ្នាក់ខ្ពស់ទៀតមានដូចខាងក្រោម៖

- អាយុពី១២-១៤ឆ្នាំរៀនអនុវិទ្យាល័យសរុបចំនួន ១១៤នាក់ ស្រីមានចំនួន ៤៩នាក់
- អាយុពី១៥-១៧ឆ្នាំរៀនអនុវិទ្យាល័យសរុបចំនួន ១៣៥នាក់ ស្រីមានចំនួន ៧២នាក់
- អាយុពី១៥-១៧ឆ្នាំរៀនវិទ្យាល័យសរុបចំនួន ១០៦នាក់ ស្រីមានចំនួន ៤៩នាក់
- អាយុពី១៨-២៤ឆ្នាំរៀនវិទ្យាល័យសរុបចំនួន ១១១នាក់ ស្រីមានចំនួន ៤៣នាក់

- អាយុពី១៨-២៤ឆ្នាំរៀនសកលវិទ្យាល័យសរុបចំនួន ៥៤នាក់ ស្រីមានចំនួន ០៦នាក់។
- អាយុពី២៥-៣៥ឆ្នាំរៀនសកលវិទ្យាល័យសរុបចំនួន ៣០នាក់ ស្រីចំនួន ២០នាក់
- អាយុពី១៨-២៤ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈសរុបចំនួន ១១នាក់ ស្រីចំនួន ០៥នាក់
- អាយុពី២៥-៣៥ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈសរុបចំនួន ១៥នាក់ ស្រីចំនួន ១០នាក់

តារាង 12៖ ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត

| ការអប់រំតាមក្រុមអាយុ | សរុប | ស្រី |
|---|---|---|
| អាយុពី១២-១៤ឆ្នាំរៀនអនុវិទ្យាល័យ | ១១៤ | ៤៩ |
| អាយុពី១៥-១៧ឆ្នាំរៀនអនុវិទ្យាល័យ | ១៣៥ | ៧២ |
| អាយុពី១៥-១៧ឆ្នាំរៀនវិទ្យាល័យ | ១០៦ | ៤៩ |
| អាយុពី១៨-២៤ឆ្នាំរៀនវិទ្យាល័យ | ១១១ | ៩៥ |
| អាយុពី១៨-២៤ឆ្នាំរៀនសកលវិទ្យាល័យ | ៥៤ | ៤៣ |
| អាយុពី២៥-៣៥ឆ្នាំរៀនសកលវិទ្យាល័យ | ៣០ | ២០ |
| អាយុពី១៨-២៤ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ | ១១ | ៥ |
| អាយុពី២៥-៣៥ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ | ១៥ | ១០ |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់ចិនជើង ខែមិថុនា ឆ្នាំ២០១៨*

## ១.១.៤. ស្ថានភាពសុខាភិបាល

មណ្ឌលសុខភាព គឺជាកន្លែងផ្តល់សេវាអប់រំសុខភាពថែទាំ និងព្យាបាលអ្នកជម្ងឺផ្សេងៗដែលជាកន្លែងសាធារណៈរបស់រដ្ឋ ។ ឃុំកំពង់ចិនជើងមិនមានមណ្ឌលសុខភាពនោះទេ ប៉ុន្តែតែប្រជាពលរដ្ឋប្រើប្រាស់សេវាមណ្ឌលសុខភាពស្ទោង ដែលមានគ្រូពេទ្យចំនួន ០៩នាក់ ពេទ្យឆ្មប ០៣នាក់ ហើយមានបន្ទប់ ០៦ និងគ្រែ ០៣ ស្ថានភាពមាតា និងទារកនៅក្នុងឃុំកំពង់ចិនជើង ស្ត្រីសម្រាលកូនដោយឆ្មបបុរាណក្នុង១ឆ្នាំកន្លងទៅមិនមានទេ ស្ត្រីដែលសម្រាលកូនដោយឆ្មបមានការបណ្តុះបណ្តាលក្នុង១ឆ្នាំកន្លងទៅមាន១១៦នាក់ ទារកដែលបានកើតរស់មិនមានទេ ស្ត្រីដែលសម្រាលកូនដោយឆ្មបមានការបណ្តុះបណ្តាលក្នុង១ឆ្នាំកន្លងទៅមាន ១១៦នាក់ មរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ០-១ ខែដោយឆ្មបបុរាណមិនមានទេ មរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោ០-១ខែដោយឆ្មបពេទ្យមាន ០២នាក់ មរណភាពទារកចន្លោះអាយុ០-១ខែ ដោយឆ្មបបុរាណមិនមានទេ មរណភាពទារកចន្លោះអាយុ០-១ខែដោយឆ្មបពេទ្យ ០២ នាក់ ទារកដែលបានចុះសំបុត្រកំណើតមាន ៨៩ នាក់ កុមារដែលមានអាយុចន្លោះពី៩-១២ខែមាន ៦៦នាក់ កុមារដែលមានអាយុចន្លោះពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួនមាន៦៦នាក់ ដែលការចាក់ថ្នាំបង្ការជម្ងឺផ្សេងៗនេះធ្វើនៅមណ្ឌលសុខភាពនិងតាមភូមិជូនប្រជាពលរដ្ឋមានជម្ងឺមួយចំនួនដូចជា៖ ជម្ងឺកញ្ជ្រិល ស្វិតដៃជើង ក្អកមាន់ របេង តេតាណូស រលាកថ្លើមប្រភេទបេ ផ្តាសាយបក្សី គ្រុនចាញ់ រាករូស និងគ្រុនឈាម ។ ករណីជម្ងឺធ្ងន់ធ្ងរការបញ្ជូនអ្នកជម្ងឺដោយមធ្យោបាយខ្លួនឯងផ្ទាល់មកមណ្ឌលសុខភាពព្រោះមណ្ឌលសុខភាពស្ថិតនៅជិតពួកគាត់ ឯការបញ្ជូនទៅមន្ទីរពេទ្យបង្អែក ដោយមធ្យោបាយផ្ទាល់ខ្លួន និងរថយន្តសង្គ្រោះរបស់ពេទ្យបង្អែកទាំងការចំណាយវាយផ្សេងៗជាបន្ទុករបស់អ្នកជម្ងឺ ក្នុងករណីអ្នកជម្ងឺមិនមានប័ណ្ណក្រីក្រ ។

តារាង 13៖ សុខភាពមាតានិងទារក

| ល.រ | សុខភាពមាតានិងទារក | ឆ្នាំ២០១៧ |
|---|---|---|
| ១ | ចំនួនបុគ្គលិកពេទ្យនៅមណ្ឌលសុខភាព | ៩ |
| ២ | ចំនួនពេទ្យឆ្មបនៅមណ្ឌលសុខភាព | ៣ |
| ៣ | ចំនួនឆ្មបបុរាណនៅមណ្ឌលសុខភាព | 0 |
| ៤ | ចំនួនបន្ទប់នៅមណ្ឌលសុខភាព | ៦ |
| ៥ | ចំនួនគ្រែនៅមណ្ឌលសុខភាព | ៣ |
| ៦ | ចំនួនឆ្មបដែលបានបណ្តុះបណ្តាលមានក្នុងភូមិ | ២ |
| ៧ | ចំនួនស្ត្រីដែលសម្រាលកូនដោយឆ្មបបុរាណក្នុង១ឆ្នាំកន្លងទៅ | 0 |
| ៨ | ចំនួនស្ត្រីដែលសម្រាលកូនដោយឆ្មបមានការបណ្តុះបណ្តាលក្នុង ១ឆ្នាំកន្លងទៅ | ១១៦ |
| ៩ | ចំនួនទារកដែលបានកើតរស់ដោយឆ្មបបុរាណ | 0 |
| ១០ | ចំនួនទារកដែលបានកើតរស់ដោយឆ្មបពេទ្យ | ១១៦ |
| ១១ | ចំនួនមរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ 0-១ខែដោយឆ្មបបុរាណ | 0 |
| ១២ | ចំនួនមរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ 0-១ខែដោយឆ្មបពេទ្យ | ២ |
| ១៣ | ចំនួនមរណភាពទារកក្នុងចន្លោះអាយុ 0-១ខែដោយឆ្មបបុរាណ | 0 |
| ១៤ | ចំនួនមរណភាពទារកក្នុងចន្លោះអាយុ 0-១ខែដោយឆ្មបពេទ្យ | ២ |
| ១៥ | ចំនួនទារកដែលបានចុះសំបុត្រកំណើត | ៨៩ |
| ១៦ | ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែ | ៦៦ |
| ១៧ | ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួន | ៦៦ |

ប្រភពទិន្នន័យ៖ *ក្រុមប្រឹក្សាឃុំ កំពង់ចិនជើង ខែមិថុនា ឆ្នាំ២០១៨*

រូបភាព 2៖ មន្ទីរពេទ្យបង្អែកស្ទោង



យោងតាមទិន្នន័យ ពីមន្ទីរផែនការខេត្ត នៅក្នុងឆ្នាំ២០១៧ បានឱ្យដឹងថា ចម្ងាយពីភូមិនីមួយៗទៅកាន់មន្ទីរពេទ្យបង្អែកស្ទោង គឺមានចម្ងាយពី១ទៅ ៨គីឡូម៉ែត្រប៉ុណ្ណោះ សម្រាប់ភូមិនៅឆ្ងាយជាងគេគឺភូមិនាងសល្ងាច ដែលមានចម្ងាយ ៨គីឡូម៉ែត្រ ដូចមានក្នុងតារាងសង្ខេបខាងក្រោម ។ ចំណែកស្ថានភាពផ្លូវទៅកាន់មណ្ឌលសុខភាពវិញ ក៏មិនពិបាកក្នុងការធ្វើដំណើរដែរ ដែលអំណោយផលដល់ការបញ្ជូនអ្នកជម្ងឺទៅកាន់មណ្ឌលសុខភាពបានទាន់ពេលវេលា ។

តារាង 14៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព

| ល.រ | ឈ្មោះភូមិ | ចម្ងាយជាមធ្យម ពីភូមិទៅមណ្ឌលសុខភាព | ផ្សេងៗ |
|---|---|---|---|
| ១ | ត្នោត | ១ គីឡូម៉ែត្រ | |
| ២ | ចេក | ១,៥ គីឡូម៉ែត្រ | |
| ៣ | ចក | ៣ គីឡូម៉ែត្រ | |
| ៤ | រកា | ៤ គីឡូម៉ែត្រ | |
| ៥ | នាងសល្ងាច | ៨ គីឡូម៉ែត្រ | |
| ៦ | ត្រាច | ៥ គីឡូម៉ែត្រ | |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់ចិនជើង ខែមិថុនា ឆ្នាំ២០១៨*

ដ្យាក្រាម 2៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មន្ទីរពេទ្យបង្អែកស្រុកស្ទោង




*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់ចិនជើង ខែមិថុនា ឆ្នាំ២០២០*

### ១.១.៦. ស្ថានភាពយេនឌ័រ

បើតាមផែនការអភិវឌ្ឍន៍ឃុំកំពង់ចិនជើងរយៈពេល៥ឆ្នាំ (២០១៨-២០២២) បានឱ្យដឹងថាសមភាពការងាររបស់ស្ត្រី និងបុរសក្នុងឃុំកំពង់ចិនជើងនាពេលបច្ចុប្បន្នគ្មានការរើសអើង ឬគាបសង្កត់ទៅលើស្ត្រីនោះទេ ផ្ទុយទៅវិញ ការងារយេនឌ័រកំពុងមានការគាំទ្រយ៉ាងពេញទំហឹង ជាក់ស្តែងនៅក្នុងការងារមានថ្នាក់ដឹកនាំជាស្ត្រីនៅថ្នាក់ភូមិ និងថ្នាក់ឃុំកំពុងតែត្រូវបានលើកកម្ពស់ និងលើកទឹកចិត្តស្ត្រីឱ្យមានការចូលរួមយ៉ាងសកម្ម នៅក្នុងការកសាងផែនការអភិវឌ្ឍន៍ឃុំ ក៏ដូចជាផែនការវិនិយោគផងដែរ ។ ទោះជាយ៉ាងនេះក្តី បញ្ហាប្រឈមនៅតែកើតមានឡើងទៅលើសមត្ថភាពស្ត្រី ដោយស្ត្រីមួយចំនួនមានកម្រិតជីវភាពក្រីក្រ ខ្លះត្រូវបានបោះបង់ការសិក្សាដើម្បីរកចំណូលមកទ្រទ្រង់ជីវភាពនៅក្នុងគ្រួសារ និងអ្នកខ្លះចំណាកស្រុកទៅភ្នំពេញ ដើម្បីធ្វើកម្មកររោងចក្រ។ ដើម្បី

ដោះស្រាយបញ្ហានេះក្រុមប្រឹក្សាឃុំ បានសហការជាមួយមន្ទីរការិយាល័យជំនាញៗ និងដៃគូអភិវឌ្ឍនានាជំរុញ និងលើកទឹកចិត្តឱ្យមានការបណ្តុះបណ្តាលបច្ចេកទេសនានា និងជំនាញវិជ្ជាជីវៈបង្កើនមុខរបរថ្មីៗ ដើម្បីបង្កើននូវប្រាក់ចំណូលនិងកាត់បន្ថយការចំណាកស្រុក ។ ប៉ុន្តែបើតាមរបាយការណ៍នៃការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ឃុំកំពង់ចិនជើងឆ្នាំ២០១៧ បានឱ្យដឹងអំពីតួនាទីយេនឌ័រក្នុងការចូលរួមសកម្មភាពការងារផលិតកម្មកសិកម្ម និងការងារទូទៅក្នុងជីវភាពគ្រួសាររបស់កសិករក្នុងឃុំកំពង់ចិនជើង មានលម្អិតក្នុងតារាងខាងក្រោម ។

តារាង 15៖ ការវិភាគលើតួនាទីយេនឌ័រ ឃុំកំពង់ចិនជើង

| សកម្មភាព | បុរស | ស្ត្រី | យោបល់បន្ថែម |
|---|---|---|---|
| ស្រូវវស្សា និង ប្រាំង | | | |
| ការរៀបចំដីលើកទី១ | ១០០% | | |
| ការរៀបចំដីលើកទី២ | ១០០% | | |
| ការត្រាំពូជ | ២០% | ៨០% | ស្ត្រីស្រង់សំដីស្រូវ និងរៀបចំ កន្លែងត្រាំពូជ |
| ព្រោះ | ៨០% | ២០% | ស្ត្រីជញ្ជូនពូជ |
| ការដាក់ជីបំប៉ន | ៧០% | ៣០% | ស្ត្រីជួយដាក់ជី |
| ការគ្រប់គ្រងទឹកស្រែ | ៦០% | ៤០% | |
| ការបាញ់ថ្នាំសម្លាប់ស្មៅ | ១០០% | | |
| ការច្រូតកាត់ | ៥០% | ៥០% | |
| ការដឹកជញ្ជូន | ១០០% | | |
| ការហាលសម្ងួត | ៤០% | ៦០% | |
| ការទុកដាក់ស្រូវ | ៤០% | ៦០% | |
| លក់ស្រូវ | ៤០% | ៦០% | |
| សកម្មភាពមុខរបរចិញ្ចឹមជីវិតសំខាន់ផ្សេងទៀត | | | |
| សួនបន្លែ | ៥០% | ៥០% | |
| ចិញ្ចឹមជ្រូក | ៥០% | ៥០% | |
| ចិញ្ចឹមគោ ក្របី | ៥០% | ៥០% | |
| ចិញ្ចឹមមាន់ ទា | ៤០% | ៦០% | |
| ការប្រមូលអនុផលព្រៃឈើ | ៨៥% | ១៥% | |
| រកត្រី | ៨០% | ២០% | ស្ត្រីធ្វើផ្អក ប្រហុក |
| ជំនួញទូទៅ | ៣៥% | ៥៥% | |
| ការថែទាំប្រព័ន្ធធារាសាស្ត្រ | គ្មាន | គ្មាន | |
| ដំណាំឪឡឹក | | | |
| ការរៀបចំដី | ១០០% | | |
| ភ្ជួរ | ១០០% | | |
| រាស់ | ១០០% | | |

| | | | |
|---|---|---|---|
| ឆ្កូតរង | ៨០% | ២០% | |
| ដាក់ជី | ៥០% | ៥០% | |
| ផ្ដុំរង | ៥០% | ៥០% | |
| ដាំគ្រាប់ | ២០% | ៨០% | |
| ដាក់ជីបំប៉ន | ៥០% | ៥០% | |
| ពូនរង | ៥០% | ៥០% | |
| បូមទឹក | ៧០% | ៣០% | ស្រ្តីជួយជញ្ជូនទុយយោ |
| ថែទាំ | ៥០% | ៥០% | |
| លក់ដោយម៉ៅ | ៤៥% | ៥៥% | |

ប្រភពទិន្នន័យ៖ *របាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន*

យោងតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំកំពង់ចិនជើង ឆ្នាំ២០១៧ បានរកឃើញពីការវិភាគតួនាទីយេនឌ័រក្នុងឃុំកំពង់ចិនជើងដូចខាងក្រោម៖

១. ស្ត្រីភាគច្រើនជាអ្នកផលិតកសិកម្ម

២. បុរសទៅរកចំណូលនៅឆ្ងាយៗផ្ទះ

៣. ស្ត្រីមើលថែការងារនៅផ្ទះជាប្រចាំ

៤. សកម្មភាពការងារមានការចូលរួមធ្វើទាំងអស់គ្នា

៥. ការងារធ្ងន់ៗជាបន្ទុករបស់បុរស

តាមប្រភពព័ត៌មានដែលទទួលបាន ដូចមានរៀបរាប់ខាងលើពាក់ព័ន្ធ ការលើកកម្ពស់សមភាព យេនឌ័រ និងសិទ្ធិអំណាចស្ត្រីនៅក្នុងឃុំកំពង់ចិនជើង យើងសង្កេតឃើញថា បុរស និងស្ត្រីមិនមានការរើសអើងគ្នាធ្ងន់ធ្ងរនោះទេ គឺមានភាពលំអៀងតិចតួចប៉ុណ្ណោះ ដូចជាការងារធ្វើស្រែសង្កេតឃើញបុរសមានការចូលរួមច្រើនជាងស្ត្រី ជាពិសេសការងាររៀបចំដីស្រែ ឃើញថាការងារនេះបុរសទទួលរ៉ាប់រងស្ទើរតែទាំងស្រុង ដែលស្ត្រីមានកម្លាំងទន់ខ្សោយជាងជាអ្នកចម្អិនអាហារនៅផ្ទះ ចំណែកការងារដឹកជញ្ជូនគ្រាប់ស្រូវ បាញ់ថ្នាំសម្លាប់សត្វល្អិត និងការដាក់ជី ច្រូតកាត់ និងការងារទុកដាក់ស្រូវជាដើម គឺបុរសបានចូលរួមច្រើនជាងស្ត្រី ប៉ុន្តែការងារក្នុងផ្ទះ និងនៅជិតផ្ទះ ឃើញស្ត្រីបានចូលរួមច្រើនជាងបុរសវិញ តែនៅក្នុងនោះក៏បានរកឃើញថា ការសម្រេចចិត្តក្នុងគ្រួសារបុរសនៅមានសិទ្ធិច្រើនជាងស្ត្រី និងមានស្ត្រីមួយចំនួននៅទទួលរងអំពើហិង្សានៅក្នុងគ្រួសារនៅឡើយ ។ ប៉ុន្តែទោះបីមានបញ្ហាប្រឈមខ្លះក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិអំណាចស្ត្រីក៏ដោយ ក៏យើងឃើញកិច្ចការនេះមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដែលទៅថ្ងៃអនាគតនឹងឈានទៅកាន់តែប្រសើរឡើង ។

## ១.២. ស្ថានភាពភូមិសាស្ត្រ

### ១.២.១. ទីតាំងភូមិសាស្ត្រ

ឃុំកំពង់ចិនជើង ជាឃុំមួយនៅក្នុងស្រុកស្ទោង ខេត្តកំពង់ធំ ដែលស្ថិតនៅទិសពាយព្យទីរួមខេត្ត និងមានចម្ងាយប្រហែល ៥២គីឡូម៉ែត្រ ពីទីរួមខេត្តធំ មានទីតាំងផ្អែកលើនិយាមកាផែនទី(អាប់ស៊ីស) ៤៥១ ៩៥៦,២៨ និង(អ័រដោនេ) ១ ៤៣២ ១៩៣,១៦។ សណ្ឋានដីនៅក្នុងឃុំកំពង់ចិនជើង បើផ្អែកទៅតាមរបាយការណ៍ស្តីពីការ

វិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំបានឱ្យដឹងថា ជាដីមិនរាបស្មើមានទាបមានខ្ពស់ដោយបានចែកចេញជា ០៣តំបន់ដូចខាងក្រោម៖

**តំបន់ទី I**៖ ស្ថិតនៅភាគខាងកើតឆៀងខាងជើងនៃឃុំ គឺជាតំបន់លំនៅឋាន និងដំណាំចម្រុះ ស្ថានភាពដីតំបន់ជម្រាលខ្ពស់មានលំនៅឋានស្របនឹងដងស្ទឹង និងតាមផ្លូវជាតិលេខ៦ ជាប្រភេទដីឥដ្ឋ (ពណ៌លឿនភ្លាវ) ហើយមានប្រភពទឹកស្ទឹងស្ទោង អូរជីម៉ាស អូរក្អឹម អូរខាន់សារ ស្រះ និងអណ្តូង(លូ ស្នប់)។ តំបន់លំនៅឋាន និងដំណាំចម្រុះ ដីមានជីជាតិកម្រិតមធ្យម និងមានបញ្ហាកត្តាចង្រៃលើដំណាំស្រូវវស្សាជាពិសេសពូជផ្ការំដួលនិងមានការយាយីពីសត្វកណ្តុរ សត្វល្អិត ជម្ងឺបំផ្លាញនិងពុំមានប្រព័ន្ធស្រោចស្រព ប៉ុន្តែប្រសិនបើបញ្ហាទាំងនេះ ត្រូវបានដោះស្រាយ គឺតំបន់នេះមានសក្តានុពល សម្រាប់ផលិតកម្មស្រូវជាលក្ខណៈគ្រួសារបែបពាណិជ្ជកម្ម ។

**តំបន់ទី II**៖ នៅភាគខាងត្បូងនៃឃុំ ជាតំបន់ទំនាបមធ្យមដំណាំស្រូវ ស្ថានភាពដីជម្រាលមធ្យមជាប្រភេទដីល្បាយខ្សាច់(ក្រហមភ្លាវ) ហើយមានប្រភពទឹកមកពី បឹងបវែង បឹងត្របែក បឹងរហាល បឹងរហាលកណ្តាល ប្រឡាយចាស់ អូរអន្លង់ក្រពើ(តពីអូរជីម៉ាស់) អូរចុងប្រាំង(តពីអូរសំខាន់)។ តំបន់នេះមានផលិតភាពយ៉ាងខ្លាំងដោយអាស្រ័យទៅលើជីជាតិដីមធ្យម និងមានប្រឡាយទឹក ស្រោចស្រពចាស់ៗ និងមានបឹង ត្រពាំងមួយចំនួនតូច ហើយរាក់ បច្ចុប្បន្នមានប្រើប្រាស់ត្រឹមតែ ពូជមានគុណភាពទាបគឺពូជ ស្រូវIR ៥០៤ និង៨៥ ដែលជាពូជស្រូវផលិតជាលក្ខណៈពាណិជ្ជកម្ម ។

**តំបន់ទី III**៖ នៅភាគខាងលិចនៃឃុំ ជាតំបន់ទំនាបទាបលិចទឹករយៈពេលខ្លី ហើយជាតំបន់ដាំដុះដំណាំស្រូវវស្សា ជាប្រភេទដីកណ្តេងល្បាប់លិចទឹកភ្លៀង (ពណ៌ទង់ដែង) មានប្រភពទឹកមកពីទឹកជំនន់ទន្លេសាប ពីស្ទឹង សល្វាច អូរទ្រទំជ្រឹង (តពីអូរខាន់សារ) ត្រពាំងថ្នាល់មាន់ ត្រពាំង (ក្នុងបរិវេណអាងស្តុកទឹកឯកជន សុង) ត្រពាំងអណ្តើក អាងស្តុកទឹកឯកជន( ចាន់ សីហា) អាងស្តុកទឹកឯកជន(អាន) អាងស្តុកទឹកឯកជន(សុង) អាងស្តុកទឹកឯកជន (សាយ គឹមឡុម) អាងស្តុកទឹកឯកជន (គក រិត)។ តំបន់នេះមានផលិតភាពយ៉ាងខ្លាំងដោយអាស្រ័យទៅលើជីជាតិដី និងអាងទឹកស្រោចស្រព។ ទោះជាយ៉ាងណាក៏មានការប្រើប្រាស់ត្រឹមតែពូជមានគុណភាពទាបគឺពូជស្រូវIR៥០៤ និង៨៥ ដែលបច្ចុប្បន្នគឺជាពូជស្រូវផលិតជាលក្ខណៈពាណិជ្ជកម្ម ។

ផែនទី 3៖ ផែនទីសណ្ឋានដីឃុំកំពង់ចិនជើង



ផែនទី 4៖ ផែនទីបង្ហាញតំបន់ក្សេត-បរិស្ថាន ឃុំកំពង់ចិនជើង




តារាង 16៖ ដ្យាក្រាមពំនុះកាត់ទទឹង ឃុំកំពង់ចិនជើង ស្រុកស្ទោង

| រូបថត កំពង់ចិនជើង |  |  |  |
|---|---|---|---|
| ឈ្មោះ តំបន់ | តំបន់ទី I<br>តំបន់លំនៅឋាន និងដំណាំចម្រុះ | តំបន់ទី II<br>តំបន់ទំនាបមធ្យមដំណាំស្រូវ | តំបន់ទី III<br>តំបន់ទំនាបទាបលិចទឹក<br>រយៈពេលខ្លី |
| រៀបរាប់ ដោយ សង្ខេប | មានជម្រាលមធ្យមមានដីលំនៅឋាន ស្រប និងដងស្ទឹង និងតាមផ្លូវជាតិលេខ៦ ប្រជាជនភាគច្រើនជាកសិកដាំដំណាំស្រូវ ដំណាំចម្រុះប្រើប្រាស់ | ជម្រាលលមធ្យមជាតំបន់ដាំដុះដំណាំស្រូវវស្សាស្រោចស្រព ដោយទឹកស្ទឹង ប្រឡាយ និង ទឹកភ្លៀងធ្វើស្រែប្រាំងមានតិចតួច | ជម្រាលទាបជាតំបន់ដាំដុះដំណាំស្រូវវស្សា ស្រោចស្រពដោយទឹកស្ទឹង ប្រឡាយ ទឹកជំនន់បឹងទន្លេសាប និងទឹកភ្លៀង ជាកន្លែងនេសាទត្រី និង |

| | | | |
|---|---|---|---|
| | ទឹកស្ទឹងគោល និង អណ្តូង | | លក់ដូរត្រីមានអាង ត្រពាំងស្តុកទឹក នៅរដូវ ប្រាំង និងធ្វើស្រែប្រាំង |
| ឋានលេខា | ជម្រាលមធ្យម | ជម្រាលមធ្យម | ជម្រាលទាប |
| ប្រភេទដី | កណ្តោងតដ្ឋ(ពណ៌លឿងភ្លាវ) | ល្បាយខ្សាច់(ក្រហមភ្លៀវ ) | កណ្តោងល្បាប់លិចទឹកទន្លេ(ពណ៌ទង់ដែង) |
| ជលសាស្ត្រ | - ស្រោចស្រពដោយទឹកភ្លៀង<br>ស្រោចស្រពដោយទឹកស្ទឹងស្ទោង និងស្ទឹងគោល | ស្រោចស្រពដោយទឹកភ្លៀង<br>ស្រោចស្រពដោយប្រឡាយចាស់ៗតិចតួច | ស្រោចស្រពដោយទឹកភ្លៀង<br>ស្រោចស្រពដោយទឹកស្ទឹងសល្ងាច<br>ស្រោចស្រពដោយជំនន់ទន្លេសាប |
| ធនធានទឹក | - ទឹកស្ទឹងស្ទោង<br>- ស្រះ<br>- អណ្តូង(លូ.ស្នប់)<br>- អូរជីម៉ាស<br>- អូរក្អឹម<br>អូរខ័ណ្ឌសារ | ប្រឡាយចាស់ បឹងបវែង<br>បឹងត្របែក.បឹងរហាល.<br>បឹងរហាលកណ្តាល<br>អូរអន្លង់ក្រពើ(តពីអូរជីម៉ាស)<br>អូរចុងប្រាំង(តពីអូរខាន់សារ)<br>អូរកំបុត | ទឹកជំនន់ទន្លេសាប<br>ស្ទឹងសល្ងាច<br>អូរទ្រនំជ្រឹង(តពីអូរខាន់សារ)<br>ត្រពាំងថ្នាលមាន់<br>ត្រពាំង(ក្នុងអាងស្តុកឯកជនសុង)<br>ត្រពាំងអណ្តើក<br>អាងស្តុកទឹកឯកជន( ចាន់ សីហា)<br>អាងស្តុកទឹកឯកជន (អាន)<br>អាងស្តុកទឹកឯកជន(សុង)<br>អាងស្តុកទឹកឯកជន(សាយគឹមឡុម)<br>អាងស្តុកទឹកឯកជន(គក រិត) |

ប្រភពទិន្នន័យ៖ *របាយការណ៍វិភាគប្រព័ន្ធកេ្សត្រ-បរិស្ថាន និងក្រុមប្រឹក្សាឃុំកំពង់ចិនជើង ខែមិថុនា ឆ្នាំ២០១៧*

ដោយយោងទៅតាមទិន្នន័យក្រុមការងារនិងរបាយការណ៍វិភាគកេ្សត្រ-បរិស្ថាន និងក្រុមប្រឹក្សាឃុំកំពង់ចិនជើងបង្ហាញថានៅក្នុងឃុំកំពង់ចិនជើងមានប្រភពទឹកសំខាន់ៗដូចជា ទឹកទន្លេសាបអាងស្តុកទឹក បឹង ត្រពាំង និងប្រឡាយមេចំនួន២ខ្សែ ដែលនាំពីស្ទឹងស្ទោង តាមរយៈប្រឡាយ៣០កញ្ញា ដែលហូរពីអាង៣០កញ្ញាក្នុងឃុំព្រះដំរី ។ នៅក្នុងឃុំកំពង់ចិនជើងមានប្រឡាយសរុបចំនួន ១៨ខ្សែ មានប្រវែង ៣៣ ៩៣០,៤២ម៉ែត្រ ដែលនៅក្នុងនោះប្រឡាយមេមានចំនួន២ខ្សែ ប្រវែង ៦ ០៣៣,៥៤ ម៉ែត្រ ប្រឡាយរង១ខ្សែប្រវែង ១ ១៨៦,២៨ ម៉ែត្រ និងប្រឡាយផ្សេងៗ ១៥ខ្សែ មានប្រវែង ២៦ ៧១០,៦០ ម៉ែត្រ ដែលបានធ្វើការបរិយាយពីប្រភេទប្រឡាយនីមួយៗនៅក្នុងតារាងខាងក្រោម៖ ផ្ទៃដីស្រែដែលទទួលបានការស្រោចស្រពពីប្រព័ន្ធធារាសាស្ត្រសរុប ១ ២៤៦ ហិកតា ស្មើនឹង ៨០ ភាគរយ នៅក្នុងនោះដីស្រែវស្សាទទួលបានពីប្រព័ន្ធស្រោចស្រពមានចំនួន ៥៧៧ហិកតា និងដីស្រែប្រាំងទទួលបានពីប្រព័ន្ធស្រោចស្រពចំនួន ៦៦៩ហិកតា ប៉ុន្តែតំបន់ខ្លះនូវមានកង្វះខាតនូវឡើយ ។

តារាង 17៖ ប្រព័ន្ធធារាសាស្ត្រ

| ល.រ | ប្រភេទផ្លូវ | ប្រវែង (ម) | ការពិពណ៌នាពីសសៃឈាមចរាចរណ៍ផ្លូវសេដ្ឋកិច្ចពិសេសក្នុងឃុំ |
|---|---|---|---|
| ១ | ប្រឡាយមេ | ៤៤៦២,៧២ | ប្រឡាយ ៣០កញ្ញាកសាងដោយក្រុមហ៊ុនចិន |
| ២ | ប្រឡាយមេ | ១៥៧០,៨២ | ប្រឡាយ ៣០កញ្ញាកសាងដោយក្រុមហ៊ុនចិន |
| ៣ | ប្រឡាយរង | ១១៨៦,២៨ | ប្រឡាយរងចាស់ ក្រោយភូមិត្រាច ក្បែរប្រឡាយមេ ៣០កញ្ញា |
| ៤ | ប្រឡាយតូច | ៣៦៩៤,១០ | ប្រឡាយចាស់ ក្រោយភូមិត្រាច ក្បែរប្រឡាយមេ ៣០កញ្ញា |
| ៥ | ប្រឡាយតូច | ១៥៧៥,៥៧ | ប្រឡាយចាស់ (ប្រឡាយជីក) ក្រោយភូមិត្រាច ក្បែរប្រឡាយមេ ៣០កញ្ញា |
| ៦ | ប្រឡាយតូច | ២២០៨,៤៥ | ក្បែរសាលាស្រុកស្ទោងកាត់ផ្លូវជាតិលេខ៦ទៅហួសប្រឡាយមេ៣០កញ្ញា |
| ៧ | ប្រឡាយតូច | ២២៤៩,២៩ | នៅខាងជើងភូមិរកា វត្តខ័ណ្ឌសរ (ប្រឡាយជីកខូចទ្រុឌទ្រោម) |
| ៨ | ប្រឡាយតូច | ៦៣១,៦៣ | នៅជាប់របង វត្តខ័ណ្ឌសរ (ប្រឡាយជីកខូចទ្រុឌទ្រោម) ភូមិចក |
| ៩ | ប្រឡាយតូច | ១៣១២,៩៦ | នៅខាងជើងភូមិ វត្តខ័ណ្ឌសរ ឆ្ពោះទៅប្លុក់ដីស្រែប្រាំង |
| ១០ | ប្រឡាយតូច | ៣៥៧៤,៦១ | ទំនប់ចាស់ ឬប្រឡាយតូចរបងយុទ្ធសាស្ត្រ កំពង់ចិនជើងនិងឃុំទ្រា |
| ១១ | ប្រឡាយតូច | ៣០៦៧,០៨ | ចេញពីប្រឡាយមេ ៣០កញ្ញា ធ្លាក់ក្បែរភូមិត្រាច អមផ្លូវ គ្រួស ក្រហម |
| ១២ | ប្រឡាយតូច | ១០៥៣,៥៩ | ប្រឡាយរងចាស់ក្រោយភូមិត្រាច ក្បែរប្រឡាយមេ ៣០កញ្ញា អមផ្លូវ |
| ១៣ | ប្រឡាយតូច | ១៥០៩,៩៤ | ប្រឡាយតូច (ចាស់) លើកអមប្រឡាយមេ ៣០កញ្ញា |
| ១៤ | ប្រឡាយតូច | ១០៨៣,២៧ | ប្រឡាយរងចាស់ ក្រោយភូមិត្រាច ក្បែរប្រឡាយមេ ៣០កញ្ញា អមផ្លូវ |
| ១៥ | ប្រឡាយតូច | ១២៥៦,១២ | ចេញពីប្រឡាយទី២ឆ្ពោះទៅលិចទល់ប្រឡាយទី៥ភូមិត្រាច |
| ១៦ | ប្រឡាយតូច | ១២៧៣,៣៦ | ភ្ជាប់ពីប្រឡាយទី៤ ភូមិត្រាច ឆ្ពោះទៅត្បូងទល់ប្រឡាយទី៩ ភូមិចក |
| ១៧ | ប្រឡាយតូច | ១០៨៦,៦០ | ភ្ជាប់ប្រឡាយទី១៥ ទៅត្បូងសាលាឃុំចាស់ រួចភ្ជាប់ប្រឡាយទី៩ភូមិចក |
| ១៨ | ប្រឡាយតូច | ១១៣៤,០៤ | បំបែកពីប្រឡាយទី១៤ ទៅកើតអមព្រះត្រពាំង ទៅទល់ផ្លូវជាតិលេខ៦ |

ប្រភពទិន្នន័យ៖ *ក្រុមការងារបច្ចេកទេស GIS អេស ប៊ី ខេ និងក្រុមប្រឹក្សាឃុំ កំពង់ចិនជើង ខែមិថុនា ឆ្នាំ២០១៨*

រូបភាព 3៖ ប្រព័ន្ធធារាសាស្ត្រ


ប្រឡាយរង


ប្រឡាយមេ

ផែនទី 5៖ ប្រព័ន្ធធារាសាស្ត្រឃុំកំពង់ចិនជើង



### ១.២.២. អាកាសធាតុ

នៅក្នុងឃុំកំពង់ចិនជើង ក៏ដូចជានៅទូទាំងខេត្ត គឺទទួលរបបខ្យល់ពីតំបន់ត្រូពិច ដែលមានអាកាសធាតុក្តៅហើយសើម ។ របបខ្យល់មូសុង បានពាំនាំមកនូវចំនួនទឹកភ្លៀងយ៉ាងច្រើនមកជាមួយ ដែលអំណោយផលទៅដល់ការធ្វើកសិកម្មនានា និងដាំដំណាំផ្សេងៗ ។

បើយោងទៅតាមប្រភពទិន្នន័យពីមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ធំ ប្រចាំស្រុកស្ទោងក្នុងឆ្នាំ ២០១៧ បានបង្ហាញឱ្យឃើញថា នៅក្នុងស្រុកស្ទោងទាំងមូលមានភ្លៀងធ្លាក់ចំនួន៨៩ដង និងមានបរិមាណទឹកភ្លៀងប្រចាំឆ្នាំចំនួន១៤២០ម.ម ។

**អំពីអាកាសធាតុ៖**

- រដូវរងារ៖ ខែ វិច្ឆិកា ដល់ ខែ មីនា (២០ ទៅ ២៨ អង្សា)
- រដូវក្តៅ៖ ខែ មីនា ដល់ ខែ ឧសភា (៣០ ទៅ ៣៥ អង្សា)
- រដូវភ្លៀង៖ ខែ ឧសភា ដល់ ខែ តុលា (២៣ ទៅ ៣០ អង្សា ជាមួយនិងការឡើងសំណើមទៅដល់ ៩០ ភាគរយ) នៅរដូវនេះជារៀងរាល់ឆ្នាំ គឺមានភ្លៀងធ្លាក់ខ្លាំង នៅពេលរសៀល និងល្ងាច។
-សំណើម៖ ឃុំកំពង់ចិនជើងមានសំណើមជាមធ្យម៤៨ភាគរយ និងមានល្បឿនខ្យល់៣គីឡូម៉ែត្រ/១ម៉ោង។

តារាង 18៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ

| ខែ | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| បរិមាណទឹកភ្លៀង | ២ | ១៥,៨ | ៣៧,៦ | ៩៨,៣ | ២០៣ | ១១១,៥ | ២០៨ | ២៥០ | ១៦៤,៥ | ១៤៤,៩ | ១១៧,៨ | ៦៦,៥ |
| ថ្ងៃមានភ្លៀង | ១ | ១ | ២ | ៨ | ១១ | ៦ | ១០ | ១៥ | ១០ | ៩ | ១០ | ៦ |

ប្រភពទិន្នន័យ៖ *មន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពង់ធំ ឆ្នាំ២០១៧*

ដ្យាក្រាម 3៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ




ប្រភពទិន្នន័យ៖ *មន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពង់ធំ ឆ្នាំ២០១៧*

### ១.២.៣. ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន

ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍រួមមាន ផ្លូវគោក ផ្លូវដែក ផ្លូវទឹក និងផ្លូវអាកាស ។ ប្រព័ន្ធផ្លូវដឹកជញ្ជូន ជាផ្នែកមួយដ៏សំខាន់ក្នុងការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច មិនត្រឹមតែប៉ុណ្ណោះផ្លូវមានតួនាទីដ៏សំខាន់ក្នុងការភ្ជាប់ទំនាក់ទំនងពីឃុំមួយទៅឃុំមួយពីភូមិមួយទៅភូមិមួយឬទៅកាន់ស្រុក ដែលមានព្រំប្រទល់ជាប់គ្នាដូចជា៖ការធ្វើដំណើរ ការដឹកជញ្ជូនផលិតផលកសិកម្ម និងសម្ភារៈផ្សេងៗទៀត ។ នៅក្នុងឃុំកំពង់ចិនជើងមានផ្លូវសំខាន់ៗ ០៣ ខ្សែ ក្នុងនោះខ្សែទី១ ប្រវែង ៧ ៦៤៦,៤០ម៉ែត្រ ជាផ្លូវជាតិលេខ៦ចេញពីចេញពីព្រំប្រទល់ឃុំកំពង់ចិនជើងត្បូងឆ្ពោះដល់ព្រំប្រទល់ឃុំប្រឡាយ។ ខ្សែទី២ ប្រវែង ៦១៤,៦២ម៉ែត្រ ជាផ្លូវជាតិលេខ៦ដែរចេញពីព្រំប្រទល់ឃុំទ្រា ឆ្ពោះដល់ព្រំប្រទល់ឃុំប្រឡាយ និងខ្សែទី៣ ប្រវែង ៦១១,៨២ម៉ែត្រ ចេញពីផ្លូវជាតិលេខ៦ទៅដល់បឋមសិក្សាត្នោត ព្រមទាំងមានផ្លូវជាច្រើនទៀត ដែលអាចតទំនាក់ទំនងពីភូមិមួយទៅភូមិមួយ ទៅឃុំផ្សេងៗ ស្រុក និងទីរួមខេត្តបានយ៉ាងស្រួល។ ឃុំកំពង់ចិនជើងមានចំនួន ៥៧ខ្សែ ប្រវែង ៦៧ ១៩០,២៩ម៉ែត្រ ក្នុងនោះផ្លូវក្រាលកៅស៊ូមាន ០៣ខ្សែ ប្រវែង ៨ ៨៧២,៨៤ម៉ែត្រ ផ្លូវចាក់បេតុងមាន ០៣ខ្សែ ប្រវែង ៨៨៨,៤៦ម៉ែត្រ ផ្លូវក្រាលគ្រួសក្រហម ១៥ខ្សែ ប្រវែង ១៩ ៨៣៦,៧១ម៉ែត្រ និងផ្លូវលំដីស ៣៦ខ្សែ ប្រវែង ៣៧ ៥៩២,២៨ម៉ែត្រ ។

តារាង 19៖ ប្រព័ន្ធផ្លូវដឹកជញ្ជូន

| ល.រ | ប្រភេទផ្លូវ | ចំនួនខ្សែផ្លូវ | ប្រវែង (ម៉ែត្រ) |
|---|---|---|---|
| ១ | ផ្លូវកៅស៊ូ | ៣ខ្សែ | ៨ ៨៧២,៨៤ |
| ២ | ផ្លូវបេតុង | ៣ខ្សែ | ៨៨៨,៤៦ |
| ៣ | ផ្លូវគ្រួសក្រហម ឬក្រាលថ្ម | ១៥ខ្សែ | ១៩ ៨៣៦,៧១ |
| ៤ | ផ្លូវដីស | ៣៦ខ្សែ | ៣៧ ៥៩២,២៨ |
| សរុប | | ៥៧ | ៦៧ ១៩០,២៩ |

រូបភាព 4៖ ប្រព័ន្ធគមនាគមន៍


ប្រភេទផ្លូវកៅស៊ូ


ប្រភេទផ្លូវគ្រួសក្រហម


ប្រភេទផ្លូវលំដីស

ផែនទី ៦៖ ផែនទីហេដ្ឋារចនាសម្ព័ន្ធឃុំកំពង់ចិនជើង



### ១.២.៨. បរិក្ខាសាធារណៈ

#### ក. ស្ថានភាពប្រើប្រាស់ថាមពលអគ្គិសនី

បេសកកម្មរបស់មន្ទីររ៉ែនិងថាមពលខេត្តកំពង់ធំគឺដឹកនាំជំរុញការគ្រប់គ្រង និងសមាហរណកម្មលើវិស័យរ៉ែនិងថាមពលរួមទាំងប្រេងកាត ឧស្ម័ន និងអគ្គិសនី នៅក្នុងសកម្មភាពអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅមូលដ្ឋាន និងក្នុងខេត្តកំពង់ធំ ក្នុងនាមជាសេនាធិការឱ្យក្រសួងរ៉ែ និងថាមពល ។

យោងទៅតាមទិន្នន័យមន្ទីរផែនការឆ្នាំ២០១៧បានបង្ហាញឱ្យឃើញថា នៅក្នុងឃុំកំពង់ចិនជើង ប្រជាពលរដ្ឋប្រើប្រាស់បណ្តាញអគ្គិសនីមានចំនួន ១ ៥៤៣ខ្នងផ្ទះ ស្មើនឹង ៩៥ភាគរយ ផ្ទះបំភ្លឺដោយអាគុយមានចំនួន ៨១ខ្នងផ្ទះ ស្មើនឹង ៤ភាគរយ ផ្ទះបន្ទះសូឡាមានចំនួន ១៦ខ្នងផ្ទះ ស្មើនឹង ១,០ភាគរយ ហើយផ្ទះមានទូរទស្សន៍ ប្រើប្រាស់មានចំនួន ១ ៥៤៣ខ្នងផ្ទះ ស្មើនឹង ៩៥ភាគរយ ។ ដូច្នេះប្រជាពលរដ្ឋប្រើប្រាស់បណ្តាញអគ្គិសនីមានចំនួនច្រើនជាងគេ និង ដោយបន្ទះសូឡាមានចំនួនតិចជាងគេ ។ សូមអាជ្ញាធរពាក់ព័ន្ធទាំងអស់ជួយជម្រុញឱ្យមាន បណ្តាញអគ្គិសនីទៅដល់លំនៅឋានរបស់ប្រជាពលរដ្ឋឱ្យបានគ្រប់គ្រាន់ ជាពិសេសនៅតំបន់ដាច់ស្រយ៉ាល ។

តារាង 20៖ ស្ថិតិអ្នកប្រើប្រាស់អគ្គិសនី

| បរិយាយ | ២០១៦ (%) | ២០១៧ | |
|---|---|---|---|
| | | ភាគរយ(%) | ចំនួនផ្ទះ |
| ផ្ទះបំភ្លឺដោយបណ្តាញអគ្គិសនី | ៩៦,០ | ៩៥ | ១ ៥៤៣ |
| ផ្ទះបំភ្លឺដោយអាគុយ | ៤៦,២ | ៤ | ៨១ |
| ផ្ទះបំភ្លឺដោយបន្ទះសូឡា | ១,៩ | ១ | ១៦ |
| ផ្ទះបំភ្លឺដោយឡជីវឧស្ម័ន | 0,0 | 0,0 | 0 |
| ផ្ទះមានទូរទស្សន៍ប្រើប្រាស់ | ៧២,២ | ៩៥ | ១ ៥៤៣ |

ប្រភពទិន្នន័យ៖ *CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់ចិនជើង ខែមិថុនា ឆ្នាំ២០១៨*

#### ខ. ប្រព័ន្ធទឹកស្អាត

អាជ្ញាធរខេត្តកំពង់ធំ បានអំពាវនាវឱ្យប្រជាពលរដ្ឋ ដែលធ្លាប់ប្រើប្រាស់ទឹក ស្ទឹង ត្រពាំង ឬអណ្តូងដៃងាកមកបរិភោគទឹកស្អាតវិញ ដើម្បីជួយលើកកម្ពស់សុខភាព និងលើកស្ទួយអនាម័យនៅតាមជនបទ ។ នៅក្នុងកំពង់ចិនជើងប្រជាពលរដ្ឋប្រើប្រាស់ទឹកស្អាតមានចំនួន ១ ១៨៣នាក់ ស្មើនឹង ៧៦,៥ភាគរយ ដែលនៅក្នុងនោះគ្រួសារមានទឹកឆ្លងកាត់ប្រព័ន្ធធ្វើទឹកឱ្យស្អាតមានចំនួន ៥៤៤គ្រួសារ គ្រួសារមានទឹកអណ្តូងស្នប់ឬអណ្តូងចម្រុះមានចំនួន ៤២៣នាក់ ទឹកអណ្តូងជីកមានការការពារមានចំនួន ២១០នាក់ ទឹកភ្លៀងដែលមានការការពារមាន ០៦គ្រួសារ ទឹកស្រះមាន ៤៨គ្រួសារ ទឹកអណ្តូងជីកមិនមានការការពារមាន ១១២នាក់ និងទឹកពីប្រភពផ្សេងៗ (ទន្លេ ស្ទឹង អូរ)មានចំនួន ២០៩គ្រួសារ ហើយក្នុងនោះទឹកដែលឆ្លងកាត់ប្រព័ន្ធធ្វើទឹកឱ្យស្អាតមានប្រជាពលរដ្ឋប្រើប្រាស់ច្រើនជាងគេ និងទឹកភ្លៀងដែលមានការការពារមានចំនួនតិចជាងគេ ។

តារាង 21៖ ស្ថិតិអ្នកប្រើប្រាស់ការប្រើប្រាស់ទឹក

| បរិយាយ | | ២០១៦ | ២០១៧ |
|---|---|---|---|
| សរុបគ្រួសារមានទឹកស្អាតប្រើប្រាស់ | | ១១២១ | ១១៨៣ |
| ក្នុងនោះ | ទឹកដែលឆ្លងកាត់ប្រព័ន្ធធ្វើទឹកឱ្យស្អាត | ៥៤៩ | ៥៤៤ |
| | ទឹកអណ្តូងស្នប់ឬអណ្តូងចម្រុះ | ៣៩៨ | ៤២៣ |
| | ទឹកអណ្តូងជីកមានការការពារ | ១៦៣ | ២១០ |
| | ទឹកភ្លៀងដែលមានការការពារ | ១១ | ៦ |
| %គ្រួសារមានទឹកស្អាតប្រើប្រាស់ | | ៧៦,០ | ៧៦,៥ |
| ទឹកអណ្តូងជីកមិនមានការការពារ | | ខ្វះ | ១១២ |
| %គ្រួសារប្រើប្រាស់ទឹកអណ្តូងជីកមិនមានការការពារ | | ៧,៦ | ៧,២ |
| ទឹកស្រះ | | ខ្វះ | ៤៨ |
| %គ្រួសាប្រើប្រាស់ទឹកស្រះ | | ២,២ | ២,៨ |
| ទឹកពីប្រភពផ្សេងៗ( ទន្លេ ស្ទឹង អូរ ជ្រោះ ) | | ខ្វះ | ២០៩ |
| %គ្រួសារប្រើប្រាស់ទឹកពីប្រភពផ្សេងៗ( ទន្លេ ស្ទឹង អូរ ជ្រោះ ) | | ១៤,២ | ១៣,៥ |

ប្រភពទិន្នន័យ៖ *CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ កំពង់ចិនជើង ខែមិថុនា ឆ្នាំ២០១៨*

## ១.៣. ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

### ១.៣.១. ស្ថានភាពការកាន់កាប់ និងគ្រប់គ្រងដី

ផែនទី 7៖ ផែនទីប្រើប្រាស់ដីសាមញ្ញឃុំកំពង់ចិនជើង



ផែនទី ៨៖ ផែនទីប្រើប្រាស់ដីលម្អិត ឃុំកំពង់ចិនជើង



តារាង 22៖ តារាងរាយលម្អិតតាមប្រភេទនៃការប្រើប្រាស់ដីបច្ចុប្បន្នឃុំកំពង់ចិនជើង

| ប្រភេទដីប្រើប្រាស់ | បរិយាយ | ផ្ទៃដីទំហំ(ហិកតា) | ភាគរយ(%) |
|---|---|---|---|
| **ក.ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ** | | **២៣៤,៦៣** | **៦,១០** |
| **ក.១. ដីលំនៅឋាន ភូមិ** | | **២៣៣,៩៣** | **៦,០៩** |
| -ដីលំនៅឋាន ភូមិក្រៅតំបន់ជុំវិញបឹងទន្លេសាប | ដីភូមិ | ៩៣,៩៣ | ២,៤៤ |
| -ដីលំនៅឋាន ភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ដីភូមិ | ១៤០ | ៣,៦៤ |
| **ក.២.កន្លែងកប់ខ្មោច** | កន្លែងកប់ខ្មោច | **០,៧** | **០,០២** |
| **ខ.ដីកសិកម្ម** | | **៣ ៣៩១,២** | **៨៧,១០** |
| **ខ.១.ដីស្រែវស្សា** | | **២ ៣២៩,៦** | **៦០,៦១** |
| -ដីស្រែវស្សាក្រៅតំបន់ជុំវិញបឹងទន្លេសាប | ស្រែវស្សា | ២១៩,៦ | ៥,៧១ |
| -ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ស្រែវស្សា | ១ ៩០០ | ៤៩,៤៣ |
| -ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ស្រែវស្សា | ២១០ | ៥,៤៦ |
| **ខ.២. ដីស្រែប្រាំងនិងស្រែវស្សា** | | **៩១៤,១៧** | **២៤,៤០** |
| -ដីស្រែប្រាំងនិង ស្រែវស្សាតំបន់១ជុំវិញបឹងទន្លេសាប | ស្រែប្រាំងនិងស្រែវស្សា | ៣០៤,១៧ | ៧,៩៣ |
| -ដីស្រែប្រាំងនិង ស្រែវស្សាតំបន់២ជុំវិញបឹងទន្លេសាប | ស្រែប្រាំងនិងស្រែវស្សា | ៦១០ | ១៥,៨៧ |
| **ខ.៣.ដីចម្ការ** | | **១៤៧,៩៩** | **៣,៨០** |
| -ដីចម្ការក្រៅតំបន់ជុំវិញបឹងទន្លេសាប | ចម្ការ | ២៧,៤ | ០,៧១ |
| -ដីចម្ការក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ចម្ការ | ១២០ | ៣,១២ |
| **គ.ដីព្រៃ/គម្របព្រៃ** | | **៨៧,២** | **២,២៧** |
| -ព្រៃគុម្ពោត និងឈើដុះរាយប៉ាយ | ព្រៃគុម្ពោត | ២៤,១៣ | ០,៦៣ |
| -ព្រៃតាមដងស្ទឹង | ព្រៃដុះតាមមាត់ស្ទឹង | ៦៣,០៧ | ១,៦៤ |
| **ឃ.ផ្ទៃទឹកនិងខ្សែទឹក** | | **១៨០,៣២** | **៤,៦៣** |
| -ស្ទឹងមានទឹកតាមរដូវ | ស្ទឹងស្ទោង | ១១៥,៧៥ | ២,៩៧ |
| -ស្រះ | ស្រះ | ១៤,៧៨ | ០,៣៨ |
| -អាងស្តុកទឹក | អាងស្តុកទឹក | ៤៩,៧៩ | ១,២៧ |
| **ផ្ទៃដីសរុបឃុំ** | | **៣ ៨៩៣,៣** | **១០០ %** |

### ក. ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ៖

### ក.១. ដីលំនៅឋានភូមិ ៖

ដីលំនៅឋាន ភូមិ គឺជាដីត្រូវបានប្រើប្រាស់សម្រាប់លំនៅឋានមានលាយសួនដំណាំ និងឈើហូបផ្លែនៅជុំវិញ ។ ដីលំនៅឋាន ភូមិនៅក្នុងឃុំកំពង់ចិនជើង មានទំហំផ្ទៃដីចំនួន ២៣៤,៦៣ហិកតា ភាគច្រើនស្ថិតនៅសងខាងតាមបណ្តោយផ្លូវជាតិលេខ៦ ក្នុងនោះមានមួយផ្នែកនៅខាងជើងផ្លូវជាតិលេខ៦ ជាដីលំនឋាន ភូមិក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប មាន ០២ភូមិ គឺភូមិត្រាច និងភូមិត្នោត មានផ្ទៃដីទំហំ ៩៣,៩៣ហិកតា ព្រមទាំងមួយផ្នែកនៅខាងត្បូងផ្លូវជាតិលេខ៦ ជាដីលំនៅឋានភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាប មានចំនួន ០៤ភូមិ គឺភូមិចេក ភូមិចក ភូមិរកា និងភូមិនាងសល្ងាច ដែលមានផ្ទៃដីទំហំ ១៤០ហិកតា ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីលំនៅឋាន ភូមិ ជាតំបន់ដីជម្រាលខ្ពស់មានប្រភេទ

ដីឥដ្ឋ (ពណ៌លឿនភ្លាវ) និងជាដីដែលកាន់កាប់ដោយប្រជាពលរដ្ឋ (កម្មសិទ្ធិឯកជន) ត្រូវបានធ្វើការចុះបញ្ជីជាលក្ខណៈប្រព័ន្ធបាន ៥០ភាគរយ ហើយ ។

រូបភាព 5៖ លំនៅឋានភូមិ

| | |
|---|---|
|  |  |
| ដីលំនៅឋានភូមិ | ដីលំនៅឋានទីប្រជុំជន |

### ក.២. ដីកប់ខ្មោច

ដីកប់ខ្មោច គឺជាដីសម្រាប់ប្រើប្រាស់សម្រាប់ការបញ្ចុះសពតែមួយមុខគត់ ហើយត្រូវបានគេរៀបចំកន្លែងមួយច្បាស់លាស់សម្រាប់ទីបញ្ចុះសព ស្ថិតនៅតាមបណ្តោយផ្លូវគ្រួសក្រហមកាត់កណ្តាលឃុំ ដែលមានផ្ទៃដីទំហំ ០,៧០ហិកតា ។ ដីនេះត្រូវបានគេធ្វើការបញ្ចុះសពតាមប្រពៃណីចិន ជាដីទំនាបមិនលិចទឹកទេ ត្រូវបានគេចាក់ដីពីលើដីទួលចាស់បន្ថែមទៀត ដើម្បីកុំឱ្យលិចទឹកពេលរដូវវស្សា។ ដីកប់ខ្មោចនេះ ជាដីកម្មសិទ្ធិរបស់សហគមន៍ និងត្រូវបានគ្រប់គ្រងដោយអាជ្ញាធរភូមិឃុំ ។

រូបភាព 6៖ កន្លែងកប់ខ្មោច

| | |
|---|---|
|  |  |
| ដីកប់ខ្មោចមានទំហំធំ | ដីកប់ខ្មោចមានទំហំតូច |

## ខ. ដីកសិកម្ម៖

### ខ.១. ដីស្រែវស្សា៖

នៅក្នុងឃុំកំពង់ចិនជើង ដីស្រែវស្សាមានផ្ទៃដីសរុបទំហំ ២ ៣២៩,៦ ហិកតា ក្នុងនោះមានមួយផ្នែកនៅខាងជើងផ្លូវជាតិលេខ៦ ជាដីស្រែវស្សាស្ថិតនៅក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប ទំហំផ្ទៃដី ២១៩,៦ ហិកតា និងមួយផ្នែកទៀត នៅខាងត្បូងផ្លូវជាតិលេខ៦ ជាដីស្រែវស្សាស្ថិតនៅក្នុងតំបន់១ជុំវិញបឹងទន្លេសាប មានផ្ទៃដីទំហំ ១ ៩០០ហិកតា ព្រមទាំងមួយផ្នែកបន្តពីដីស្រែវស្សាក្នុងតំបន់១ទៅភាគខាងត្បូងនៃឃុំ ជាដីស្រែវស្សាតំបន់២ជុំវិញបឹងទន្លេសាប មានផ្ទៃដីទំហំ ២១០ ហិកតា ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំកំពង់ចិនជើងនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែវស្សាទាំងអស់ មានដីជាតិល្អបង្គួរជាប្រភេទដីឥដ្ឋ (ពណ៌លឿនភ្លាវ) និងល្បាយខ្សាច់(ពណ៌ក្រហមភ្លាវ) និងជាដីកម្មសិទ្ធិឯកជន ដែលបានកាន់កាប់ដោយប្រជាពលរដ្ឋ លើកលែងតែដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប គឺជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋមានសិទ្ធិត្រឹមតែអាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ ហើយត្រូវបានកំពុងដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធនៅក្នុងឃុំទាំងមូលបាន ៥០ភាគរយ ហើយ ។ ដីស្រែវស្សាទាំងនេះ មានមួយផ្នែកនៅក្បែរៗជាប់នឹងដីលំនៅឋាន ភូមិ ក្រោយពីច្រូតកាត់ស្រូវរួច ប្រជាពលរដ្ឋនៅក្នុងឃុំតែងនាំគ្នាដាំដំណាំរួមផ្សំថែមទៀតរួមមានដូចជា ពោត សណ្តែក ឪឡឹក និងបន្លែគ្រប់មុខជាដើម។ល។ ហើយដីទាំងនេះមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង អាងស្តុកទឹក៣០កញ្ញា ដែលមានទំនប់បង្វៀរស្ទាក់ទឹកស្ទឹងស្ទោងនៅក្នុងស្រុកស្ទោង ដែលនាំទឹកពីភាគខាងជើងមកស្រោចស្រពតាមរយៈប្រឡាយមេមួយខ្សែ គឺប្រឡាយ៣០កញ្ញា ព្រមទាំងមានអាងស្តុកទឹក និងបឹងធម្មជាតិមួយនៅភាគខាងត្បូងនៃឃុំ ។

**-ដីស្រែវស្សាក្រៅតំបន់ជុំវិញបឹងទន្លេសាប**

ដីស្រែវស្សាក្រៅតំបន់ជុំវិញបឹងទន្លេសាប ស្ថិតនៅភាគខាងជើងនៃឃុំ មានផ្ទៃដីទំហំ ២១៩,៦ហិកតា ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំកំពង់ចិនជើងនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន មានដីជាតិល្អបង្គួរជាប្រភេទដីឥដ្ឋ (ពណ៌លឿនភ្លាវ) និងល្បាយខ្សាច់(ពណ៌ក្រហមភ្លាវ) ដីស្រែវស្សាស្ថិតនៅក្រៅតំបន់ជុំវិញបឹងទន្លេសាប គឺជាដីកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋ ។ ដីស្រែវស្សានេះពឹងផ្អែកប្រភពទឹកស្រោចស្រពពីទឹកភ្លៀង ស្រះទឹក ប្រឡាយ៣០កញ្ញា និងស្ទឹងស្ទោង ។

**-ដីស្រែវស្សាក្នុងតំបន់១ ជុំវិញបឹងទន្លេសាប**

ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាបស្ថិតនៅភាគខាងត្បូងនៃឃុំ មានផ្ទៃដីទំហំ ១ ៩០០ហិកតា ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំកំពង់ចិនជើងនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន មានដីជាតិល្អបង្គួរជាប្រភេទដីឥដ្ឋ (ពណ៌លឿនភ្លាវ) និងល្បាយខ្សាច់ (ពណ៌ក្រហមភ្លាវ) ដីស្រែវស្សាស្ថិតនៅក្រៅតំបន់ជុំវិញបឹងទន្លេសាប ជាដីកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ ។ ដីស្រែវស្សានេះ ពឹងផ្អែកប្រភពទឹកស្រោចស្រពពីទឹកភ្លៀង ស្រះទឹក ប្រឡាយ៣០កញ្ញា និងស្ទឹងស្ទោង ។

**-ដីស្រែវស្សាក្នុងតំបន់២ ជុំវិញបឹងទន្លេសាប**

ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប ស្ថិតនៅភាគខាងត្បូងនៃឃុំ មានផ្ទៃដីទំហំ២១០ហិកតា ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំបចំណារក្រោមនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថានមានដីជាតិល្អបង្គួរជាប្រភេទដីឥដ្ឋ (ពណ៌លឿនភ្លាវ) និងល្បាយខ្សាច់ (ពណ៌ក្រហមភ្លាវ) ដីស្រែវស្សាស្ថិតនៅក្រៅតំបន់ជុំវិញបឹងទន្លេសាប គឺជាដីសាធារណៈរបស់រដ្ឋ ដោយប្រជាពលរដ្ឋមានសិទ្ធិត្រឹមអាស្រ័យផលតែប៉ុណ្ណោះ ដោយមិនមាន

សិទ្ធិក្នុងការចាត់ចែងនោះឡើយ ។ ដីស្រែវស្សានេះពឹងផ្អែកប្រភពទឹកស្រោចស្រពពីទឹកភ្លៀង ស្រះទឹក ប្រឡាយ ៣០កញ្ញា និងស្ទឹងស្ទោង។

រូបភាព 7៖ ដីស្រែវស្សា

| | |
|---|---|
|  |  |
| ដីស្រែវស្សាក្រៅតំបន់ | ដីស្រែវស្សាក្នុងតំបន់១ |

### ខ.២. ដីស្រែប្រាំង និងស្រែវស្សា៖

**-ដីស្រែប្រាំងនិង ស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

នៅក្នុងឃុំកំពង់ចិនជើង ដីស្រែប្រាំង និងស្រែវស្សា ដែលនៅខាងត្បូងផ្លូវជាតិលេខ៦ ជាដីស្រែស្ថិតនៅក្នុងតំបន់១ជុំវិញបឹងទន្លេសាបមានផ្ទៃដីទំហំ ៣០៤,១៧ ហិកតា ។បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំកំពង់ចិនជើងនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែវស្សាទាំងអស់ មានជីជាតិល្អបង្គួរជាប្រភេទដីឥដ្ឋ (ពណ៌លឿនភ្លាវ) និង ល្បាយខ្សាច់ (ពណ៌ក្រហមភ្លាវ)គឺជាដីកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋ ហើយត្រូវបានកំពុងដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធនៅក្នុងឃុំទាំងមូលបាន៥០ភាគរយហើយ ។ ដីស្រែប្រាំង និងវស្សានេះ ពឹងផ្អែកពីប្រភពទឹកភ្លៀង អាងស្តុកទឹក៣០កញ្ញា ដែលមានទំនប់បង្ហៀរស្នាក់ទឹកស្ទឹងស្ទោងនៅក្នុងស្រុកស្ទោងដែលនាំទឹកពីភាគខាងជើងមកស្រោចស្រពតាមរយៈប្រឡាយមេមួយខ្សែគឺប្រឡាយ៣០កញ្ញា ព្រមទាំងអាងស្តុកទឹកមួយចំនួន បឹងធម្មជាតិនៅភាគខាងត្បូងនៃឃុំ និងស្រះទឹកមួយចំនួន ។

**-ដីស្រែប្រាំងនិង ស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

នៅក្នុងឃុំកំពង់ចិនជើង ដីស្រែប្រាំង និងស្រែវស្សាមានពីរតំបន់ជុំវិញបឹងទន្លេសាប ដែលនៅខាងត្បូងផ្លូវជាតិលេខ៦បន្តពីដីតំបន់១ជុំវិញបឹងទន្លេសាប ជាដីស្រែស្ថិតនៅក្នុងតំបន់១ជុំវិញបឹងទន្លេសាប មានផ្ទៃដីទំហំ ៦១០ហិកតា ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំកំពង់ចិនជើងនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែវស្សាទាំងអស់ មានជីជាតិល្អបង្គួរជាប្រភេទដីឥដ្ឋ(ពណ៌លឿនភ្លាវ) និងល្បាយខ្សាច់(ពណ៌ក្រហមភ្លាវ)គឺជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋមានសិទ្ធិត្រឹមតែអាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ ហើយត្រូវបានកំពុងដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធ ក្នុងឃុំទាំងមូលបាន ៥០ភាគរយហើយ ។ ដីស្រែប្រាំង និងវស្សានេះ ពឹងផ្អែកពីប្រភពទឹកភ្លៀង អាងស្តុកទឹក៣០កញ្ញា ដែលមានទំនប់បង្ហៀរស្នាក់ទឹកស្ទឹងស្ទោង នៅក្នុងស្រុកស្ទោង ដែលនាំទឹកពីភាគខាងជើងមកស្រោចស្រពតាមរយៈប្រឡាយមេមួយខ្សែ គឺប្រឡាយ៣០កញ្ញា ព្រមទាំងអាងស្តុកទឹកមួយចំនួន បឹងធម្មជាតិនៅភាគខាងត្បូងនៃឃុំនិងស្រះទឹកមួយចំនួន ។

រូបភាព ៨៖ ដីស្រែប្រាំង និងស្រែវស្សា

|  |  |
|---|---|
| ដីស្រែប្រាំងនិងវស្សាក្នុងតំបន់១ | ដីស្រែប្រាំងនិងវស្សាក្នុងតំបន់២ |

### ៦.៣ ដីចម្ការ

**-ដីចម្ការនៅក្រៅតំបន់ជុំវិញបឹងទន្លេសាប**

ដីចម្ការនៅក្នុងឃុំកំពង់ចិនជើង មានផ្ទៃដីទំហំ ២៧,៤ ហិកតា ស្ថិតនៅខាងជើងផ្លូវជាតិលេខ៦ បច្ចុប្បន្ននេះបាននិងកំពុងប្រើប្រាស់ជាដីចម្ការ ហើយភាគច្រើនជាដំណាំស្វាយចន្ទី និងដំឡូងមី ។ ដីចម្ការនេះគេបានដាំនៅក្បែរប្រភពទឹកក្បែរស្ទឹងគោល នៅភាគខាងជើងឆៀងខាងលិច ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំកំពង់ចិនជើង នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីចម្ការនេះ មានដី ជាតិល្បបង្គួរជាប្រភេទដីឥដ្ឋ(ពណ៌លឿនភ្លាវ) ដីចម្ការនេះ គឺជាដីកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋ ដោយពឹងផ្អែកប្រភពទឹកភ្លៀង ស្រះទឹក និងទឹកស្ទឹងស្ទោង ។

**-ដីចម្ការក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

ដីចម្ការនៅក្នុងឃុំកំពង់ចិនជើង មានផ្ទៃដីទំហំ ១២០ហិកតា នៅភាគខាងជើងឆៀងខាងលិចនៃឃុំ បានដាំដុះដំណាំនៅតាមបណ្តោយដងស្ទឹងគោលពីជើងមកត្បូង ដែលរួមមានដំណាំដូចជា ឪឡឹក ត្រសក់ស្រូវ និងដំឡូងជាដើម រួមទាំងមានដាំដំណាំស្វាយចន្ទី និងដំឡូងមីតិចតួច ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំកំពង់ចិនជើង នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីចម្ការនេះ មានដីជាតិល្បបង្គួរជាប្រភេទដីឥដ្ឋ (ពណ៌លឿនភ្លាវ) ជាដីកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋ ដោយពឹងផ្អែកប្រភពទឹកភ្លៀង ស្រះទឹក និងទឹកស្ទឹងស្ទោង ។

រូបភាព ៩៖ ដីចម្ការ

|  |  |
|---|---|
| ដីចម្ការក្នុងតំបន់១ | ដីចម្ការក្រៅតំបន់ |

គ. ដីព្រៃ/គម្របព្រៃ៖

**-ព្រៃគុម្ពោត និងឈើដុះរាយប៉ាយ**

ព្រៃគុម្ពោត និងឈើដុះរាយប៉ាយនៅក្នុងឃុំកំពង់ចិនជើង ស្ថិតនៅភាគខាងលិចនៃឃុំ នៅក្បែរស្ទឹងនាងសល្វាច ដែលមានផ្ទៃដីទំហំ ២៤,១៣ហិកតា សម្បូរទៅដោយ ដើមឈើខ្លុង ត្បែង កកោះ និងតាសេក ជាដើម។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំកំពង់ចិនជើងនៃរបាយការណ៍វិភាគប្រព័ន្ធកេ្សត្រ-បរិស្ថាន ព្រៃគុម្ពោត និងឈើដុះរាយប៉ាយនេះមានដីជាតិល្អបង្គួរជាប្រភេទដីឥដ្ឋ(ពណ៌លឿនភ្លាវ) ជាដីកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ ដោយពឹងផ្អែកប្រភពទឹកភ្លៀង និងទឹកស្ទឹងនាសល្វាច ។

រូបភាព 10៖ ព្រៃគុម្ពោត



**-ព្រៃតាមដងស្ទឹង៖**

នៅក្នុងឃុំកំពង់ចិនជើង ព្រៃតាមដងស្ទឹង មានចំនួនពីរកន្លែង ផ្ទៃដីសរុបទំហំ ៦៣,០៧ហិកតា ស្ថិតនៅតាមដងស្ទឹងស្ទោងនិងស្ទឹងនាងសល្វាច នៅក្នុងនោះព្រៃតាមដងស្ទឹងស្ទោងមានផ្ទៃដីទំហំ ៤,១៩ហិកតា ស្ថិតនៅភាគខាងកើតនៃឃុំ និងជាព្រំប្រទល់ជាមួយឃុំកំពង់ចិនត្បូងផង និងឃុំទ្រាផង និងព្រៃតាមដងស្ទឹងនាងសល្វាច មានផ្ទៃដីទំហំ ៥៨,៨៨ហិកតា ស្ថិតនៅភាគខាងលិចនៃឃុំ ជាប់ព្រំប្រទល់ជាមួយឃុំប្រឡាយ ។ព្រៃទាំងនេះមានសម្បូរទៅដោយដើមឈើចម្រុះដុះលាយឡំគ្នាដូចជា៖ ដើមភ្នំភ្លើង ត្រស់ កប្បាសព្រៃ ស្វាច់ ដើមរាំងជាដើម ព្រៃតាមដងស្ទឹងនេះ គឺជាកម្មសិទ្ធិសាធារណៈរបស់រដ្ឋ ។

រូបភាព 11៖ ព្រៃតាមដងស្ទឹង



ឃ. ផ្ទៃទឹក និងខ្សែទឹកៈ

**-ស្ទឹងមានទឹកតាមរដូវ**

នៅក្នុងឃុំកំពង់ចិនជើង មានស្ទឹងចំនួនពីរ គឺស្ទឹងស្ទោង និងស្ទឹងនាងសល្វាច ដែលមានផ្ទៃដីសរុបទំហំ ១១៥,៧៥ហិកតា ក្នុងនោះស្ទឹងស្ទោង មានផ្ទៃដីទំហំ ៨០,៧៦ ហិកតា ស្ថិតនៅភាគខាងកើតនៃឃុំជាប់ជាមួយព្រំប្រទល់ឃុំកំពង់ចិនត្បូង និងស្ទឹងនាងសល្វាច មានផ្ទៃដីទំហំ ២៥,៦៤ហិកតា ស្ថិតនៅភាគខាងលិចនៃឃុំជាប់ជាមួយព្រំប្រទល់ឃុំប្រឡាយ។ ស្ទឹងទាំងនេះអាចផ្គត់ផ្គង់ទឹកបានតែរដូវវស្សាទេ ដោយឡែកនៅរដូវប្រាំងវិញស្ទឹងទាំងនេះបានស្រកអស់ ដោយសារតែប្រភពទឹកនៅផ្នែកខាងលើមិនអាចហូរមកផ្គត់ផ្គង់បាន។ ស្ទឹងនេះ ក្រៅពីការស្រោចស្រព ក៏ជាប្រភពធនធានជលផលនិងការប្រើប្រាស់ផ្សេងៗទៀតរបស់ប្រជាពលរដ្ឋនៅក្នុងឃុំផងដែរ។

រូបភាព 12៖ ស្ទឹងមានទឹកតាមរដូវ



**-ស្រះទឹកៈ**

នៅក្នុងឃុំកំពង់ចិនជើង មានស្រះទឹកជាច្រើនកន្លែង ដែលជីកនៅតាមវាលស្រែក្រៅតំបន់ជុំវិញបឹងទន្លេសាបនិងក្នុងតំបន់១ជុំវិញទន្លេសាប ដីសរុប ១៤,៧៨ហិកតា ក្នុងនោះមាន ស្រះទឹកក្រៅតំបន់ជុំវិញបឹងទន្លេសាប មានផ្ទៃដីទំហំ ០,៧២ហិកតា ស្ថិតនៅខាងជើងផ្លូវជាតិលេខ៦ និងស្រះ នៅក្នុងតំបន់១ជុំវិញបឹងទន្លេសាប មានផ្ទៃដី ១៤,៦ ហិកតា ស្ថិតនៅត្បូងផ្លូវជាតិលេខ៦ ស្រះទាំងអស់នេះ ជាដីឯកជន ដែលកាន់កាប់ និងប្រើប្រាស់ដោយប្រជាពលរដ្ឋ ។ បច្ចុប្បន្នស្រះទាំងនេះ ត្រូវបានប្រើប្រាស់សម្រាប់ជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់ផ្សេងៗទៀតតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង ។

រូបភាព 13៖ ស្រះទឹក





**-អាងស្តុកទឹកៈ**

នៅក្នុងឃុំកំពង់ចិនជើង មានអាងស្តុកទឹកជាច្រើនកន្លែងនៅភាគច្រើននៅកណ្តាលស្រែប្រាំង ដែល មានផ្ទៃដីទំហំ៤៩,៧៩ហិកតា ស្ថិតក្នុងដីតំបន់១ និងតំបន់២ជុំវិញបឹងទន្លេសាបក្នុងនោះអាងស្តុកទឹកតំបន់១ជុំវិញបឹងទន្លេសាបមានទំហំផ្ទៃដី ០,១៧ហិកតា និងអាងស្តុកទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានផ្ទៃដី ៤៩,៦ហិកតា។ អាងស្តុកទឹកដែលស្ថិតក្នុងតំបន់២ជុំវិញបឹងទន្លេសាប គឺជាដីសាធារណៈរដ្ឋ ដែលប្រជាពលរដ្ឋមានមានសិទ្ធិត្រឹមតែកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិក្នុងការចាត់ចែងឡើយ ហើយបច្ចុប្បន្នត្រូវបានប្រើប្រាស់សម្រាប់ការស្រោចស្រព និងប្រើប្រាស់ផ្សេងៗទៀតតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆជាតិទៀតផង ដែលអាចប្រើប្រាស់បានពេញមួយឆ្នាំ។

រូបភាព 14៖ អាងស្តុកទឹក

|  |  |
|---|---|
| អាងស្តុកទឹកខែវស្សា | អាងស្តុកទឹកខែប្រាំង |

ពាក់ព័ន្ធបញ្ហាផ្សេងៗក្នុងការប្រើប្រាស់ដីនៅក្នុងឃុំកំពង់ចិនជើង តាមរយៈការសម្ភាសន៍ជាមួយក្រុមប្រឹក្សាឃុំបានឱ្យដឹងថាមានប្រជាពលរដ្ឋចំនួន ៦៧គ្រួសារ ដែលមិនមានដីសម្រាប់សាងសង់លំនៅឋាន និង២៤៦គ្រួសារទៀតមិនមានដីធ្វើកសិកម្ម ។ ក្នុងចំណោមប្រជាពលរដ្ឋទាំងនេះ មានមួយចំនួនរស់នៅលើដីចិញ្ចើមផ្លូវ រស់នៅលើដីកម្មសិទ្ធិរបស់គេផ្សេង ព្រមទាំងមួយចំនួនទៀត ពួកគាត់រស់នៅជាមួយឪពុកម្តាយ។ ចំណែកបញ្ហាទំនាស់នៅក្នុងការប្រើប្រាស់ដីនៅក្នុងឃុំកំពង់ចិនជើងវិញ ពុំមានចេញជារូបភាពធំដុំគួរឱ្យកត់សម្គាល់ឡើយ ដោយសារដីក្នុងឃុំទាំងមូល កំពុងដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធបាន ៥០ភាគរយហើយ ។

## ១.៣.២. ផលិតកម្មកសិកម្ម

### ក. ផលិតកម្មដំណាំស្បៀង

ផលិតកម្មដំណាំស្បៀងនៅក្នុងឃុំកំពង់ចិនជើងបានផ្តោតសំខាន់ទៅលើផលិតកម្មដំណាំស្រូវហើយដំណាំនេះបានដើរតួយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍន៍ឃុំដោយសារផលិតផលស្រូវ។ ក្រៅពីទុកផ្គត់ផ្គង់សម្រាប់ការហូបចុក ហើយប្រជាពលរដ្ឋបានលក់ស្រូវ ដែលសល់សម្រាប់បំពេញតម្រូវការចាយវាយចាំបាច់ក្នុងជីវភាពរស់នៅផងដែរ។ នៅក្នុងឃុំកំពង់ចិនជើងមានផ្ទៃដីស្រែសរុបទំហំ ៣ ២៤៣,៧៧ ហិកតា ដែលនៅក្នុងនោះផ្ទៃដីស្រែប្រាំង និងវស្សាមានទំហំដី ៩១៣,៨៣ហិកតា ដីស្រែវស្សាមានផ្ទៃដី ២ ៣២៩,៦ហិកតា និងដីស្រែប្រាំងមានផ្ទៃដី ០,៣៤ហិកតា ជាដីប្រភេទដីឥដ្ឋ(ពណ៌លឿនភ្លាវ)ដីជាតិល្អបង្គួរល្បាយខ្សាច់(ក្រហមភ្លាវ)និងជាប្រភេទដីកណ្តោង ល្បាប់លិចទឹកភ្លៀង(ពណ៌ទង់ដែង)។ប្រជាពលរដ្ឋនៅក្នុងឃុំនេះនិយមដាំដុះដំណាំស្រូវដូចជាៈ ស្រូវកណ្តាល ពូជ រំដួល ម្លិះ ម្លិះ

ថៃ ស្រូវកណ្តាលពូជ ម្លិះ ម្លិះថៃ ពូជ៨៥ និងពូជស្រូវ៥០៤ ស្រូវប្រាំងពូជ៥០៤។ ប្រភពទឹកស្រោចស្រពនៅក្នុងឃុំកំពង់ចិនជើងមានមានប្រភពពី ស្ទឹងស្ទោង ស្រះ និងអណ្តូង(លូ ស្នប់) ប្រឡាយចាស់ ទឹកជំនន់ទន្លេសាបពីស្ទឹងសល្វាច អាងស្តុកទឹកឯកជន (ចាន់ សីហា) អាងស្តុកទឹកឯកជន (អាន) អាងស្តុកទឹកឯកជន(សុង)អាងស្តុកទឹកឯកជន (សាយគឹមឡុម) និងអាងស្តុកទឹកឯកជន(គកវិត)។ ជាទូទៅនៅក្នុងឃុំកំពង់ចិនជើងទទួលបានទិន្នផលស្រូវវស្សាជាមធ្យម ២,៥តោន/ហិកតា និងស្រូវប្រាំងជាមធ្យម ៤,៥តោន/ហិកតា ហើយនៅឆ្នាំ២០១៧ ឃុំកំពង់ចិនជើងទទួលបានទិន្នផលស្រូវសរុបចំនួន ៨ ៨៣៤,៥ តោន ដែលនៅក្នុងនោះទិន្នផលស្រូវវស្សាចំនួន ៥៨២៤តោន ចំណែកស្រូវប្រាំងវិញមានចំនួន ៣០១០,៥តោន ។ ប្រជាពលរដ្ឋបានទុកស្រូវសម្រាប់បរិភោគចំនួន ២៥ភាគរយ ក្នុងចំណោមស្រូវដែលរក្សាទុក ៣០ភាគរយ ស្មើនឹង ៦៦២,៥៩តោន និងទុកពូជ ០៥ភាគរយ ស្មើនឹង ១៣២,៥២តោន និងលក់ចេញ ៧០ភាគរយ នៃស្រូវសរុបទទួលបាន ស្មើនឹង ៦១៨៤,១៥តោន បានធ្វើការលក់ចេញក្នុងតម្លៃជាមធ្យម ១ ០០០រៀល/គ.ក្រ ដែលទទួលបានចំណូលសរុបប្រមាណ ៦ ១៨៤ ១៥០ រៀល ។

តារាង 23៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាសលើដំណាំស្ម្យៀង

| ឧបសគ្គ | ឱកាស |
|---|---|
| - ការដាំដុះដំណាំកសិកម្មទទួលបានផលល្អតែមានតម្លៃទាប<br>- ការប្រែប្រួលអាកាសធាតុ(រាំងស្ងួត ឬ ទឹកជំនន់)<br>- តម្លៃស្រូវមិនទៀងទាត់<br>- សម្ភារៈ និងឧបករណ៍កសិកម្មមានតម្លៃខ្ពស់<br>- ការស្រាវជ្រាវផ្នែកកសិកម្មនៅមានកម្រិត<br>- គ្មានសមាគមន៍ផ្នែកអភិវឌ្ឍកសិកម្ម<br>- ទីផ្សារស្រូវផ្នែកខ្លាំងលើពូជស្រូវ នាំចូល ពីប្រទេសជិតខាង<br>- ខ្វះប្រព័ន្ធស្រោចស្រព និងប្រភពទឹក ប្រើប្រាស់<br>- ការផ្សព្វផ្សាយពូជស្រូវ១០មុខនៅមានកម្រិត<br>- មានឈ្មួញ ឬ អាជីវករ យកជីគីមីទៅលក់បណ្តាក់តាមមូលដ្ឋានដោយគ្មានច្បាប់អនុញ្ញាត<br>- ជីគីមីនិងថ្នាំពុលខ្លះមិនទាន់បកប្រែជាភាសាខ្មែរ<br>- ខ្វះមន្ត្រីផ្សព្វផ្សាយនៅតាមឃុំ | - នឹងមានប្រភពទឹកស្រោចស្រព<br>- ទិន្នផលបានខ្ពស់ និងមានតម្លៃថ្លៃជាងមុន<br>- នឹងមានការជីក ស្តារត្រពាំង ប្រឡាយទឹក ប្រើប្រាស់ម៉ាស៊ីនបូមទឹកជាជំនួយ<br>- ធ្វើការជម្រុញឱ្យកសិករលើកប្រព័ន្ធភ្លឺស្រែ<br>- បិទទំនប់ស្ទាក់ទឹកតាមដងអូរ ឬ ស្នាមភ្លោះ<br>- ផ្តល់ជូនពូជស្រូវដែលមានទិន្នផលខ្ពស់ និងតម្លៃនៅលើទីផ្សារ<br>- ប្រជាពលរដ្ឋប្រើប្រាស់សម្ភារៈ ទំនើប និងមានតម្លៃថោកជាងមុន |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់ចិនជើង ខែមិថុនា ឆ្នាំ២០១៨*

### ខ. ផលិតកម្មដំណាំរួមផ្សំ

ផលិតកម្មដំណាំរួមផ្សំនៅក្នុងឃុំកំពង់ចិនជើងមានដូចជា៖ ស្ពៃ ត្រកួន ត្រសក់ សណ្តែក នននោង ល្ពៅ ឪឡឹក ដំឡូង សណ្តែកកួរ និងដំណាំពោត ដែលភាគច្រើនប្រជាពលរដ្ឋធ្វើការដាំដុះលក្ខណៈគ្រួសារនៅជុំវិញដីលំនៅឋាននិងជុំវិញត្រពាំងបឹងបួ និងកន្លែងដែលមានប្រភពទឹក ជាប្រភេទដីកណ្តោងតដ្ឋ(ពណ៌លឿងភ្លាវ)តែមិនមានទិន្នន័យពីទំហំផ្ទៃដីនោះទេ ដែលទទួលបានការស្រោចស្រពពីស្ទឹងស្ទោង ស្ទឹងនាងសល្វាចស្រះ អណ្តូង(លូ ស្នប់) និងទឹកភ្លៀងហើយពួកគាត់ធ្វើការដាំដុះដើម្បីផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ និងលក់ដូរបន្តិចបន្តួច។ ទិន្នផលដែលទទួលបានអាស្រ័យទៅលើការថែទាំ ហើយសម្រាប់ការដាំដំណាំនេះដែរ ប្រជាពលរដ្ឋក៏ជួបនឹងបញ្ហាមួយចំនួនដូចជា៖ សត្វល្អិត ជម្ងឺ និងមិនទាន់មានបច្ចេកទេសគ្រប់គ្រាន់ក្នុងការដាំដុះដំណាំទាំងនោះទេ ។

តារាង 24៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| - ការដាំដុះដំណាំកសិកម្មទទួលបានផលល្អតែមានតម្លៃទាប<br>- ការប្រែប្រួលអាកាសធាតុ(រាំងស្ងួត ឬ ទឹកជំនន់)<br>- ខ្វះប្រភពទឹកស្រោចស្រពដំណាំ<br>- តម្លៃកសិផលមិនទៀងទាត់<br>- ប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិត<br>- មិនទាន់មានបច្ចេកគ្រប់គ្រាន់<br>- ខ្វះទីផ្សារលក់ផលិតផល | - នឹងមានប្រភពស្រោចស្រពគ្រប់គ្រាន់<br>- តម្លៃកសិផលនឹងកើនឡើងជាងមុន<br>- កាត់បន្ថយការប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិតដោយងាកមកប្រើជីធម្មជាតិ និងថ្នាំធម្មជាតិ<br>- ការយល់ដឹងពីបច្ចេកទេសប្រសើរជាងមុន<br>- មានទីផ្សារសម្រាប់ទិញផលិតផល |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់ចិនជើង ខែមិថុនា ឆ្នាំ២០១៨*

### គ. ផលិតកម្មឧស្សាហកម្ម

នៅឃុំកំពង់ចិនជើង ប្រជាពលរដ្ឋធ្វើការដាំដុះដំណាំឧស្សាហកម្មដែលមានទំហំ ១៤៧,៩៩ហិកតា មានដាំនៅភាគខាងជើងឆៀងខាងលិចជាប់ព្រំប្រទល់ជាមួយឃុំប្រឡាយ ហើយនៅតំបន់នោះជាប្រភេទដីកណ្តៀងតដ្ឋ (ពណ៌លឿងភ្លាវ)ហើយប្រភេទដំណាំដែលប្រជាពលរដ្ឋធ្វើការដាំដុះនោះមានប្រភេទដំណាំស្វាយស្វាយចន្ទី និងដំឡូងមី ដែលទទួលបានការស្រោចស្រពពីស្ទឹងស្ទោង ស្រះ អណ្តូង (លូស្នប់) និងទឹកភ្លៀង ។ ឃុំកំពង់ចិនជើងបើយោងទៅតាមព័ត៌មានស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចឆ្នាំ២០១៧របស់ឃុំ សម្រាប់ផលិតផលដំណាំស្វាយចន្ទីស្វាយ និងដំឡូងមីទាំងនេះ មិនមានទិន្នន័យជាទិន្នផលសម្រាប់ផលិតផលនោះទេ ។

តារាង 25៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| -ខ្វះទឹកស្រោចស្រព<br>-បញ្ហាជួបគ្រោះរាំងស្ងួត<br>-បញ្ហាជួបទឹកជំនន់(ទឹកភ្លៀង)<br>-បញ្ហាសត្វល្អិតបំផ្លាញ<br>-បញ្ហាតម្លៃនៅទីផ្សារមាន ការប្រែប្រួល<br>-បញ្ហាជម្ងឺលើដំណាំ<br>-បញ្ហាដីខ្វះជីវជាតិ<br>-បញ្ហាខ្វះបច្ចេកទេសកសិកម្ម | -ពង្រីកប្រព័ន្ធស្រោចស្រព<br>-ពង្រីកផ្ទៃដីដាំដុះលើដំណាំ ស្វាយ ចន្ទីរ ដំណាំដំឡូងមី<br>-បើវគ្គបណ្តុះបណ្តាលលើដំណាំ ឈើហូបផ្លែ<br>-បើវគ្គបណ្តុះបណ្តាលលើដំណាំ បន្លែ<br>-បើកវគ្គបណ្តុះបណ្តាលលើដំណាំ<br>-បោកវគ្គបណ្តុះបណ្តាលការ ប្រើប្រាស់ថ្នាំកសិកម្មសមស្រប |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ប្រឡាយ ខែមិថុនា ឆ្នាំ២០១៨*

### ១.៣.៣. ធនធានធម្មជាតិ

#### ក. ធនធានព្រៃឈើ

បច្ចុប្បន្ននៅក្នុងឃុំ មានព្រៃគុម្ពោតនិងឈើដុះរាយប៉ាយចំនួន ២៤,១៣ហិកតា និងព្រៃតាមដងស្ទឹងមានចំនួន៦៣,០៧ហិកតា ដែលមានប្រភេទឈើមួយចំនួនដូចជា៖ ខ្លុង ត្បែង ផ្ចិក កកោះ ដង្កៀបក្តាម លៀង ត្រសេក រកា កណ្តោល ច្រេស កន្ទួតព្រៃ ស្វាយព្រៃ។ល។ នៅក្នុងឃុំនេះក៏មានប្រភេទសត្វព្រៃមួយចំនួនដូចជាពស់ អណ្តើក ប្រវឹក កណ្តុរជាដើម។ល។ ដោយប្ចុប្បន្នមានការកាប់បំផ្លាញព្រៃឈើទាំងនេះសម្រាប់ការកាប់រានដីថ្មីយកមកធ្វើស្រែ និងសម្រាប់ធ្វើឧសដុត និងសម្រាស់ជាដើម ។ បច្ចុប្បន្ននៅក្នុងឃុំកំពង់ចិនជើង មានធនធានព្រៃឈើគ្របដណ្តប់នៅលើផ្ទៃដីប្រមាណ ៨៧,២៨ហិកតា ស្មើនឹង ២,២៨ភាគរយ នៃផ្ទៃដីឃុំទាំងមូល ដែលនៅក្នុងនោះមានប្រភេទព្រៃគុម្ពោធនិងឈើដុះរាយប៉ាយទំហំ ២៤,១៣ ហិកតា ស្ថិតនៅក្នុងភូមិនាងសល្វាចជាប់ព្រំប្រទល់ឃុំប្រឡាយ ហើយត្រូវបានគ្រប់គ្រង និងថែទាំដោយសហគមន៍មូលដ្ឋាន និងអាជ្ញាធរដែនដីភូមិឃុំ(ជាដីកម្មសិទ្ធិរបស់រដ្ឋ) ដែលមានមុខងារការពារឱ្យមានស្ថិរភាពទៅលើបរិស្ថានធម្មជាតិ ដូចជា ចរន្តទឹកភ្លៀង ខ្យល់អាកាស សីតុណ្ហភាពជាដើម។ល។ ព្រមទាំងបង្កើតនូវលក្ខខណ្ឌជីវៈចម្រុះប្រកបដោយនិរន្តរភាព និងផលិតកម្មកសិកម្ម។ ទន្ទឹមនេះព្រៃនេះ ក៏មានមុខងារផ្តល់នូវផលិតផល ដែលប្រជាជនប្រមូលផលបានពីក្នុងព្រៃមានដូចជា ឃ្មុំ ផ្លែឈើព្រៃ ផ្សិត វល្លិ និងរុក្ខជាតិជាច្រើនប្រភេទ ព្រមទាំងមានមុខងារសង្គម ដែលបង្កើតបាននូវបរិយាកាសអំណោយផលដល់សុខភាព និងការកម្សាន្តរបស់សង្គមផងដែរ ចំណែកព្រៃតាមដងស្ទឹងមាន ៦៣,១៥ ហិកតា ស្ថិតនៅតាមដងស្ទឹងស្ទោង ដែលគ្រប់គ្រង និងថែទាំដោយសហគមន៍មូលដ្ឋាន និងអាជ្ញាធរដែនដីភូមិឃុំ (ជាដីកម្មសិទ្ធិរបស់រដ្ឋ) ដែលមានមុខងារសម្រាប់ទប់ទល់នឹងការហូរច្រោះបាក់ដីមាត់ស្ទឹង និងសម្រាប់ជាឧសដុត និងសម្រាប់យកធ្វើជាសម្រាស់ត្រីជាដើម ។

តារាង 26៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| - ការបាត់បង់ព្រៃឈើ និងព្រៃលិចទឹក<br>- ការបាត់បង់សត្វព្រៃ<br>- ផ្ទៃដីព្រៃលិចទឹកត្រូវបានបំលែងទៅជាដីកសិកម្ម<br>- ភ្លើងឆេះព្រៃ ព្រៃលិចទឹក<br>- កាប់ព្រៃធ្វើ ឧសដុត ធ្វើទ្រើងដំណាំផ្សេងៗ | - នឹងចូលរួមគ្រប់គ្រង ការពារ និងអភិរក្សព្រៃឈើ<br>- ដាំដើមឈើឡើងវិញ<br>- ទប់ស្កាត់ការទន្ទានព្រៃឈើ<br>- ផ្សព្វផ្សាយឱ្យបានទូលំទំលាយពីសារប្រយោជន៍ព្រៃឈើ<br>- បង្កើតសហគមន៍ការពារព្រៃឈើ |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ កំពង់ចិនជើង ខែមិថុនា ឆ្នាំ២០១៨*

#### ខ. ធនធានជលផល

នៅក្នុងឃុំកំពង់ចិនជើង មានស្ទឹងចំនួនពីរ គឺស្ទឹងស្ទោង ដែលមានផ្ទៃដីទំហំ ៨០,៧៦ ហិកតា និងមួយទៀត គឺស្ទឹងនាងសល្វាច មានផ្ទៃដីទំហំ ២៥,៦៤ហិកតា និងអាងស្តុកទឹកចំនួន ០៤ ជារបស់ឯកជន ដែលមានផ្ទៃដីទំហំ៤៩,៧៩ហិកតា ស្ថិតនៅភាគខាងលិចនៃឃុំ នៅក្នុងតំបន់ដីស្រែប្រាំងនិងស្រែវស្សា ព្រមទាំងមានស្រះទឹកជាច្រើនទៀត ដែលមានទំហំ ១៤,៧៨ហិកតា ស្ថិតនៅរាយប៉ាយក្នុងភូមិសាស្ត្រឃុំ ។ ស្ទឹង អាង និងស្រះទាំងអស់នេះ មានធនធានជលផលជាច្រើនប្រភេទដូចជា ៖ ត្រីរ៉ស់ ត្រីឆ្តោរ ត្រី អណ្តែង ត្រីក្រាញ់ ត្រីទីឡាបស្យា អន្ទង់ ក្តាម ខ្យង កង្កែប អណ្តើក និងពស់ជាដើម។ល។ ហើយត្រូវបានធ្វើការនេសាទដោយប្រជាជននៅក្នុងឃុំ

ដែលជាលក្ខណៈគ្រួសារតាមរយៈការប្រើប្រាស់ឧបករណ៍រួមមានដូចជាសំណាញ់ មង ទ្រូ អួន សន្ទូចជាលក្ខណៈប្រពៃណី ដែលផលនេសាទទាំងនេះបានសម្រាប់តែការហូបចុក និងលក់ដូរតិចតួចប៉ុណ្ណោះ ។

តារាង 27៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| មានការប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិតមិនសមស្របលើដំណាំកសិកម្ម នាំឱ្យមានការថយចុះបរិមាណធនធានជលផលការប្រើឧបករណ៍នេសាទខុសច្បាប់។ | មានស្ទឹង បឹង ត្រពាំង អាងស្តុកទឹក ស្រះ និងស្រែ ដែលអំណោយផលដល់ធនធានជលផលមានច្បាប់ជលផលប្រើប្រាស់ឧបករណ៍បែបប្រពៃណី ។ |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ កំពង់ចិនជើង ខែមិថុនា ឆ្នាំ២០១៨*

រូបភាព 15៖ ប្រភពធនធានជលផល



ទឹកស្ទឹងស្ទោង



ទឹកស្ទឹងនាងសល្វាច

### ១.៣.៨. ធនធានរ៉ែ

នៅក្នុងឃុំកំពង់ចិនជើងទាំងមូល មានធនធានខ្សាច់ដែលស្ថិតនៅតាមដងស្ទឹងស្ទោង ។ ទីតាំងទាំងនេះមានការចេញលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មដោយពីមន្ទីរ ឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបានដឹកចេញ និងយកទៅធ្វើអាជីវកម្ម និងសំណង់ផ្សេងៗទៀត ។ ក្រៅពីធនធានខ្សាច់ ឃុំកំពង់ចិនជើង មិនមានធនធានរ៉ែផ្សេងៗទៀតឡើយ ។ ទៅថ្ងៃមុខប្រសិនបើគ្មានការគ្រប់គ្រងឱ្យបានត្រឹមត្រូវច្បាស់លាស់នោះទេនឹងធ្វើឱ្យបាត់បង់ចំណូលរបស់រដ្ឋព្រោះមានឈ្មួញដែលចូលដឹកដោយគ្មានច្បាប់អនុញ្ញាតនិងធ្វើឱ្យរងការខូចខាតផ្លូវទៀតផង ។

## ១.៤. ទីផ្សារ និងខ្សែសង្វាក់ផលិតផល

### ១.៤.១. ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ

បច្ចុប្បន្ននៅក្នុងឃុំកំពង់ចិនជើងមានតែផលិតផលស្រូវ ដែលអាចនាំចេញទៅរកទីផ្សារ ហើយផលិតផលស្រូវដែលនៅសល់ពីការហូបចុក អាចនាំទៅរកទីផ្សារមានប្រភេទស្រូវឡើងទឹក(ពូជបាំងកក និងក្រញ៉ូល)ស្រូវប្រដេញទឹក(ពូជ៥០៤/៥៤៥១) សែនក្រអូប ស្រូវ៤៩ ស្រូវនាងខុន និងស្រូវផ្ការំដួល គឺត្រូវបាននាំទៅរកទីផ្សារទាំងអស់ ។ នៅក្នុងឃុំកំពង់ចិនជើង ប្រជាពលរដ្ឋលក់ផលិតផលស្រូវឲ្យឈ្មួញនៅតាមភូមិ ឈ្មួញកណ្តាលនៅ

ស្រុកស្ទោង រោងម៉ាស៊ីននៅទីរួមខេត្តកំពង់ធំ រោងម៉ាស៊ីននៅស្រុកស្ទោង ឈ្មួញមកពីប្រទេសវៀតណាម និងប្រទេសថៃ ហើយតម្លៃស្រូវមានភាពខុសគ្នាទៅតាមប្រភេទ និងគុណភាពស្រូវនីមួយៗ ដែលប្រជាពលរដ្ឋតែងតែលក់ស្រូវសើម ៧០ភាគរយ នៅក្នុងនោះសម្រាប់ស្រូវសែនក្រអូបលក់ទៅឲ្យឈ្មួញក្នុងស្រុកតម្លៃ៩០-៩៥០រៀល និងប្រទេសជិតខាងមានតម្លៃ ៩៧០-១០០០រៀល /គីឡូក្រាម ហើយស្រូវ៤៩នៅក្នុងស្រុកតម្លៃ ៨០០រៀល លក់ចេញទៅក្រៅប្រទេស ៨៥០-៩០០រៀល ចំណែកស្រូវផ្ការំដួលមានតម្លៃ ១ ០០០-១ ២០០រៀលនៅក្នុងស្រុក និង១ ១០០ -១ ៣០០រៀល សម្រាប់ធ្វើការលក់ចេញទៅក្រៅប្រទេស ។

តារាង 28៖ ស្ថិតិផលិតផលស្រូវ និងតម្លៃ

| ល.រ | ប្រភេទផលិតផលស្រូវ | ឯកតា | តម្លៃគិតរៀល | តម្លៃជារៀលទីផ្សារ | |
|---|---|---|---|---|---|
| | | | | ក្នុងស្រុក | ក្រៅប្រទេស |
| ១ | សែនក្រអូប | ១គ.ក | ៩០០-១ ០០០ | | វៀតណាម |
| ២ | ស្រូវ៤៩ | ១គ.ក | ៨០០-៩០០ | | វៀតណាម |
| ៣ | ផ្ការំដួល | ១គ.ក | ១ ០០០-១ ៣០០ | | វៀតណាម |
| ៤ | ខា៨ | ១គ.ក | ៧០០-៩០០ | | វៀតណាម |
| ៥ | នាងខុន | ១គ.ក | ៧០០-៩០០ | | វៀតណាម |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់ចិនជើង ខែមិថុនា ឆ្នាំ២០១៨*

### ១.៨.២. ខ្សែសង្វាក់ និងចរាចរផលិតផល

តាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំកំពង់ចិនជើងឆ្នាំ២០១៧បានឱ្យដឹងថា បច្ចុប្បន្ននៅក្នុងឃុំកំពង់ចិនជើង ការផលិតដំណាំស្រូវរហូតដល់បានផលលក់ចេញ គឺត្រូវដំណើរការតាមខ្សែសង្វាក់ជាបន្តបន្ទាប់ ដូចជា ការផលិតដំណាំស្រូវផ្ការំដួល ដោយចាប់ផ្តើមពីការត្រៀមពូជស្រូវ ដែលភាគច្រើនបានរក្សាទុកដោយខ្លួនឯង ៨៥ ភាគរយ និងមានការទិញចូល ១៥ ភាគរយ ហើយមានការរៀបចំដីរួមទាំងការថែទាំ មានការដាក់ជី និងបាញ់ថ្នាំសម្លាប់សត្វល្អិតរហូតដល់ច្រូតកាត់ដោយប្រើប្រាស់គ្រឿងយន្តរហូតទៅដល់ ៩៥ភាគរយ និងច្រូតកាត់ដោយដៃតែ ០៥ភាគរយប៉ុណ្ណោះ ។ ទិន្នផលស្រូវដែលទទួលបាន ត្រូវហាលសម្ងួតទុកពូជ ៣០ភាគរយ (ក្នុងនោះទុកផ្គត់ផ្គង់ការហូបចុកប្រមាណ ២៥ភាគរយ និងទុកពូជ ០៥ភាគរយ) ចំណែកទិន្នផលស្រូវនៅសើមប្រមាណជា ៧០ភាគរយ បានយកទៅលក់ឱ្យឈ្មួញនៅតាមដងផ្លូវបានតម្លៃ ៩៥០-១០០០រៀល/មួយគីឡូក្រាម ហើយឈ្មួញបន្តលក់ឱ្យរោងម៉ាស៊ីនកិនស្រូវយកទៅកិនកែច្នៃជាអង្ករនាំទៅទីផ្សារក្នុងប្រទេស និងក្រៅប្រទេស ។ តែចំពោះស្រូវប្រដេញទឹក(ពូជ៥០៤/៥៤៥១)វិញ ពូជត្រូវបានទិញ ៩៥ភាគរយ និងទុកពូជ ០៥ភាគរយ ហើយមានការរៀបចំដី រួមទាំងការថែទាំមានការដាក់ជី និងបាញ់ថ្នាំសម្លាប់សត្វល្អិត រហូតដល់ច្រូតកាត់ ដែលប្រើដោយគ្រឿងយន្តទាំងអស់ ១០០ភាគរយ ចំណែកផលស្រូវ ដែលទទួលបាន ត្រូវបានហាល សម្ងួតទុកពូជ២០ភាគរយប៉ុណ្ណោះ ចំណែកផលស្រូវនៅសើមដែលសល់ប្រមាណ ៨០ភាគរយ យកទៅលក់ឱ្យឈ្មួញនៅតាមដងផ្លូវក្នុងឃុំ បានតម្លៃត្រឹមតែ ៨០០- ១ ០៥០រៀល/គីឡូក្រាម ហើយឈ្មួញបន្តយកទៅលក់ឱ្យទីផ្សារប្រទេសវៀតណាម ។

រូបភាព 16៖ ផលិតផលកសិកម្ម



ការលក់ផលិតផលស្រូវ

## ដ្យាក្រាម 4៖ គំនូសតាងនៃការលំហូផលិតផលកសិកម្ម នៅក្នុងភូមិ និង ការប្រើប្រាស់






### ១.៨.៣. ឧបសគ្គ និងឱកាសនៃទីផ្សារ និងខ្សែសង្វាក់ផលិតផល

តារាង 29៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| - ទីផ្សារមានការប្រកួតប្រជែងតម្លៃជាមួយប្រទេសជិតខាង<br>- គុណភាពស្រូវមិនទាន់ស្របតាមស្តង់ដាសម្រាប់ធ្វើការនាំចេញ<br>- ទីផ្សារស្រូវក្នុងស្រុកនូវមានកម្រិត<br>- តម្លៃស្រូវមិនទៀងទាត់(អាស្រ័យលើឈ្មួញ)<br>- ប្រើប្រាស់ពូជវៀតណាម | - អាចប្រកួតប្រជែងតម្លៃជាមួយប្រទេសជិតខាង<br>- ក្រុមហ៊ុននាំចេញស្រូវរបស់កម្ពុជាមានការកើនឡើង<br>- គុណភាពស្រូវស្របតាមស្តង់ដាសម្រាប់ការនាំចេញ<br>- ទីផ្សារស្រូវមានការកើនឡើង<br>- តម្លៃអង្ករកើនឡើង និងទៀងទាត់<br>- ពូជស្រូវមានទិន្នផលខ្ពស់ និងតម្លៃខ្ពស់ |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់ចិនជើង ខែមិថុនា ឆ្នាំ២០១៨*

# ជំពូក ២៖ ការវិភាគ តម្រូវការ សក្តានុពល និងឱបសគ្គសម្រាប់អនាគត

## ២.១. តម្រូវការសម្រាប់អនាគត

### ២.១.១. ផែនការអភិវឌ្ឍន៍ឃុំ

#### ក. ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ (២០១៨ ដល់ ២០២២)

ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ គឺជាមធ្យោបាយយ៉ាងសំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវប្រើប្រាស់សម្រាប់កំណត់អំពីបញ្ហា តម្រូវការ ដែលជាអាទិភាពយ៉ាងពិតប្រាកដរបស់មូលដ្ឋាន និងយុទ្ធសាស្ត្រនានា ដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនោះ សំដៅឆ្លើយតបទៅនឹងតម្រូវការជាអាទិភាព របស់ប្រជាពលរដ្ឋនៅក្នុងឃុំយ៉ាងមានប្រសិទ្ធិភាព តាមរយៈការរៀបចំឱ្យមានតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំមួយ មានរយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិក្រុមប្រឹក្សាឃុំ។ តារាងក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំនេះ បានរំលេចនូវចក្ខុវិស័យអភិវឌ្ឍ ដែលជាទស្សនៈរបស់ក្រុមប្រឹក្សាចង់បាន ដើម្បីកែប្រែនូវជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ឱ្យស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ហើយដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ ក៏បានរំលេចចេញឱ្យឃើញពីគោលបំណងអភិវឌ្ឍ ដែលជាលទ្ធផលរួមរបស់ក្រុមប្រឹក្សា ព្រមទាំងគោលដៅអភិវឌ្ឍដែលជាលទ្ធផលនានារបស់ក្រុមប្រឹក្សាចង់បានតាមវិស័យនីមួយៗ ។ ទន្ទឹមនេះក៏បានរំលេចឱ្យឃើញនូវយុទ្ធសាស្ត្រអភិវឌ្ឍ ដែលបានកំណត់នូវវិធីសាស្ត្រឬសកម្មភាពត្រូវអនុវត្ត ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍនីមួយៗខាងលើ ។

ចំណែកឃុំកំពង់ចិនជើង ក្រុមប្រឹក្សាឃុំនៅក្នុងអាណត្តិ(២០១៨-២០២២) ក៏បានរៀបចំឱ្យមានផែនការអភិវឌ្ឍន៍ឃុំរយៈពេលប្រាំឆ្នាំរបស់ខ្លួន ដែលក្នុងនោះបានលើកឡើងពីគម្រោងវិនិយោគរយៈពេលប្រាំឆ្នាំ ទៅក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំ ដូចមានខ្លឹមសារ ដែលក្រុមការងារបានដកស្រង់បញ្ចូលក្នុងតារាងខាងក្រោម៖

តារាង 30៖ ក្របខ័ណ្ឌនៃការអភិវឌ្ឍ និងជម្រើសនៃការប្រើប្រាស់ដីធ្លីអនាគត

| កំណត់តម្រូវការនៃការអភិវឌ្ឍ គោលដៅ និង យុទ្ធសាស្ត្រ | | | | | |
|---|---|---|---|---|---|
| តម្រូវការនៃការអភិវឌ្ឍ | ប្រភពឯកសារ | គោលដៅនៃការអភិវឌ្ឍ | យុទ្ធសាស្ត្រនៃការអភិវឌ្ឍ | សកម្មភាពជា អាទិភាព | លេខរៀងនៅលើផែនទី |
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| ១.ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនល្អប្រសើរ | -សៀវភៅផែនការអភិវឌ្ឍន៍ឃុំ ២០១៨-២០២២ | -ប្រជាពលរដ្ឋក្នុងឃុំមានផ្លូវធ្វើដំណើរស្រួលចាប់ពីឆ្នាំ ២០១៨ | -កែលម្អជួសជុលផ្លូវ និងដាក់លូបង្ហូរទឹក<br>-សាងសង់ផ្លូវថ្មីបន្ថែម | -ជួសសុលផ្លូវគ្រួសក្រហម<br>-កសាងផ្លូវបេតុង<br>-កសាងផ្លូវកៅស៊ូ<br>-ដាក់លូកាត់ផ្លូវ និងប្រព័ន្ធលូបង្ហូរទឹក | |
| ២.មានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់ | -សៀវភៅផែនការអភិវឌ្ឍន៍ឃុំ ២០១៨-២០២២ | -ប្រជាពលរដ្ឋមានប្រព័ន្ធស្រោចស្រពគ្រាប់គ្រាន់ | -ស្តារនិងជួសជុលប្រព័ន្ធធារាសាស្ត្រចាស់ៗ<br>-សាងសង់ប្រព័ន្ធធារាសាស្ត្រថ្មីបន្ថែមទៀត | -ជីកប្រឡាយស្រោចស្រព<br>-សាងសង់ទ្វារទឹក<br>-ស្តារប្រឡាយស្រោចស្រព<br>-ជួសជុលទ្វារទឹក<br>-បង្កើតសហគមន៍កសិករប្រើប្រាស់ទឹក<br>-ផ្តល់ម៉ាស៊ីនបូមទឹក<br>-បង្កើតគណៈកម្មការគ្រប់គ្រង | |

| | | | | | |
|---|---|---|---|---|---|
| | | | | ធារាសាស្ត្រ | |
| ៣.កម្រិតអប់រំមានគ្រប់កម្រិតនិងសិស្សបានចូលរៀនគ្រប់គ្នានៅក្នុងឃុំ | -សៀវភៅផែនការអភិវឌ្ឍន៍ឃុំ ២០១៨-២០២២ | -បង្កើនការចូលរៀនកុមារអាយុ ៣-៤ ឆ្នាំឲ្យបាន ៩០% នៅឆ្នាំ ២០១៨<br>-កុមារអាយុ ៦-១៤ឆ្នាំបានរៀនបញ្ចប់នូវកម្រិតមូលដ្ឋាន ៩ឆ្នាំ<br>-ចំនួនអនក្ខរជននឹងថយ | -ពង្រឹងនិងពង្រីកផ្នែកមត្តេយ្យសាលាឲ្យបានគ្រប់មូលដ្ឋានភូមិ<br>-ជម្រុញការយល់ដឹងដល់ឪពុកម្ដាយកុមារពីតម្លៃសិក្សា<br>-ពង្រឹងកិច្ចសហការជាមួយមន្ទីរជំនាញ និងអង្គការនានា ដើម្បីកាត់បន្ថយអនក្ខរកម្មរបស់ប្រជាពលរដ្ឋ | -បង្កើតថ្នាក់មត្តេយ្យ<br>-ផ្ដល់គ្រូមត្តេយ្យ<br>-ផ្សព្វផ្សាយឱ្យឪពុកម្ដាយនាំកូនចូលរៀន<br>-ផ្ដល់សម្ភារៈ សិក្សាដល់សិស្សក្រីក្រ<br>-ផ្ដល់អាហាររូបករណ៍ដល់សិស្សក្រីក្រ<br>-អប់រំកុមារឱ្យយល់ដឹងពីតម្លៃនៃការសិក្សា<br>-បើកថ្នាក់អក្ខរកម្មឱ្យបានគ្រប់ភូមិ | |
| ៤.សុខភាពរបស់ប្រជាជនល្អប្រសើរ | -សៀវភៅផែនការអភិវឌ្ឍន៍ឃុំ ២០១៨-២០២២ | -ធ្វើឱ្យប្រសើរឡើងសុខភាព និងអនាម័យរបស់ប្រជាជនបានល្អ | -បង្កើននិងកែលម្អសេវាសុខភាព និងចំណេះដឹងដល់ភ្នាក់ងារសុខភាពភូមិ | -ចាក់វ៉ាក់សាំងការពារជម្ងឺ៧មុខ<br>-ផ្ដល់ថ្នាំជាតិដែក<br>-សុំគ្រូពេទ្យ សម្ភារៈ និងថ្នាំពេទ្យ<br>-សាងសង់បង្គន់អនាម័យ<br>-អប់រំ និងផ្សព្វផ្សាយអំពីជម្ងឺឆ្លងដូចជារបេង ថ្លើម គ្រុនចាញ់ និងគ្រុណឈាមជាដើម<br>-កម្មវិធីពន្យាកំណើត | |
| ៥.ឃុំមានបរិស្ថាន និងធនធានធម្មជាតិស្រស់បំព្រង | -សៀវភៅផែនការអភិវឌ្ឍន៍ឃុំ ២០១៨-២០២២ | -ធ្វើឱ្យប្រសើរឡើងនូវធនធានធម្មជាតិ | -បង្កើនសេវាលើការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន | -បណ្ដុះបណ្ដាលច្បាប់ស្ដីពីព្រៃឈើ<br>-បណ្ដុះបណ្ដាលច្បាប់ជលផល<br>-បណ្ដុះបណ្ដាលច្បាប់បរិស្ថាន<br>-ដាក់ធុងសំរាមសាធារណៈ<br>-អប់រំចំណេះដឹងនិងច្បាប់បរិស្ថាន<br>-ជំរុញឲ្យមានធុងសំរាមគ្រួសារ<br>-ដាំកូនឈើតាមទីសាធារណៈ<br>-ស្ដារត្រពាំងចាស់ៗ ឡើងវិញ<br>-ចិញ្ចឹមត្រីតាមគ្រួសារតាមគោលការណ៍ធម្មជាតិ | |
| ៦.ឲ្យប្រជាពលរដ្ឋរស់នៅប្រកបដោយភាពសុខសាន្ត និងសុវត្ថិភាព | -សាលាឃុំ | -ភូមិ ឃុំមានសន្តិសុខ និងសណ្ដាប់ធ្នាប់ និងមានសុវត្ថិភាពល្អ | -ជម្រុញពង្រីកការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព<br>-ប្រជាពលរដ្ឋចូលរួមនិងបង្កើតក្រុមការពារមេភូមិដើម្បីរក្សាសន្តិសុខសណ្ដាប់ធ្នាប់ក្នុងភូមិឃុំ | -ពង្រឹងគណៈកម្មការដោះស្រាយទំនាស់<br>-ផ្សព្វផ្សាយច្បាប់អំពើហឹង្សាគ្រួសារ<br>-បង្កើតប៉ុស្តិ៍ស្វ័យការពារតាមភូមិ<br>-បង្កើតក្រុមប្រជាជនការពារ<br>-ផ្សព្វផ្សាយច្បាប់ភូមិបាលនិងច្បាប់ផ្សេងៗទៀត<br>-ផ្សព្វផ្សាយពីច្បាប់ចរាចរ<br>-ដាក់ផ្លាកសញ្ញាចរាចរណ៍<br>-ចុះបញ្ជីអគ្រានុកូលដ្ឋានគ្រប់ៗគ្នា<br>-ផ្សព្វផ្សាយអប់រំក្រុមក្រុមក្មេងទំនើង<br>-អប់រំពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន | |

| | | | | | |
|---|---|---|---|---|---|
| | | | | -បង្ក្រាបល្បែងស៊ីសងគ្រប់ប្រភេទ | |
| ៧.លុបបំបាត់កាត់បន្ថយទំនាស់ដីធ្លី | -សាលាឃុំ | -មានប័ណ្ណកម្មសិទ្ធិគ្រប់គ្រងដីធ្លីនិងយល់ច្បាស់ពីសិទ្ធិក្នុងការគ្រប់គ្រង | -ជម្រុញឱ្យប្រជាពរដ្ឋបានយល់ដឹងពីច្បាប់ និងមានកម្មសិទ្ធិដីធ្លីដោយស្របច្បាប់<br>-បង្កើនការគ្រប់គ្រងដីធ្លីឱ្យស្របតាមគោលនយោបាយរបស់រដ្ឋ | -ផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់ប្រជាពលរដ្ឋ<br>-ផ្សព្វផ្សាយពីច្បាប់ភូមិបាល និងច្បាប់ផ្សេងៗ<br>-ជម្រុញឱ្យប្រជាពលរដ្ឋធ្វើរបង និងព្រំដីឱ្យបានច្បាស់លាស់<br>-សាងសង់សាលាឃុំថ្មី | |
| ៨.ទិន្នផលកសិកម្មកើនឡើង | -សៀវភៅផែនការអភិវឌ្ឍន៍ឃុំ ២០១៨-២០២២ | -ធានាស្បៀងហូបគ្រប់គ្រាន់ | -បង្កើនផលិតផលកសិកម្ម | -លើកទំនប់និងភ្លឺស្រែ<br>-ជីកប្រឡាយ<br>-លូស្អាក់ទឹក ទ្វារទឹក<br>-ពូជស្រូវល្អ<br>-ធ្វើជីកំប៉ុស<br>-បច្ចេកទេសប្រើជី<br>-បច្ចេកទេសដាំឈើហូបផ្លែ | |
| ៩.មានទឹកស្អាតសម្រាប់គ្រួសារប្រើប្រាស់ | -សៀវភៅផែនការអភិវឌ្ឍ ឃុំ ២០១៨-២០២២ | -ការរស់នៅមានអនាម័យតាមរយៈមានទឹកស្អាតប្រើប្រាស់ | -ពង្រីក និងកែលម្អប្រភពផ្គត់ផ្គង់ទឹក | -អប់រំសុខភាអនាម័យ<br>-ផ្សព្វផ្សាយការប្រើប្រាស់ទឹកស្អាត<br>-ជីកអណ្តូងលូ ស្នប់ ស្រះសហគមន៍<br>-ជួសជុលអណ្តូង<br>-បច្ចេកទេសចម្រោះទឹក<br>-ជម្រុញការតបណ្តាញទឹកស្អាត | |
| ១០.សមភាពនិងសមធម៌ក្នុងការរស់នៅ | -សៀវភៅផែនការអភិវឌ្ឍ ឃុំ ២០១៨-២០២២ | -ធ្វើឱ្យប្រសើរឡើងដល់ប្រជាជនគ្រប់រូបរស់នៅប្រកបដោយសមភាព សមធម៌ គោរពគ្នាទៅវិញទៅមក | -បង្កើនការផ្សព្វផ្សាយច្បាប់ និងលើកកម្ពស់មុខរបរ | -ផ្សព្វផ្សាយច្បាប់សិទ្ធិមនុស្ស<br>-ផ្សព្វផ្សាយច្បាប់អំពើហិង្សាក្នុងគ្រួសារ<br>-ផ្សព្វផ្សាយច្បាប់ជួញដូរស្ត្រី និងកុមារ<br>-ពង្រឹងជនបង្គោលជាស្ត្រីតាមភូមិ<br>-ផ្សព្វផ្សាយច្បាប់កេងប្រវ័ញ្ចដល់កម្លាំងពលកម្មស្ត្រី និងកុមារ<br>-បណ្តុះបណ្តាលពីតួនាទីយេនឌ័រ | |
| ១១.ទិន្នផលត្រីកើនឡើង | -សាលាឃុំ | -បង្កើនធនធានជលផល | -ជម្រុញការបង្កើតវារីវប្បកម្ម | -បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី<br>-ជ្រើសរើសទីតាំង<br>-ផ្តល់ពូជត្រី<br>-ផ្សព្វផ្សាយច្បាប់ជលផល<br>-បង្កើនការចិញ្ចឹមត្រីតាមគ្រួសារ<br>-អប់រំ និងផ្សព្វផ្សាយបម្រាមនេសាទនៅរដូវត្រីពង<br>-បង្កើនការចិញ្ចឹមតាមគ្រួសារ | |
| ១២.គ្រួសារចិញ្ចឹមសត្វកើនឡើង | -សាលាឃុំ | -បង្កើនការចិញ្ចឹមសត្វបន្ថែមទៀត | -ជម្រុញការផ្តល់បច្ចេកទេសជំនាញកសិកម្ម<br>-ជម្រុញការផ្តល់បច្ចេកទេសចិញ្ចឹម ថែទាំ | -ចាក់វ៉ាកសាំងការពារជម្ងឺសត្វឱ្យបានទៀងទាត់<br>-ផ្តល់ពូជសត្វចិញ្ចឹម<br>-ផ្តល់ឥណទានមានការប្រាក់ទាប<br>-ផ្តល់បច្ចេកទេសចិញ្ចឹមសត្វ | |

| | | | | | |
|---|---|---|---|---|---|
| | | | សុខភាពសត្វ និងជ្រើសរើសពូជ | | |
| ១៣.កាត់បន្ថយមរណមាតា និងទារកក្រោយសម្រាលកូន | -សាលាឃុំ | -បង្កើនការលុបបំបាត់អត្រាស្លាប់មាតា និងទារកក្រោយសម្រាលកូន | -ពង្រឹង និងពង្រីកការផ្តល់សេវាគាំពារសុខភាពមាតា និងទារក | -ផ្សព្វផ្សាយដល់ស្ត្រីមានផ្ទៃពោះឱ្យទៅសម្រាលកូនដោយពេទ្យឆ្មប<br>-អប់រំឱ្យស្ត្រីចេះរបៀបការពារជម្ងឺឆ្លងកាមរោគ និងជម្ងឺអេដស៍<br>-មិនរើសអើង និងគាំទ្រដល់អ្នកកើតមេរោគអេដស៍<br>-ជម្រុញឱ្យស្ត្រីមានផ្ទៃពោះទៅពិនិត្យពោះនៅមណ្ឌលសុខភាព<br>-ជម្រុញឪពុកម្តាយយកកុមារទៅចាក់ថ្នាំការពារជម្ងឺ៧មុខ | |
| ១៤.ឲ្យមានថាមពលអគ្គិសនីប្រើប្រាស់គ្រប់ផ្ទះ | -សាលាឃុំ | -ទូទាំងឃុំមានអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ | -ពង្រឹងកិច្ចសហការជាមួយអង្គភាពជំនាញដើម្បីជម្រុញការផ្គត់ផ្គង់ថាមពលអគ្គិសនី | -រៀបចំបណ្តាញអគ្គិសនីតាមភូមិ | |

ប្រភពទិន្នន័យ៖ *របាយការណ៍ក្សេត្រ-បរិស្ថាន និងក្រុមប្រឹក្សាឃុំ កំពង់ចិនជើង ខែកញ្ញា ឆ្នាំ២០១៨*

### ខ. គម្រោងអភិវឌ្ឍផ្សេងៗទៀតដែលបានអនុម័តរួច

នៅក្នុងឃុំកំពង់ចិនជើង បច្ចុប្បន្នមិនមានគម្រោងអភិវឌ្ឍណាមួយ ដែលត្រូវបានអនុម័តរួចដើម្បីដំណើរការជួយជំរុញក្នុងការអភិវឌ្ឍន៍ឃុំឡើយ ។

ផែនទី ១៖ ផែនទីគម្រោងអាទិភាព ឃុំកំពង់ចិនជើង



### ២.១.២. ចំណោលប្រជាសាស្ត្រគិតទៅដល់ឆ្នាំ២០៣២

ការព្យាករណ៍ពីកំណើនប្រជាជន ជាចំនុចសំខាន់ណាស់ សម្រាប់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុង ឃុំកំពង់ចិនជើង ដែលអាចឱ្យយើងដឹងមុននូវចំនួនប្រជាជនក្នុងឃុំរយៈពេល១៥ឆ្នាំខាងមុខដ៏វែង អត្រាកំណើន ជាមធ្យមរបស់ប្រជាពលរដ្ឋនៅក្នុងឃុំកំពង់ចិនជើង ដែលបានបង្ហាញនៅក្នុងជំពូកទី១បានឱ្យដឹង គឺ៥,២៩ភាគរយ ដូច្នេះ ប្រជាពលរដ្ឋក្នុងឃុំនឹងមានការកើនឡើងរហូតដល់ឆ្នាំ ២០៣២ ត្រូវបានធ្វើចំណោលតាមរយៈការគណនា ដូចខាងក្រោម៖

-ចំនួនប្រជាពលរដ្ឋសរុបក្នុងឆ្នាំ ២០១៧ គឺ ១០ ១២៨នាក់

-អត្រាកំណើនមធ្យមប្រចាំឆ្នាំៈ ៥,២៩%

-ចំនួនមនុស្សកំណើនមធ្យមប្រចាំឆ្នាំៈ ១០ ១២៨នាក់ x ៥,២៩% = ៥៣៦នាក់

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើនឡើងបានៈ ៥៣៦នាក់ x ១៥ ឆ្នាំ = ៨ ០៣៧នាក់**

**-ដូច្នេះប្រជាជនសរុបក្នុងរយៈពេល១៥ឆ្នាំខាងមុខមានៈ ១០ ១២៨នាក់ + ៨ ០៣៧នាក់ = ១៨ ១៦៩ នាក់**

ចំណែកចំនួនគ្រួសារនៅក្នុងឃុំ នឹងមានការកើនឡើងនៅក្នុងឆ្នាំ ២០៣២ ត្រូវបានធ្វើចំណោលតាមរយៈការគណនាដូចខាងក្រោម៖

-ចំនួនប្រជាជនសរុបក្នុងឆ្នាំ ២០១៧ គឺ ១០ ១២៨នាក់

-ចំនួនគ្រួសារសរុបក្នុងឆ្នាំ២០១៧គឺ ១ ៥៤៧គ្រួសារ

-ចំនួនសមាជិកមធ្យមក្នុងមួយគ្រួសារក្នុងឆ្នាំ ២០១៧ គឺៈ

**១០ ១២៨នាក់ /១ ៥៤៧គ្រួសារ = ៦ ,៥៥នាក់ /គ្រួសារ** (ប្រហាក់ប្រហែល៧នាក់)

-ចំនួនគ្រួសារកំណើនមធ្យមប្រចាំឆ្នាំៈ

**៥៣៦នាក់៖៧នាក់= ៧៧គ្រួសារ/ឆ្នាំ**

-ចំនួនកំណើនគ្រួសារក្នុងរយៈពេល១៥ឆ្នាំៈខាងមុខកើនឡើងបានៈ

**៧៧គ្រួសារ x ១៥ ឆ្នាំ= ១ ១៥៥គ្រួសារ**

-ដូច្នេះចំនួនគ្រួសារសរុបក្នុងរយៈពេល១៥ឆ្នាំខាងមុខទៀតមានៈ

**១ ៥៤៧គ្រួសារ + ១ ១៥៥ គ្រួសារ= ២ ៧០២ គ្រួសារ**

តារាង 31៖ ចំណោលប្រជាសាស្ត្រនៃចំនួនគ្រួសារ និងប្រជាជនសរុប (០៥ឆ្នាំ)

| ឆ្នាំ | ចំនួនគ្រួសារ | ចំនួនប្រជាជន(នាក់) | |
|---|---|---|---|
| | | សរុប | ស្រី |
| ២០១៧ | ១ ៥៤៧ | ១០ ១២៨ | ៥ ០៧៧ |
| ២០២២ | ១ ៩៦៨ | ១២ ៨០៨ | ៦ ៤២១ |
| ២០២៧ | ២ ៣៨៩ | ១៥ ៤៨៩ | ៧ ៧៦៤ |
| ២០៣២ | ២ ៧០២ | ១៨ ១៦៩ | ៩ ១០៨ |

☞**ចំណាំ៖**

- ចំណោលប្រជាសាស្ត្រសម្រាប់១៥ឆ្នាំខាងមុខ៖ អត្រាកំណើនមធ្យមប្រចាំឆ្នាំxចំនួនប្រជាជនឆ្នាំបច្ចុប្បន្ន/១០០
- ដូច្នេះក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើន៖ អត្រាកំណើនប្រជាជនប្រចាំឆ្នាំx១៥

តារាង 32៖ ចំណោលប្រជាសាស្ត្រតាមក្រុមអាយុ (០៥ឆ្នាំ)

| ស្ថិតិតាមក្រុមអាយុ | ២០១៧ | | ២០២២ | | ២០២៧ | | ២០៣២ | |
|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អាយុពី០-២ឆ្នាំ | ៤៩០ | ២៣៨ | ៥៥២ | ២៦៨ | ៦១៤ | ២៩៨ | ៦៧៦ | ៣២៨ |
| អាយុពី៣-៤ឆ្នាំ | ៤០៨ | ១៨៩ | ៤៧០ | ២១៩ | ៤៧០ | ២៤៩ | ៤៧០ | ២៧៩ |
| អាយុ៥ឆ្នាំ | ២៣៤ | ១១៤ | ២៩៦ | ១៤៤ | ៣៥៨ | ១៧៤ | ៤២០ | ២០៥ |
| អាយុ៦-១១ឆ្នាំ | ១ ១០៣ | ៥៤៣ | ១ ៣៩៥ | ៦៨៧ | ១ ៦៨៧ | ៨៣០ | ១ ៩៧៩ | ៩៧៤ |
| អាយុ១២-១៤ឆ្នាំ | ៥៣១ | ២៥៦ | ៦៧២ | ៣២៤ | ៨១២ | ៣៩១ | ៩៥៣ | ៤៥៩ |
| អាយុ១៥-១៧ឆ្នាំ | ៥៣១ | ២៦៦ | ៦៧២ | ៣៣៦ | ៨១២ | ៤០៧ | ៩៥៣ | ៤៧៧ |
| អាយុ១៨-២៤ឆ្នាំ | ១ ៣៣៧ | ៦៧២ | ១ ៦៩១ | ៨៥០ | ២ ០៤៥ | ១ ០២៨ | ២ ៣៩៨ | ១ ២០៦ |
| អាយុ២៥-៦០ឆ្នាំ | ៤ ៦៤៧ | ២ ៣៥៧ | ៥ ៨៧៧ | ២ ៩៨១ | ៧ ១០៧ | ៣ ៦០៥ | ៨ ៣៣៦ | ៤ ២២៨ |
| អាយុ៦១ឆ្នាំ | ៨៤៧ | ៤៤២ | ១ ០៧១ | ៥៥៩ | ១ ២៩៥ | ៦៧៦ | ១ ៥១៩ | ៧៩៣ |
| ប្រជាជនសរុប | ១០ ១៧៩ | ៥ ០៦២ | ១២ ៧៦១ | ៣ ៣៦៨ | ១៥ ២៧៨ | ៧ ៦៣៥ | ១៥ ៨១៧ | ៨ ៩២៣ |
| ចំនួនគ្រួសារ | ១ ៥៤៧ | | ១ ៩៦៨ | | ២ ៣៨៩ | | ២ ៧០២ | |

### ២.១.៣. តម្រូវការដីធ្លីជាមូលដ្ឋាន

#### ក. ដីលំនៅឋាន

ដីលំនៅឋាន ភូមិ គឺសំដៅទៅលើដីសម្រាប់សង់ផ្ទះ និងសម្រាប់សួនដំណាំជុំវិញផ្ទះតាមគ្រួសារ។ នៅក្នុងឆ្នាំ២០១៧ ដែលជាឆ្នាំគោល យើងបានដឹងថា ដីលំនៅឋានមានទំហំ ២៣៤,៦៣ ហិកតា និងមានគ្រួសារសរុបចំនួន ១ ៥៤៧ គ្រួសារ ដែលនៅក្នុងនោះ ស្ថានភាពរស់នៅរបស់ប្រជាជនមានភាពសមស្របមិនមានបញ្ហាការខ្វះដីសម្រាប់លំនៅឋានឡើយ លើកលែងតែ ៦៧គ្រួសារ ប៉ុណ្ណោះ ដែលមិនទាន់មានដីសម្រាប់សាងសង់លំនៅឋាន ហើយបច្ចុប្បន្នគ្រួសារទាំងនោះកំពុងរស់នៅលើដីចំណីប្រឡាយ និងស្ទឹង ដែលជាដីសាធារណៈរបស់រដ្ឋ និង គ្រួសារមួយចំនួនទៀត គឺកំពុងរស់នៅលើដីកម្មសិទ្ធិរបស់អ្នកដទៃ (យោងតាមទិន្នន័យក្នុងជំពូកទី១ ត្រង់ចំណុច ១.៣.១ អំពីការកាន់កាប់ និងគ្រប់គ្រងការប្រើប្រាស់ដី)ដែលត្រូវយកចិត្តទុកដាក់ នៅក្នុងការដោះស្រាយជូនតាមរយៈដីសម្បទានដីសង្គមកិច្ច ដែលមានទីតាំងនៅខាងក្រៅឃុំ ទៅតាមការសម្រេចរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ច ។

**ក្នុងឆ្នាំ២០១៧ ផ្ទៃដីលំនៅឋានជាមធ្យមសម្រាប់មួយគ្រួសារមានចំនួន៖**

**២៣៤,៦៣កតា / ១៥៤៧គ្រួសារ = ០,១៥ហិកតា /គ្រួសារ**

តែបើយោងទៅតាមអនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច បានចែងតម្រូវឱ្យមានដីលំនៅឋានយ៉ាងច្រើន ០,២៥ហិកតា ក្នុងមួយគ្រួសារ ដែលអាចប្រើប្រាស់សម្រាប់ដោះស្រាយជូនទៅ ៦៧គ្រួសារ ដែលពួកគាត់គ្មានដីពិតប្រាកដ សម្រាប់លំនៅឋាន ដើម្បីអាចទទួលបានដីសម្បទានសង្គមកិច្ចពីរដ្ឋ ដែលមាននៅទីតាំងផ្សេងក្រៅពីឃុំកំពង់ចិនជើងនេះ ។

ដូច្នេះដើម្បីធានានិរន្តរភាពនៃការរស់នៅដូចបច្ចុប្បន្ននេះចំពោះប្រជាជនដែលមានកំណើនក្នុងរយៈពេល ១៥ឆ្នាំខាងមុខ ត្រូវការដោះស្រាយដីសម្រាប់ធ្វើកសិកម្ម ក្នុងចំនួនតាមការគណនាដូចខាងក្រោម៖

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើនឡើងចំនួនៈ ៨ ០៤១នាក់

-ចំនួនសមាជិកមធ្យមក្នុងមួយគ្រួសារមានៈ ៦,៥៥នាក់/គ្រួសារ

-តម្រូវការដីលំនៅឋានក្នុង១គ្រួសារមានចំនួន 0,១៥ហិកតា/គ្រួសារ

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខចំនួនគ្រួសារកើនឡើងបាន:

៨ ០៤១នាក់/ ៦,៥៥នាក់/គ្រួសារ = ១ ២២៨គ្រួសារ

-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ(២០១៧-២០៣២) ដីលំនៅឋានត្រូវកើនឡើង:

១២២៨គ្រួសារ x 0,១៥ហិកតា/គ្រួសារ = ១៨៤ហិកតា

-ដូច្នេះរហូតដល់ឆ្នាំ ២០៣២ ដីលំនៅឋាននៅក្នុងឃុំកំពង់ចិនជើងត្រូវកើនឡើងដល់:

២៣៤,៦៣ហិកតា + ១៨៤ហិកតា = ៤១៨,៦៣ហិកតា

ចំណែកការដោះស្រាយដីលំនៅឋាន ជូនគ្រួសារដែលគ្មានដីពិតប្រាកដចំនួន៦៧គ្រួសារតាមរយៈ

**សម្បទានសង្គមកិច្ចមានចំនួនៈ ៦៧គ្រួសារ x 0,២៥ ហិកតា/គ្រួសារ = ១៦,៧៥ហិកតា**

តារាង 33៖ តម្រូវការដីសម្រាប់លំនៅឋានក្នុងឆ្នាំ២០៣២

| បរិយាយ | ២០១៧ បច្ចុប្បន្ន | អនាគត ២០៣២ | បម្រែបម្រួលតម្រូវការដី |
|---|---|---|---|
| គ្រួសារ | ១ ៥៤៧ គ្រួសារ | ២ ៧០២ គ្រួសារ | ១ ១៥៥ គ្រួសារ |
| តម្រូវការដីលំនៅឋាន | ២៣៤,៦៣ ហិកតា | ៤១៨,៦៣ ហិកតា | ១៨៤ ហិកតា |

ខ. ដីកសិកម្ម

ចំពោះដីកសិកម្ម គឺសំដៅទៅលើដីសម្រាប់ធ្វើស្រែ និងដីចម្ការដំណាំ ។ នៅក្នុងឆ្នាំ២០១៧ ដែលជាឆ្នាំគោលយើងបានដឹងថាដីកសិកម្មសរុបមានទំហំ ៣ ៣៨៧,៣ហិកតា និងមានគ្រួសារសរុបចំនួន១ ៥៤៧ គ្រួសារ អាចធ្វើស្រែផលិតស្រូវបានសល់ពីការហូបចុកខ្លះ សម្រាប់ការនាំចេញទៅទីផ្សារ ដើម្បីដោះស្រាយជីវភាព គឺជាស្ថានភាពដែលប្រជាពលរដ្ឋអាចរស់នៅក្នុងជីវភាពសមរម្យបាន លើកលែងតែគ្រួសារចំនួន២៤៦គ្រួសារប៉ុណ្ណោះដែលមិនមានដីសម្រាប់ធ្វើកសិកម្មផ្ទាល់ខ្លួន និងមួយចំនួនស៊ីឈ្នួលគេ ។

ដូច្នេះបច្ចុប្បន្នទំហំដីកសិកម្មសម្រាប់មួយគ្រួសារជាមធ្យមមានចំនួន៖

**៣ ៣៨៧,៣ហិកតា /១ ៥៤៧គ្រួសារ = ២,១៨ហិកតា/គ្រួសារ**

តែបើយោងតាមអនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច ចែងតម្រូវឱ្យមានដីកសិកម្មយ៉ាងច្រើន ២ហិកតា នៅក្នុង១គ្រួសារ ដែលអាចប្រើប្រាស់សម្រាប់ដោះស្រាយជូនទៅ ២៤៦គ្រួសារ ដែលគ្មានដីពិតប្រាកដសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ដើម្បីអាចទទួលបានដីសម្បទានសង្គមកិច្ចពីរដ្ឋ ដែលមាននៅទីតាំងផ្សេងពីឃុំកំពង់ចិនជើង ។

ដូច្នេះដើម្បីធានានិរន្តរភាពនៃការរស់នៅដូចបច្ចុប្បន្ន ចំពោះប្រជាជន ដែលមានកំណើនក្នុងរយៈពេល ១៥ឆ្នាំខាងមុខ ត្រូវការដោះស្រាយដីសម្រាប់ធ្វើកសិកម្មចំនួនតាមការគណនាដូចខាងក្រោម៖

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ គ្រួសារកើនឡើងចំនួនៈ ១ ១៥៥គ្រួសារ

-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ (២០១៧-២០៣២) ដីកសិកម្មត្រូវកើនឡើង:

១ ១៥៥គ្រួសារ x ២,៥ហិកតា/គ្រួសារ = ២ ៨៨៧,៥ហិកតា

-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ(២០១៧-២០៣២) ដីកសិកម្មសរុបមានចំនួន:

៣ ៣៨៧,៣ហិកតា + ២ ៨៨៧,៥ហិកតា= ៦ ២៧៤,៨ហិកតា

ចំណែកការដោះស្រាយដីកសិកម្មជូនគ្រួសារដែលគ្មានដីពិតប្រាកដចំនួន ២៤៦គ្រួសារតាមរយៈសម្បទានសង្គមកិច្ចមានទំហំដីចំនួន ៥០០ហិកតា ។

**២៤៦គ្រួសារ x ២ ហិកតា/គ្រួសារ = ៤៩២ហិកតា**

តារាង 34៖ តម្រូវការដីសម្រាប់កសិកម្មក្នុងឆ្នាំ២០៣២

| បរិយាយ | ២០១៧ បច្ចុប្បន្ន | អនាគត ២០៣២ | បម្រែបម្រួលតម្រូវការដី |
|---|---|---|---|
| គ្រួសារ | ១ ៥៤៧ គ្រួសារ | ២ ៧០២គ្រួសារ | ១ ១៥៥គ្រួសារ |
| តម្រូវការដីកសិកម្ម | ៣ ៣៨៧,៣ហិកតា | ៦ ២៧៤,៨ហិកតា | ២ ៨៨៧,៥ហិកតា |

### គ. ដីព្រៃឈើ

ព្រៃឈើផ្តល់នូវផលិតផលនានាដូចជា ឈើហ៊ុប ឈើគ្រឿងសង្ហារឹម ឈើបង្គោល ឧស និងអនុផលនានាមានជ័រ វល្លិ ឱសថ ដែលគាំទ្រដល់ការចិញ្ចឹមជីវិតរបស់ប្រជាជននៅជនបទ តាមរយៈការប្រើប្រាស់ដោយផ្ទាល់ ឬតាមរយៈការលក់ដូរ។ ទន្ទឹមនេះ ព្រៃឈើក៏បានដើរតួយ៉ាងសំខាន់ក្នុងចំណោមតួនាទីដទៃទៀត ដូចជាទាក់ទាញទឹកភ្លៀង បញ្ចុះសីតុណ្ហភាព មានអាកាសធាតុបរិសុទ្ធ (ផ្តល់ខ្យល់អាកាសបរិសុទ្ធ) បញ្ចេញឧស្ម័នអុកស៊ីសែន (ជួយស្រូបយកឧស្ម័នកាបូននិច និងបញ្ចេញឧស្ម័នអុកស៊ីសែនដល់មនុស្ស) ការពារគ្រោះធម្មជាតិ (ជួយទប់ទល់ខ្យល់ព្យុះទឹកជំនន់ជួយការពារការហូរច្រោះដី និងបាក់ដី) ធ្វើឱ្យដីមានជីជាតិជាតំបន់ទេសចរណ៍ធម្មជាតិ (ជួយទប់ទល់ខ្យល់ព្យុះ ទឹកជំនន់ ជួយការពារការហូរច្រោះដី និងបាក់ដី) ធ្វើឱ្យដីមានជីជាតិ ជាតំបន់ទេសចរធម្មជាតិ ។ ចំណែកព្រៃលិចទឹកសាបជាជម្រកត្រីពង ផ្តល់ជីជាតិដី សម្រាប់ធ្វើកសិកម្ម រក្សាជីវសាស្ត្រចម្រុះនិងប្រព័ន្ធអេកូឡូស៊ី ។

ចំពោះស្ថានភាពប្រើប្រាស់ដីនៅក្នុងឃុំកំពង់ចិនជើងបច្ចុប្បន្ន មិនមានដីព្រៃឈើនោះទេគឺមានតែព្រៃដុះតាមដងស្ទឹងដែលមានផ្ទៃដីសរុបចំនួន ៦៣,០៧ ហិកតា និងព្រៃគុម្ពោតនិងដើមឈើដុះរាយប៉ាយមានផ្ទៃដីទំហំ ២៤,១៣ ហិកតា ។ នៅពេលអនាគតនៅក្នុងឃុំកំពង់ចិនជើង មិនមានតម្រូវការដីបន្ថែមសម្រាប់ព្រៃឈើនោះទេ តែនៅក្នុងឃុំមានលទ្ធភាពក្នុងការដាំដើមឈើបន្ថែមលើដីសាធារណៈផ្សេងៗ ដូចជាតាមដងផ្លូវ ប្រឡាយ អាងស្តុកទឹក សាលាសង្កាត់ សាលារៀន មណ្ឌលសុខភាព និងតាមវត្តអារាមជាដើម សម្រាប់ផ្តល់ផលជាម្លប់ ពណ៌បៃតង ធ្វើឱ្យដីមានជីជាតិ ផ្តល់អុកស៊ីសែន ស្រូបឧស្ម័នកាបូនិកជួយដល់សុខភាពប្រជាពលរដ្ឋ។ល។

### ឃ. ធនធានទឹក

ឃុំកំពង់ចិនជើង ជាឃុំមានសក្តានុពលទៅលើផ្នែកសិកម្ម ដំណាំស្រូវ និងចម្ការដំណាំឧស្សាហកម្ម ដែលនាំឱ្យឃុំកំពង់ចិនជើង មានគោលដៅអភិវឌ្ឍរយៈពេលវែងរបស់ខ្លួនផ្តោតសំខាន់ទៅលើកសិកម្មដំណាំស្រូវ និងចម្ការដំណាំឧស្សាហកម្មមិនអាចគេចចេញបានឡើយ ។ ដូច្នេះ ដើម្បីជំរុញវិស័យកសិកម្មដំណាំស្រូវ កត្តាចាំបាច់មួយក្នុងចំណោមកត្តាជាច្រើន គឺមានទឹក ដែលជាកត្តាសំខាន់ ត្រូវយកចិត្តទុកដាក់ ដោយត្រូវធ្វើយ៉ាងណាឱ្យមានទឹកគ្រប់គ្រាន់សម្រាប់ការស្រោចស្រពបានគ្រប់រដូវកាលទៅលើដីស្រែ និងចម្ការដែលឃុំមាន ដើម្បីដោះស្រាយទឹកពេលមានគ្រោះរាំងស្ងួត និងធ្វើស្រែបង្កើនរដូវឱ្យទទួលបានផលិតភាពខ្ពស់ ដើម្បីជួយផ្គត់ផ្គង់ដល់ការហូបចុក និងជំរុញការនាំចេញ សម្រាប់បង្កើនសេដ្ឋកិច្ចក្នុងគ្រួសារ ក៏ដូចសេដ្ឋកិច្ចជាតិ ដើម្បីឆ្លើយតបបានទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការជម្រុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ។

ឃុំកំពង់ចិនជើងបច្ចុប្បន្ននេះ មានស្ទឹង២ គឺស្ទឹងស្ទោង និងស្ទឹងនាងសលាច មានផ្ទៃដីទំហំ ១១៦ ហិកតា ស្រះទឹកជាច្រើនកន្លែង ដែលមានផ្ទៃដីទំហំ ១៤,៧៨ហិកតា អាងស្តុកទឹកចំនួន៤ ទំហំ ៤៩,៧៩ហិកតា ដូច្នេះ នាពេលអនាគតក្នុងរយៈពេល១៥ឆ្នាំខាងមុខ ឃុំកំពង់ចិនជើង មានតម្រូវការដីសម្រាប់ធ្វើការស្តារប្រព័ន្ធប្រឡាយបង្ហូរទឹកដែលមានស្រាប់ចំនួន ៩ខ្សែ ប្រវែង ១២ ៦៤៩,០៦ម៉ែត្រ ជាប្រឡាយតូចៗដែលមានស្រាប់ក្នុងឃុំ ដែលជាប្រព័ន្ធស្រោចស្រពមានស្រាប់ សម្រាប់នាំទឹកមកស្រោចស្រពដំណាំស្រូវនៅរដូវប្រាំង និងនៅពេលមានគ្រោះរាំងស្ងួត ហើយក៏អាចជាជម្រកត្រីនាំឱ្យកើនឡើងបរិមាណត្រី បូកផ្សំជាមួយការយកចិត្តទុកដាក់ក្នុងការចិញ្ចឹមត្រីតាមបែបចិញ្ចឹម នៅក្នុងស្រះខ្នាតតូច ស្រះចិញ្ចឹមត្រីតាមគ្រួសារ លាយឡំជាមួយបន្លែចម្រុះ និងកសិដ្ឋានចិញ្ចឹមត្រីនៅក្នុងស្រែ ដែលជាទម្រង់មួយនៃ វារីវប្បកម្ម ដែលជាបច្ចេកទេសមួយជួយដើម្បីបង្កើនបរិមាណត្រី ដោយអាចបង្កើនផលិតភាពជលផលនៅតាមវាលស្រែ ហើយមានប្រយោជន៍ក្នុងការប្រើត្រី សម្រាប់ទប់ទល់សត្វល្អិត និងដង្កូវហ្វូងក្នុងស្រែដែលបំផ្លាញផលស្រូវផង ជាប្រភពប្រូតេអ៊ីនសាច់ដ៏សំខាន់បំផុត សម្រាប់ទ្រទ្រង់សុខភាព និងជីវិតរស់នៅអោយមានភាពល្អប្រសើរ ។

**ង.ហេដ្ឋារចនាសម្ព័ន្ធ និងការប្រើប្រាស់ជាសាធារណៈផ្សេងៗទៀត**

**ង.១.វិស័យអប់រំ**

កុមារគ្រប់រូបអាចមានសិទ្ធិរៀនសូត្រ មិនថាពួកគេស្ថិតនៅកាលៈទេសៈបែបណានោះឡើយ ។ ការផ្តល់ការគាំទ្រគ្រប់គ្រាន់ដល់ការរៀនសូត្ររបស់កុមារ ពិតជាមានសារៈសំខាន់យ៉ាងខ្លាំងដើម្បីឱ្យពួកគេអាចអភិវឌ្ឍខ្លួនឈានទៅសម្រេចបានសក្តានុពលរបស់ពួកគេ ។ យ៉ាងណាមិញនៅក្នុងឃុំកំពង់ចិនជើងរយៈពេល១៥ឆ្នាំទៅមុខនឹងមានការកើនឡើងនូវចំនួនកុមារ និងមនុស្សវ័យជំទង់ក្នុងវ័យសិក្សាដូចមានការគណនានៅក្នុងចំណុច ២.១.២ ស្តីពីចំណោលប្រជាសាស្ត្រខាងលើ ដែលចាំបាច់ត្រូវគិតគូរដោះស្រាយបន្ទប់រៀនបន្ថែមនៅគ្រប់កម្រិតនៅតាមទីតាំងសាលារៀនដែលមានស្រាប់ក្នុងពេលបច្ចុប្បន្ន។

❖ **មត្តេយ្យសិក្សាៈ**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ កុមារមានអាយុពី៣-៥ឆ្នាំ នឹងកើនឡើងចំនួនៈ ២ ០៨១នាក់

-តាមរយៈមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ បានឱ្យដឹងពីការកំណត់សម្រាប់មត្តេយ្យសាលាក្នុងមួយថ្នាក់មានចំណុះកុមារសិក្សារៀនសូត្រ ៥០នាក់

-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ(២០១៧-២០៣២)បន្ទប់សិក្សាសម្រាប់ថ្នាក់មត្តេយ្យត្រូវការបន្ថែមចំនួនៈ

២ ០៨១នាក់ /៥០ នាក់/បន្ទប់= ៤២បន្ទប់

-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៥ បន្ទប់បន្ថែមចំនួនៈ

៤២បន្ទប់ /៥ បន្ទប់/អគារ= ៨ អគារ

❖ **បឋមសិក្សា**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ៦-១១ ឆ្នាំនឹងកើនឡើងចំនួនៈ ១ ៩៧៩នាក់

-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់បឋមសិក្សាត្រូវការបន្ថែមចំនួនៈ

១ ៩៧៩នាក់ ៖ ៤៥នាក់/បន្ទប់ = ៤៤បន្ទប់

-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៦ បន្ទប់បន្ថែមចំនួនៈ

៤៤បន្ទប់ ៖ ៦ បន្ទប់/អគារ = ៧ អគារ

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សាតែចំនួនៈ

៧ អគារ/វេន ៖ ២ វេន = ៤អគារ

❖ **អនុវិទ្យាល័យ**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ១២-១៤ ឆ្នាំនឹងកើនឡើងចំនួនៈ ៩៥៣នាក់

-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់អនុវិទ្យាល័យសិក្សាត្រូវការបន្ថែមចំនួនៈ

៩៥៣នាក់ ៖ ៤៥នាក់/បន្ទប់ =២១បន្ទប់

-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ១២ បន្ទប់បន្ថែមចំនួនៈ

២១បន្ទប់ ៖ ១២បន្ទប់/អគារ =២ អគារ

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សាតែចំនួនៈ

២ អគារ /វេន ៖ ២ វេន = ១ អគារ

❖ **វិទ្យាល័យ**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ១៥-១៧ឆ្នាំនឹងកើនឡើងចំនួនៈ ៩៥៣នាក់

-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់អនុវិទ្យាល័យសិក្សាត្រូវការបន្ថែមចំនួនៈ

៩៥៣នាក់ ៖ ៤៥នាក់/បន្ទប់ = ២១បន្ទប់

-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ១២ បន្ទប់បន្ថែមចំនួនៈ

២១ បន្ទប់ ៖ ១២បន្ទប់/អគារ = ២អគារ

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សាតែចំនួនៈ

២ អគារ /វេន ៖ ២ វេន = ១អគារ

តារាង 35៖ កំណើនកុមារ តម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១៨ ដល់ឆ្នាំ ២០៣២

| **បរិយាយ** | **បច្ចុប្បន្ន២០១៧** | **អនាគត ២០៣២** | **បម្រែបម្រួល** |
|---|---|---|---|
| **សាលាមត្តេយ្យ** | | | |
| សិស្ស | ៨៩៨ នាក់ | ២ ០៨១នាក់ | ១ ១៨៣នាក់ |
| បន្ទប់ | ៤ បន្ទប់ | ៤២បន្ទប់ | ៣៨ បន្ទប់ |
| អគារ | ៤ អគារ | ៨ អគារ | ៦ អគារ |
| **សាលាបឋមសិក្សា** | | | |
| សិស្ស | ១ ១០៣ នាក់ | ១ ៩៧៩នាក់ | ២៦៨នាក់ |
| បន្ទប់ | ៥ បន្ទប់ | ៤៤ បន្ទប់ | ៣៩ បន្ទប់ |
| អគារ | ១ អគារ | ៧ អគារ | ៦ អគារ |
| **អនុវិទ្យាល័យ** | | | |
| សិស្ស | ៥៣១នាក់ | ៩៥៣ នាក់ | ៤២២នាក់ |

| | | | |
|---|---|---|---|
| បន្ទប់ | ៥ បន្ទប់ | ២១ បន្ទប់ | ១៦បន្ទប់ |
| អគារ | ១ អគារ | ២ អគារ | ១ អគារ |
| **វិទ្យាល័យ** | | | |
| សិស្ស | ៥៣១នាក់ | ៩៥៣ នាក់ | ៤២២នាក់ |
| បន្ទប់ | ០ បន្ទប់ | ២១ បន្ទប់ | ២១ បន្ទប់ |
| អគារ | ០ អគារ | ២ អគារ | ២ អគារ |

## ៦.២. វិស័យសុខាភិបាល

នៅក្នុងឃុំកំពង់ចិនជើង មិនមានមណ្ឌលសុខភាពនោះទេ ដោយប្រជាពលរដ្ឋទទួលសេវាសុខភាព នៅមន្ទីរពេទ្យបង្អែកស្ទោង ដែលស្ថិតនៅក្នុងភូមិឈើទាល ឃុំកំពង់ចិនត្បូង ហើយបើផ្អែកទៅតាមកំណើនប្រជាជនដែលមានការកើនឡើង និងស្ថានភាពភូមិសាស្ត្ររបស់ឃុំទាំងមូល យើងសង្កេតឃើញថា មានភូមិដែលនៅឆ្ងាយពីមណ្ឌលសុខភាព ដូចជា ភូមិត្រាច និងភូមិនាងសល្ងាច ។ នៅថ្ងៃអនាគត១៥ឆ្នាំទៅមុខ នឹងមានរៀបចំបង្កើតឲ្យមានមណ្ឌលសុខភាព ០១កន្លែង ដែលស្ថិតនៅភូមិត្រាច ដោយជំរុញការផ្តល់សេវាពីមណ្ឌលសុខភាពនេះជូនដល់ប្រជាពលរដ្ឋ នៅក្នុងឃុំឱ្យបានប្រសើរឡើង ហើយក៏នឹងអាចផ្តល់លទ្ធភាពឱ្យមានគ្លីនិចឯកជនបំពេញបន្ថែមទៀតផងដែរ ។

## ៦.៣. អគ្គិសនី

អគ្គិសនី មានសារៈសំខាន់ណាស់សម្រាប់ជីវិតរស់នៅរបស់មនុស្សយើង ។ អគ្គិសនីផ្តល់ឱ្យយើងនូវសន្តិសុខ សុវត្ថិភាព សុខភាព និងភាពសម្បូររុងរឿង ដូចជា ជួយដោះស្រាយបញ្ហា ធ្វើឱ្យកាន់តែប្រសើរឡើងនូវសន្តិសុខសុវត្ថិភាព ការប្រែប្រួលអាកាសធាតុ ផលិតកម្មស្បៀងអាហារ និងការពង្រឹងសេដ្ឋកិច្ច ដោយរួមទាំងការអប់រំនិងការកម្សាន្តផងដែរ។ ចំពោះស្ថានភាពការប្រើប្រាស់អគ្គិសនី នៅក្នុងឃុំកំពង់ចិនជើង ដូចបានរៀបរាប់ក្នុងជំពូកទី១ ដែលបច្ចុប្បន្ននៅក្នុងឃុំកំពង់ចិនជើងមានប្រជាពលរដ្ឋប្រើប្រាស់បណ្តាញអគ្គិសនីចំនួន១៥៤៣ខ្នងផ្ទះស្មើនឹង ៩៥ភាគរយ។ ដូច្នេះនាពេលអនាគត១៥ឆ្នាំទៅមុខនឹងមានការកើនឡើងចំនួនគ្រួសារថែមទៀត អាជ្ញាធរពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ជាពិសេសក្រុមប្រឹក្សាឃុំត្រូវតែខិតខំយកចិត្តទុកដាក់ក្នុងការដោះស្រាយពង្រីកនូវបណ្តាញអគ្គិសនី ផ្គត់ផ្គង់ឱ្យដល់គ្រប់គ្រួសារបានប្រើប្រាស់ ។

## ៦.៤. ទីលានចាក់សំរាម

សំរាម គឺជាកាកសំណល់ដែលត្រូវបានគេបោះបង់ចោល វាមានពីរប្រភេទ គឺកាកសំណល់រឹង និងរាវ ។ ដូច្នេះសំរាម គឺជាអ្វីដែលបំបែកចេញពីបរិស្ថានយើង និងអាចបង្កើតកន្លែងគរមួយផ្សេងទៀត ប្រសិនបើយើងមិនប្រុងប្រយ័ត្ន ។ គំនរសំរាម បានមកពីកាកសំណល់ផ្ទះបាយ ដែលដាក់លាយឡំចូលគ្នាជាមួយនឹង អំបែងកែវ អំបែងចាន និងអំបែងដបជាដើម ។ នៅពេលមានភ្លៀងធ្លាក់ចុះមក គឺដូចជាការចម្រោះជាតិពុល គ្រប់បែបយ៉ាងឱ្យហូរជ្រាបទៅបំពុលដី បំពុលទឹក និងបំពុលដល់ប្រភពទឹកនៅក្នុងស្រទាប់ដីខាងក្រោម ជាហេតុធ្វើឱ្យទឹកស្អាតក្លាយជាទឹកមិនស្អាត មានលោហៈធ្ងន់ និងជួនកាលមានបាក់តេរីកាចៗ នៅពេលនោះ បណ្តាលឱ្យលេចឡើងនូវជម្ងឺរាតត្បាតផ្សេងៗដោយសារតែការទទួលទានទឹកមិនស្អាត ។

ចំពោះសំរាម នៅក្នុងឃុំកំពង់ចិនជើងបច្ចុប្បន្ន ប្រជាពលរដ្ឋភាគច្រើន បោះចោលនៅក្បែរផ្ទះ ខ្លះចោលរាយប៉ាយនៅតាមផ្លូវ ខ្លះដុតចោល ដែលធ្វើឱ្យរងការបំពុលពីផ្សែងដុត និងបាត់បង់សោភ័ណភាពក្នុងភូមិ ឃុំ ។ ដើម្បីអាចគ្រប់គ្រងសំរាមបាន ឃុំត្រូវរកដី ដែលមានទីតាំងសមស្របនៅក្នុងឃុំ ដែលនៅដាច់ដោយឡែកឆ្ងាយពីភូមិ ធ្វើជាទីលានចាក់សំរាមមួយកន្លែង តែក្នុងករណីក្នុងឃុំមិនមានទីលានចាក់សំរាមក៏គួររៀបចំឲ្យមានឡត៌សម្រាប់ដុតសំរាមមួយផងដែរ ឬ រកទីតាំងនៅខាងក្រៅឃុំចាក់សំរាមរួមជាមួយគ្នាឃុំផ្សេង ដើម្បីប្រមូលសំរាមដែលមាននៅក្នុងឃុំទៅរក្សាទុកឱ្យបានគត់មត់ ឬត្រូវប្រមូលសំរាមប្លាស្ទីកយកទៅកែច្នៃផលិតឡើងវិញ ចំណែកសំរាមចេញពីផ្ទះបាយ និងស្លឹកឈើផ្សេងៗក្រៅពីប្លាស្ទីកអាចកែច្នៃធ្វើជីដូចជាជីកំប៉ុស្តជាដើម ដើម្បីប្រើប្រាស់នៅក្នុងការបង្កើនគុណភាពដីដាំដុះ ។ ជារួមសំខាន់ជាងគេបំផុត គឺត្រូវលុបបំបាត់សំរាមប្លាស្ទីកឱ្យអស់ពីភូមិ ឃុំ ។

### ៦.៥. ដីកប់ខ្មោច

ជាទូទៅពិធីបូជាសព មានពីប្រភេទ គឺពិធីដុតសព និងកប់សពរក្សាក្នុងដី ក្នុងពិធីទាំងពីរនេះ គឺពីធីកប់សពត្រូវការប្រើប្រាស់ដី ដែលធ្វើឱ្យមានការបាត់បង់ដី សម្រាប់ប្រើប្រាស់បម្រើឱ្យការអភិវឌ្ឍន៍នៅក្នុងសហគមន៍ដែលមនុស្សរស់នៅ ។ នៅក្នុងឃុំកំពង់ចិនជើងបច្ចុប្បន្ន ក៏មានប្រើពិធីទាំងពីរនេះដែរ ចំណែកការប្រើប្រាស់ដីនៅក្នុងឃុំ ក៏មានតម្រូវការកាន់តែច្រើនឡើង ដើម្បីបំពេញតម្រូវការស្របទៅនឹងអត្រាមរណៈទៅថ្ងៃអនាគត ដែលចាំបាច់អាជ្ញាធរដែនដីពាក់ព័ន្ធ ជាពិសេសក្រុមប្រឹក្សាឃុំកំពង់ចិនជើង ត្រូវតែខិតខំយកចិត្តទុកដាក់គិតគូរអំពីពិធីបូជាសពនេះ ដែលនឹងកើតឡើងជាបន្តបន្ទាប់ ដោយគួរខិតខំលប់បំបាត់ការបញ្ចុះសពដោយកប់នៅក្នុងដី ហើយជំនួសមកវិញ ដោយការរៀបចំឱ្យមានកន្លែងបូជាសពនៅតាមវត្តអារាម ឬកន្លែងណាផ្សេងដាច់ឆ្ងាយពីភូមិ ដែលជាជម្រើសល្អបំផុត ។

### ៦.៦ . ស្រះ និងអណ្តូងទឹក

ទឹក គឺជាផ្នែកមួយនៃធាតុដ៏សំខាន់បំផុតសម្រាប់រាងកាយមនុស្ស ជាពិសេសសម្រាប់សុខភាពដើម្បីធានាបាននូវការរស់រានមានជីវិតរបស់មនុស្ស ។ ទឹកអាចនឹងមាននៅគ្រប់ទីកន្លែង ប៉ុន្តែវាមិនត្រូវបានយកមកសម្រាប់ការទទួលទានបានទាំងអស់នោះទេ គឺត្រូវការទឹកដែលស្អាត ។ នៅក្នុងឃុំបច្ចុប្បន្ននេះមានការប្រើប្រាស់ទឹកស្អាតសម្រាប់ទទួលទានតាមរយៈការប្រើទឹកស្រះ និងអណ្តូងដូចបានរៀបរាប់នៅក្នុងតារាងខាងក្រោមសម្រាប់ផែនការរយៈពេល១៥ឆ្នាំខាងមុខដែរ ប៉ុន្តែចំនួនស្រះទឹក និងអណ្តូងទាំងអស់នេះសម្រាប់ឆ្នាំ ២០១៧ មិនមានបរិមាណគ្រប់គ្រាន់សម្រាប់បំពេញតម្រូវរបស់មនុស្ស និងសត្វចិញ្ចឹមគ្រប់គ្រាន់នារដូវប្រាំងបានឡើយ ។

ដូច្នេះ ដើម្បីឆ្លើយតបទៅនឹងការខ្វះខាតនាពេលបច្ចុប្បន្ន ក៏ដូចជាឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋក្នុងរយៈពេល១៥ឆ្នាំខាងមុខបាន អាជ្ញាធរដែនដីពាក់ព័ន្ធជាពិសេសក្រុមប្រឹក្សាឃុំ ត្រូវយកចិត្តទុកដាក់លើកទឹកចិត្តឱ្យប្រជាពលរដ្ឋក្នុងឃុំត្រង់ទឹកភ្លៀង នៅរដូវវស្សារក្សាទុកក្នុងអាងស្តុកតាមផ្ទះរៀងៗខ្លួន សម្រាប់ដោះស្រាយការប្រើប្រាស់នៅរដូវប្រាំង ដែលខ្សត់ទឹកហើយថែមពីលើនេះ ក៏ត្រូវបំផុសឱ្យមានការរៀបចំជីកស្រះសហគមន៍ផងដែរ ព្រមទាំងជំរុញលើកទឹកចិត្តទៅដល់វិស័យឯកជនឱ្យផលិតទឹកស្អាត និងតបណ្តាញឱ្យទៅដល់គ្រប់ខ្នងផ្ទះរបស់ប្រជាពលរដ្ឋ ដែលអាចឱ្យពួកគាត់បានប្រើប្រាស់គ្រប់ក្រុមគ្រួសារ ដែលជាជម្រើសដ៏ល្អបំផុត ។

## ២.២. តំបន់រសើប

តំបន់រសើប គឺជាតំបន់ដែលទាមទារនូវការការពារបន្ថែម និងជាពិសេសដោយផ្អែកលើសារៈសំខាន់ ឬជីវចម្រុះនៃបរិស្ថាន បេតិកភណ្ឌវប្បធម៌ តម្លៃខាងផ្លូវចិត្តដែលមានលក្ខណៈដូចជា៖ តំបន់ព្រៃណីសម្រាប់ជនជាតិដើមភាគតិច ឬក៏មូលហេតុសំខាន់ៗផ្សេងទៀត ។ តំបន់បង្ហាញបញ្ហាចោទ ចាំបាច់ត្រូវតែកំណត់ ដើម្បីធានាថា ឃុំ/សង្កាត់ត្រូវការដឹងឮនូវតម្រូវការ និងប្រធានបទពិសេសទាំងនេះ ។

នៅក្នុងឃុំកំពង់ចិនជើង តំបន់រសើបមានលើដីសម្រាប់ធ្វើកសិកម្ម និងចម្ការ របស់ប្រជាពលរដ្ឋ ដែលជាតំបន់សង្ស័យមានគ្រាប់មិនទាន់ផ្ទុះចំនួន ០១កន្លែង មានទំហំចំនួន ៤,២៥ហិកតា និងតំបន់សហគមន៍នេសាទ។ តំបន់ដីសង្ស័យមានមីនដែលត្រូវទាមទារនូវកិច្ចការពារបន្ថែម និងជាពិសេសនោះ ដោយសារតែតំបន់នេះត្រូវការហាមឃាត់ប្រជាពលរដ្ឋចូលទៅតំបន់នេះ ដែលនាំឱ្យមានគ្រោះថ្នាក់ពីគ្រាប់មីនមិនទាន់ផ្ទុះនោះ និងតំបន់ ដែលមានច្បាប់ស្តីពីជលផល ដែលត្រូវការពារ និងការនេសាទ ។ តំបន់រសើបដែលមាននៅក្នុងឃុំ កំពង់ចិនជើងដូចបានរៀបរាប់ខាងលើមានបង្ហាញនៅក្នុងផែនទីតំបន់រសើបខាងក្រោម ។

ផែនទី 10៖ ផែនទីតំបន់រសើប ឃុំកំពង់ចិនជើង



## ២.៣. ការប្រឈម

### ២.៣.១. ការប្រឈមដោយធម្មជាតិ

#### ក. កំណើនប្រជាជន

បច្ចុប្បន្នឃុំកំពង់ចិនជើង បានរកឃើញថា ប្រជាពលរដ្ឋកើនឡើងតាមធម្មជាតិជារៀងរាល់ឆ្នាំដែលគិតជាមធ្យមប្រមាណជា ៥,២៧ភាគរយ ហើយទៅថ្ងៃអនាគតត្រឹមឆ្នាំ២០៣២ បញ្ហាកំណើនប្រជាជន ត្រូវបានធ្វើការគិតគូរដោះស្រាយ ដោយពុំមានបញ្ហាប្រឈមធ្ងន់ធ្ងរអ្វីឡើយ តែបន្តពីនេះទៅមុខវែងឆ្ងាយនឹងអាចកើតមានបញ្ហាប្រឈមដែលត្រូវបន្តដោះស្រាយមួយចំនួនដូចខាងក្រោម៖

-ខ្វះខាតដីលំនៅឋាន ដែលនាំឱ្យមានការដោះស្រាយផលប៉ះពាល់ទៅដល់ដីស្រែ

-ខ្វះខាតដីស្រែ ដែលនាំឱ្យពិបាកដោះស្រាយដោយឃុំពុំមានដីសល់ទំនេរសម្រាប់បំពេញការខ្វះខាតនេះ

-ខ្វះខាតដល់ការផ្តល់សេវាអប់រំ ដែលត្រូវដោះស្រាយការសាងសង់សាលារៀន គ្រូបង្រៀន និង សម្ភារៈសិក្សាបន្ថែម

-ខ្វះខាតសេវាសុខាភិបាល ដែលត្រូវដោះស្រាយគ្រូពេទ្យ ឧបករណ៍និងសម្ភារៈពេទ្យនិងថ្នាំពេទ្យបន្ថែម

-ខ្វះខាតទឹកស្អាត អគ្គិសនី ដែលត្រូវដោះស្រាយផ្គត់ផ្គង់បន្ថែម

#### ខ. គ្រោះធម្មជាតិ ការវិចរិលនៃធម្មជាតិ៖

បច្ចុប្បន្ននៅក្នុងឃុំកំពង់ចិនជើង គេសង្កេតឃើញថា មានជួបបញ្ហាគ្រោះធម្មជាតិកើតស្ទើរតែរៀងរាល់ឆ្នាំដូចជា ខ្យល់ព្យុះ/កន្ត្រាក់ (ខូចខាតផ្ទះ បាក់រលំដើមឈើ) គ្រោះទឹកជំនន់ (ខូចប្រព័ន្ធផ្លូវ ដំណាំស្រូវ និងសត្វពាហនៈមានជម្ងឺ) គ្រោះរាំងស្ងួត ទឹកស្ទឹង បឹង អូររីងស្ងួត(ខ្វះទឹក ប្រើប្រាស់ ស្រោចស្រព និងចិញ្ចឹមសត្វ) សត្វល្អិតចង្រៃបំផ្លាញដំណាំ និងភ្លៀងខុសរដូវ (សត្វកើតជម្ងឺ ប៉ះពាល់ដំណាំ)និងដីធ្លីដែលជាធនធានធម្មជាតិកម្រក៏មានភាពរេចរឹលទៅៗ ដូចជា ធ្វើឱ្យដីស្រែរឹងនិងខ្សោះជីជាតិដោយសារការប្រើប្រាស់ជីគីមីនិងថ្នាំសម្លាប់សត្វល្អិតលើដំណាំស្រូវ ។ ទៅថ្ងៃអនាគត ប្រជាពលរដ្ឋនៅក្នុងឃុំនៅតែបន្ត ជួបប្រទះនូវបញ្ហាប្រឈមទាំងនេះជាដដែល បើសិនជាមិនមានយន្តការឬដំណោះស្រាយដើម្បីទប់ទល់ទៅនឹងគ្រោះរាំងស្ងួត ព្រមទាំងមិនមានការកែប្រែនូវឥរិយាបថក្នុងការប្រើប្រាស់ដីកសិកម្មឱ្យបានសមស្របទេនោះ។

### ២.៣.២. ការប្រឈមដោយ ការអភិវឌ្ឍដែលពុំមាននិរន្តរភាព

ជាការពិតណាស់រាល់គម្រោងអភិវឌ្ឍនានា ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានធម្មជាតិ ជាពិសេសការប្រើប្រាស់ដីក្នុងទីតាំងភូមិសាស្ត្រណាមួយ តែងតែនាំមកនូវការរីកចម្រើនជានិច្ច តែផ្ទុយទៅវិញ បើគម្រោងអភិវឌ្ឍទាំងនោះពុំទាន់បានគិតគូរគ្រប់ជ្រុងជ្រោយទៅដល់ទីតាំងភូមិសាស្ត្រនីមួយៗ និងសក្តានុពលនៃធនធាន ដែលមានវានឹងនាំមកនូវផលប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ច សង្គម និងបរិស្ថាននាពេលអនាគត ដោយមិនអាចធានាចីរភាពនៃគម្រោងទាំងនោះ ទៅដល់កូនចៅជំនាន់ក្រោយនៅក្នុងតំបន់នោះបានឡើយ ដូចជា ស្ថានភាពនៅក្នុងឃុំកំពង់ចិនជើង ដែលជាឃុំគោលដៅសិក្សារៀបចំផែនការប្រើប្រាស់ដី ដូចដែលបានរៀបរាប់នៅក្នុងជំពូកទី១នៃរបាយការណ៍នេះបានឱ្យដឹងថានៅឃុំកំពង់ចិនជើង មានស្ថានភាពភូមិសាស្ត្រ ជាតំបន់វាលទំនាបមានធនធានដីអំណោយផលដល់ដំណាំស្រូវ និងដំណាំចម្ការ ដែលជាសក្តានុពលដល់ការអភិវឌ្ឍដល់ឃុំនេះ ដោយមិនមានការអះអាងណាផ្សេងក្រៅពីនេះនៅឡើយ។ ដូចនេះ ឃុំកំពង់ចិនជើង គួរចៀសវាងដាច់ខាតនៅគម្រោងអភិវឌ្ឍ

ទាំងឡាយណា ដែលនាំឱ្យមានផលប៉ះពាល់ដល់ការបាត់បង់ដីស្រែចម្ការ ដែលខ្លួនមាន ធ្វើឱ្យឃុំមានការថយចុះឱកាសអភិវឌ្ឍ ដូចជា គម្រោងចាក់លុបដីស្រែ ដីចម្ការបង្កកទុកលក់ឬពុះដីឡូត៍លក់ ដើម្បីកេងផលចំណេញពីឈ្មួញនិងគម្រោងជីកយកអាចម៍ដីទៅលក់ជាដើម។ លើកលែងតែគម្រោងណាពាក់ព័ន្ធ ដែលធ្វើឱ្យប្រសើរឡើងដល់ប្រព័ន្ធកសិកម្ម មានដូចជា កសិដ្ឋានផលិតពូជស្រូវ ពូជដំណាំ ស្រែគម្រូ ផលិតជីធម្មជាតិ ទុកដាក់គ្រឿងយន្តកសិកម្ម ទន្ទឹមនឹងនេះក៏នៅមានគម្រោងអភិវឌ្ឍប៉ះពាល់ទៅដល់ការរស់នៅ និងបរិស្ថាន ដែលគួរចៀសវាងផងដែរ ដូចជា គម្រោងបង្កើតសិប្បកម្ម ឧស្សាហកម្ម ដែលធ្វើឱ្យមានការបង្ហូរទឹកស្អុយកខ្វក់ជាដើម។ល។ ទន្ទឹមទៅនឹងការប្រឈមដោយការអភិវឌ្ឍខាងលើដែលត្រូវចៀសវាង ក៏មានការប្រឈមនឹងអំពើអនាធិបតេយ្យ ដែលកើតឡើងពីការដោះស្រាយការខ្វះខាតរបស់ប្រជាពលរដ្ឋនៅក្នុងឃុំផងដែរ ដូចជាការសាងសង់ផ្ទះស្នាក់នៅលើដីនៅតាមចិញ្ចើមផ្លូវសាធារណៈ ការទន្ទ្រានដីព្រៃ ធ្វើស្រែបំពានទៅលើប្រឡាយ និងស្ទឹងបឹង ជាដើម។

## ២.៤.ឱកាស

### ២.៤.១. ដោយអំណោយផលពីធម្មជាតិ

នៅលើលោកយើងនេះ ធម្មជាតិ គឺពិតជាបានផ្តល់នូវធនធានដ៏មានសារសំខាន់ សម្រាប់ធ្វើអ្វីៗគ្រប់យ៉ាងដែលមនុស្សចង់ធ្វើ ដូចជា មនុស្សបានប្រើប្រាស់ធនធានដី និងទឹកសម្រាប់ការដាំដុះ ឈើធ្វើឧសដុត សម្រាប់ផ្តល់កំដៅ ឬសាងសង់ទីជម្រក ខ្យល់អាកាស ត្បូងថ្ម ប្រេង ឧស្ម័នធម្មជាតិ និងរ៉ែជាវត្ថុធាតុដើមជាច្រើនទៀត ដូចជាដែកទង់ដែងជាដើម សម្រាប់ធ្វើឧបករណ៍ប្រើប្រាស់ផ្សេងៗ ចំណែកនៅក្នុងឃុំកំពង់ចិនជើង យើងផ្តោតសំខាន់លើធនធានដី ដែលមានសក្តានុពលលើសលប់ទៅលើការអភិវឌ្ឍឃុំ ដូចបានរកឃើញ និងរៀបរាប់នៅក្នុងជំពូកទី១នៃរបាយការណ៍នេះ។ នៅក្នុងឃុំកំពង់ចិនជើងមានស្ថានភាពអំណោយផលពីធម្មជាតិដូចខាងក្រោម៖

- ស្ថានភាពដី ជាវាលទំនាប ដែលអំណោយផលដល់ការដាំដុះដំណាំស្រូវ ព្រមទាំងទំនាបទាបនិងទំនាបខ្ពស់អំណោយផលដល់ការដាំដំណាំចម្ការជាពិសេសដំណាំឧស្សាហកម្ម។
- នៅជិតប្រភពស្ទឹង បឹង អូរ អាចមានលទ្ធភាពនាំទឹកមកស្រោចស្រពដំណាំស្រូវ និងដំណាំចម្ការ នៅពេលជួបប្រទះគ្រោះរាំងស្ងួត និងមានលទ្ធភាពនាំទឹកមកស្រោចស្រពបង្កើនរដូវធ្វើស្រែបានច្រើនដង។
- នៅរដូវវស្សាមានភ្លៀងធ្លាក់ច្រើនអាចស្រោចស្រពដំណាំស្រូវ និងដំណាំចម្ការបាន។
- អាកាសធាតុ ក្តៅ ហើយសើម អំណោយផលដល់ការលូតលាស់របស់រុក្ខជាតិ និងដំណាំគ្រប់ប្រភេទ។

### ២.៤.២. ដោយបច្ចេកវិទ្យាថ្មីៗ

ជីវិតរស់នៅ ដែលយើងកំពុងតែទទួលបានភាពប្រសើរឡើងនាពេលបច្ចុប្បន្ននេះ គឺដោយសារតែមានការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា។ បច្ចេកវិទ្យាថ្មីៗបានធ្វើឱ្យមានការផ្លាស់ប្តូរកាន់តែប្រសើរឡើងសម្រាប់ជីវិតរស់នៅរបស់ពលរដ្ឋ ដែលធ្វើឱ្យអ្វីៗនៅក្នុងពេលបច្ចុប្បន្នកាន់តែប្រសើរឡើង និងងាយស្រួលជាងមុន។ បច្ចេកវិទ្យាថ្មីអាចកាត់បន្ថយបាននូវពេលវេលា គុណភាព និងការចំណាយទៅលើកម្លាំងពលកម្មក្នុងផលិតកម្មនានា។

បច្ចុប្បន្ន ស្ថានភាពក្នុងឃុំកំពង់ចិនជើង មានសក្តានុពលខ្លាំងដោយពឹងផ្អែកទៅលើផលិតកម្មដំណាំស្រូវ និងដំណាំចម្ការឧស្សាហកម្ម ហើយនាពេលអនាគត ក៏នៅពឹងផ្អែកលើផលិតកម្មដំណាំទាំងនេះដដែលដែរនោះ ប្រជាពលរដ្ឋនឹងចាំបាច់ត្រូវការបច្ចេកវិទ្យាទំនើបទាន់សម័យ សម្រាប់វិស័យកសិកម្មដំណាំស្រូវ និងចម្ការ ដើម្បីជួយជំរុញឱ្យមានការកើនឡើងទិន្នផលខ្ពស់ ដើម្បីអាចដោះស្រាយបាននូវសន្តិសុខស្បៀង និងមានប្រាក់ចំណូលកាន់តែខ្ពស់ ដែលនាំឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំកាន់តែប្រសើរឡើង ក្នុងពេលដែលមានកំណើន

ប្រជាពលរដ្ឋកាន់តែខ្ពស់នាពេលខាងមុខ ។ តាមរយៈបច្ចេកវិទ្យាថ្មីៗ នឹងនាំឱ្យប្រជាពលរដ្ឋមានឱកាសប្រើប្រាស់គ្រឿងយន្តកសិកម្មទំនើបទាន់សម័យ សម្រាប់ការផលិតដំណាំស្រូវ រួមមានដូចជា៖ ម៉ាស៊ីនភ្ជួររាស់ដី ម៉ាស៊ីនពង្រាបដីស្រែដោយប្រើប្រាស់ប្រព័ន្ធឡាស៊ែរ ម៉ាស៊ីនដកស្ទូង ដ្រូនបាញ់ថ្នាំសម្លាប់សត្វល្អិត និងដាក់ជី ម៉ាស៊ីនច្រូតកាត់ និងបោកបែន ព្រមទាំងគ្រឿងយន្តដឹកជញ្ជូនជាដើម។ល។

### ២.៤.៣. គម្រោងវិនិយោគ

សម្រាប់នាពេលអនាគត ឃុំកំពង់ចិនជើង ដែលមានសក្តានុពលខ្ពស់ទៅលើដំណាំស្រូវនោះ នឹងនាំឱ្យមានការផ្តួចផ្តើមបង្កើតគម្រោងវិនិយោគនានា ដែលភាគច្រើនផ្តោតទៅលើដំណាំស្រូវនិងដំណាំចម្ការ មានដូចជាគម្រោងបង្កើតកសិដ្ឋានកសិកម្មដើម្បីជំរុញផលិតកម្មដំណាំស្រូវ និងដំណាំចម្ការ ព្រមទាំងគម្រោងវិនិយោគទៅលើការកែច្នៃផលិតផលកសិកម្មដើម្បីនាំចេញ ដែលនឹងអាចផ្តល់ការងារបន្ថែមទៀតទៅដល់ប្រជាពលរដ្ឋ ដើម្បីបង្កើនប្រាក់ចំណូលឱ្យបានកាន់តែខ្ពស់ដែលអាចធ្វើឱ្យជីវភាពរស់នៅកាន់តែប្រសើរឡើង ព្រមទាំងកាត់បន្ថយបាននូវភាពក្រីក្រ ស្របទៅតាមគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។

## ២.៥. បញ្ហា មូលហេតុ និងដំណោះស្រាយ

ផ្អែកទៅតាមការរកឃើញ នៅក្នុងជំពូកទី១នៃរបាយការណ៍នេះ អាចឱ្យយើងធ្វើការវិភាគ និងចងក្រងបាននូវបញ្ហា ដែលកើតមាននៅក្នុងឃុំកំពង់ចិនជើង មូលហេតុដែលនាំឱ្យកើតមានបញ្ហា និងដំណោះស្រាយលើបញ្ហាទាំងអស់នេះ គឺត្រូវបានបង្ហាញនៅក្នុងតារាង និងនៅក្នុងផែនទី ដូចមាននៅខាងក្រោមនេះ៖

តារាង 36៖ បញ្ហាប្រឈម និងសក្តានុពល (ផ្អែកលើការវិភាគ បញ្ហា/មូលហេតុ/ដំណោះស្រាយ)

| បញ្ហា | ទីតាំងបញ្ហា | មូលហេតុនៃបញ្ហា | ដំណោះស្រាយ |
|---|---|---|---|
| ១.លំនៅឋានលើដីសាធារណៈរបស់រដ្ឋ (ស្ទឹងប្រឡាយ...) (៦៧គ្រួសារ) | គ្រប់ភូមិ | ក-កំណើនប្រជាជនក្នុងឃុំ | ក.១-ផ្សព្វផ្សាយច្បាប់ភូមិបាល<br>ក.ខ.២-ស្រង់ស្ថិតិប្រជាជននៅលើដីសារធារណៈរបស់រដ្ឋ |
| | | ខ-រស់នៅតាំងពីដូនតា<br>ក.គ-ខ្វះដីលំនៅឋាន | ខ.គ.១-បញ្ឈប់ការសាងសង់លំនៅឋានថ្មី នៅលើដីសារធារណៈរបស់<br>ខ.គ.២-មន្ទីរ ឬក្រសួង ពាក់ព័ន្ធ ដោះស្រាយដីសម្បទានសង្គមកិច្ច |
| ២.កង្វះខាតទីលានទុកដាក់សំរាម ក្នុងឃុំ  | ឃុំទាំងមូល | ក-គ្មានសណ្តាប់ធ្នាប់ មិនមានទីតាំងសមរម្យ | ក.១-យល់ដឹងពីការបែងចែកសំរាម (ប្រភេទសំរាមនីមួយ) |
| | | ខ-កង្វះខាតទីលានចាក់សំរាម(អត់មានដី)<br>គ-ចោលសំរាមលើដីសារធារណៈរបស់រដ្ឋ | ខ.គ.១-ជម្រុញឲ្យក្រុមហ៊ុនវិនិយោគ ក្នុងការប្រមូលសំរាមកែច្នៃ |

| បញ្ហា | ទីតាំងបញ្ហា | មូលហេតុនៃបញ្ហា | ដំណោះស្រាយ |
|---|---|---|---|
| ៣..ផ្លូវពិបាកធ្វើដំណើរចំពោះ ផ្លូវគ្រួសក្រហម   | -ភូមិនាងសល្មាច<br>-ភូមិត្រាច<br>-ភូមិចេក | ក-ផ្លូវខូច<br>ខ-ផ្លូវត្រូវទឹកហូរជាច់ | ក.ខ.១-ជួសជុលផ្លូវលំក្រាលគ្រួសក្រហម<br>ក.ខ.២-ក្រាលបេតុង ឬ កៅស៊ូ<br>ក.ខ.៣-ដាក់លូអមផ្លូវ |
| | | គ-គ្មានស្ពានឆ្លង | គ.១-ធ្វើស្ពានឆ្លង |
| ៤.ខ្វះដីកសិកម្ម)(២៤៦គ្រួសារ) | គ្រប់ភូមិ | ក-លក់សងបំណុល<br>ខ-កំណើនគ្រួសារក្នុងភូមិ | ក.ខ.១-ស្នើសុំដីសម្បទានសង្គមកិច្ច |
| | | គ-គ្មានដីកសិកម្ម<br>ឃ-ដីកសិកម្មតិច | គ.ឃ.១-ផ្តល់បច្ចេកទេសកសិកម្មទំនើបៗ |
| ៥.ខ្វះប្រភពទឹក និងធារាសាស្ត្រ | គ្រប់ភូមិ | ក-ខ្វះទឹកនៅរដូវប្រាំង<br>ខ-ខ្វះប្រព័ន្ធប្រឡាយ (មិនគ្រប់តាមតម្រូវការ) | ក.ខ.គ.១-សាងសង់ប្រព័ន្ធធារាសាស្ត្របន្ថែម<br>ក.២-ធ្វើទំនប់ស្ទាក់ទឹកស្ទឹងនាងសល្មាច<br>ក.៣-ធ្វើទំនប់ស្ទាក់ទឹកស្ទឹងស្ពោង(តំបន់ព្រៃតូច)<br>ខ.គ.១-ជួសជុលហេដ្ឋារចនាសម្ព័ន្ធធនធានទឹក |
| ៦.ទិន្នផលស្រូវទាប | គ្រប់ភូមិ | ក.ដីអត់រៀបស្មើ<br>ខ.ដីខ្សោះជីជាតិ<br>គ.កណ្តូល ខ្យងក្រហម | ក.១-កៀរដីឱ្យស្មើ<br>ខ.គ.ង.២-បណ្តុះបណ្តាលការប្រើប្រាស់ជីធម្មជាតិ និងថ្នាំសម្លាប់សត្វល្អិត |
| | | ឃ.ខ្វះពូជស្រូវល្អ | ឃ.១-ផ្តល់ពូជស្រូវដែលមានទិន្នផលខ្ពស់ |
| | | ង.ខ្វះប្រឡាយបញ្ចេញ បញ្ចូលទឹក | ង.១-ធ្វើទ្វារទឹក និងប្រឡាយថ្មី<br>ង.២-ស្តារប្រឡាយនិងធ្វើទ្វារទឹក |
| | | ច.ធ្វើស្រែតាមទម្លាប់ចាស់ | ច.១-បណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវ |
| ៧. បាត់បង់ព្រៃលិចទឹក  | ភូមិនាងសល្មាច | ក-កាប់រានយកដីធ្វើស្រែចម្ការ | ក.១-ផ្សព្វផ្សាយច្បាប់ព្រៃលិចទឹក |
| | | ខ-កាប់ខុសដុត | ខ.១-ដាំដើមឈើឡើងវិញ |
| ៨. បាត់បង់ធនធានជលផល | គ្រប់ភូមិ | ក-ប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់<br>ខ-ខ្វះជម្រកត្រីពង | ក.ខ.គ.ឃ.១-ផ្សព្វផ្សាយច្បាប់ជលផល |
| | | គ-កំណើនអ្នកនេសាទច្រើន | គ.១-បង្កើនការចិញ្ចឹមត្រីតាមគ្រួសារ |
| | | ឃ-នេសាទនៅរដូវត្រីពង | ឃ.១-ផ្សព្វផ្សាយបម្រាមនេសាទនៅរដូវត្រីពង |
| ៩. ខ្វះទឹកស្អាតប្រើប្រាស់ប្រាស់ | ១.ភូមិនាងសល្មាច<br>២.ភូមិត្រាច<br>៣.ភូមិរការ | ក-គ្មានទឹកស្អាតប្រើប្រាស់ | ក.១-តបណ្តាញទឹកស្អាត<br>ក.២-ធ្វើឧបករណ៍ចម្រោះទឹកឱ្យស្អាត |
| | | ខ-ប្រភពទឹកស្អាតនៅឆ្ងាយ | ខ.១-ធ្វើអាងស្តុកទឹក |
| | | គ-អណ្តូងភាគច្រើនមិនអាចប្រើបាន(ក្រហមជូរប្រៃ) | គ.១-ជីកអណ្តូងទឹកស្អាត |

ប្រភពទិន្នន័យៈ *របាយការណ៍គ្បេត្រ-បរិស្ថាន និងក្រុមប្រឹក្សាឃុំ កំពង់ចិនជើង ខែកញ្ញា ឆ្នាំ២០១៨*

ផែនទី 11៖ ផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ ឃុំកំពង់ចិនជើង



# ជំពូក ៣៖ ផែនការប្រើប្រាស់ដីសម្រាប់ពេលអនាគតឆ្នាំ២០១៧-២០៣២

## ៣.១. តម្រូវការ ស្ថានភាព និងសក្តានុពលដីជាក់ស្តែង

### ៣.១.១. តម្រូវការដីទៅតាមប្រភេទ

នៅពេលអនាគតរហូតដល់ឆ្នាំ២០៣២ នៅក្នុងឃុំកំពង់ចិនជើង នឹងមានការកើនឡើងចំនួនប្រជាពលរដ្ឋ ១៨ ១៦៩នាក់ ដែលត្រូវនឹងចំនួន ១ ១៥៥គ្រួសារ ។ ដោយសារសន្ទុះនៃកំណើនប្រជាពលរដ្ឋនេះហើយ ដែលតម្រូវឱ្យមានការគិតគូរយកចិត្តទុកដាក់ទៅដល់ការរកដីបន្ថែម សម្រាប់លំនៅឋាននិងដីស្រែជូនដល់ប្រជាពលរដ្ឋដែលមានចំនួនកើនឡើង ដើម្បីធានាឱ្យមាននិរន្តរភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំកំពង់ចិនជើង ទៅថ្ងៃអនាគតបន្តពីពេលបច្ចុប្បន្ន ដូចបានរកឃើញនៅក្នុងជំពូកទី២ខាងលើ នៃរបាយការណ៍នេះ។ តែដោយសារទំហំផ្ទៃដី ដែលត្រូវបានប្រើប្រាស់បច្ចុប្បន្នក្នុងឃុំកំពង់ចិនជើង ពុំមានប្រែប្រួលកើនឡើង ស្របគ្នាទៅនឹងកំណើនប្រជាពលរដ្ឋនាពេលអនាគតនោះ ជាដំណោះស្រាយ គឺសម្រាប់លំនៅឋាន ត្រូវប្រើប្រាស់ដីលំនៅឋានភូមិដែលមានស្រាប់ ពីព្រោះថាស្ថានភាពការតាំងលំនៅឋាន ក្នុងបច្ចុប្បន្ន មិនទាន់មានភាពចង្អៀតនោះទេ ដែលអាចមានលទ្ធភាពទ្រទ្រង់ដល់ការសាងសង់លំនៅឋានបន្ថែមទៀតបានសម្រាប់រយៈពេល១៥ឆ្នាំទៅមុខ ហើយម៉្យាងទៀតការតាំងលំនៅឋានមានលក្ខណៈប្រមូលផ្តុំវានឹងផ្តល់ភាពងាយស្រួលទៅដល់ការផ្គត់ផ្គង់ទឹកស្អាត ភ្លើង និងសេវាសង្គមផ្សេងៗទៀតដូចជាសេវាអប់រំ សេវាសុខភាពជាដើម។ល។

ដោយឡែកចំពោះដីស្រែវិញ ក៏មិនមានលទ្ធភាពពង្រីកបន្ថែមបានទៀតដែរ ជាដំណោះស្រាយ គឺត្រូវតែគិតគូរពិចារណាដោយយកចិត្តទុកដាក់ទៅលើការបង្កើនផលិតភាព គុណភាព និងពិពិធកម្មកសិកម្មដំណាំស្រូវ ដោយត្រូវធ្វើស្រែប្រាំងបង្កើនរដូវឱ្យបាន ០៣ដង/ឆ្នាំ និងធ្វើស្រែតាមបែបប្រពលវប្បកម្ម ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទនៃរាជរដ្ឋាភិបាលកម្ពុជា ។

### ៣.១.២. ស្ថានភាពនៃដីធ្លី និងសក្តានុពល

នៅពេលអនាគត ធនធានដីនៅក្នុងឃុំ នៅតែរក្សាទំហំក្រឡាផ្ទៃសរុប ៣ ៨៩៣,៣ហិកតា ហើយមានការប្រើប្រាស់សម្រាប់ លំនៅឋាន (រួមទាំងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន) ដីស្រែ(រួមទាំងប្រព័ន្ធធារាសាស្ត្រនឹងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន) ដីព្រៃគុម្ពោត និងឈើដុះរាយប៉ាយ ដីស្ទឹងមានទឹកតាមរដូវ ដីអាងស្តុកទឹក និងដីស្រះដូចទៅនឹងការប្រើប្រាស់ដីបច្ចុប្បន្នដដែល ដោយពុំមានការប្រែប្រួលឡើយ ព្រោះដីធ្លីដែលបានប្រើប្រាស់នៅក្នុងពេលបច្ចុប្បន្ននេះ គឺសមស្របនិងចំសក្តានុពលនៃដីរួចហើយ ។ ចំណែកទំហំផ្ទៃដីតំបន់និមួយៗ ដូចមានរៀបរាប់ក្នុងសេចក្តីអត្ថាធិប្បាយអំពីការបែងចែកដីតាមតម្រូវការប្រើប្រាស់ខាងក្រោមនេះ ។ ជាទូទៅធនធានដីនៅក្នុងឃុំកំពង់ចិនជើង មានសក្តានុពលខ្ពស់សមស្របទៅលើកសិកម្មដំណាំស្រូវ ដោយសារដីនៅក្នុងឃុំមានទីតាំងភូមិភូមិសាស្ត្រអំណោយផលពីធម្មជាតិ ដូចបានរៀបរាប់នៅក្នុងជំពូកទី២ ខាងលើ ។ ដូច្នេះ ការប្រើប្រាស់ដីនាពេលបច្ចុប្បន្ន និងការសម្រេចចិត្តប្រើប្រាស់ដីទៅថ្ងៃអនាគតនៅក្នុងឃុំ ដោយបានផ្តោតសំខាន់ទៅលើកសិកម្មដំណាំស្រូវជាចម្បង គឺជាការប្រើប្រាស់បានត្រឹមត្រូវចំសក្តានុពលនៃដីហើយក៏ជាការគាប់ជួន ដែលភាពអំណោយផលពីធនធានដីនៅក្នុងឃុំសមស្របទៅលើវិស័យកសិកម្មដំណាំស្រូវនេះក៏ស្របទៅនឹងគោលដៅដែលជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងតួនាទីវិស័យកសិកម្ម ក្នុងការបង្កើតការងារ ការធានាសន្តិសុខស្បៀងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍជនបទដែលមានចែងក្នុងមុំទី១ ចតុកោណទី៤ នៃយុទ្ធសាស្ត្រចតុកោណដំណាក់

កាលទី៤ មានការរបស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភាដែលជាការផ្តល់ឱកាសដ៏ល្អដល់អាចអភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួនឱ្យឃុំរីកចម្រើនបានតាមរយៈការជំរុញធ្វើពិពិធកម្មកសិកម្មដំណាំស្រូវ នៅលើផ្ទៃដីកសិកម្មដ៏ធំល្វឹងល្វើយស្ទើរតែពេញដែនដីឃុំទាំងមូល ដើម្បីបង្កើនទិន្នផលស្រូវដែលជាដំណាំដ៏មានសារៈសំខាន់ សម្រាប់ជាស្បៀងផ្គត់ផ្គង់ការហូបចុកមិនអាចខ្វះបាន និងការនាំចេញទៅលក់នៅទីផ្សារ ដើម្បីបានចំណូលផ្គត់ផ្គង់តម្រូវការចាំបាច់ក្នុងជីវភាពរស់នៅ របស់ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង រួមទាំងចូលរួមនៅក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ តាមរយៈសកម្មភាព ធ្វើពាណិជ្ជកម្មនាំអង្ករចេញរបស់រាជរដ្ឋាភិបាលកម្ពុជា ។

ចំណែកដី ដែលមានទំហំតិចតួច ដែលបានកំណត់ការប្រើប្រាស់ដីសម្រាប់សាងសង់លំនៅឋាននៅលើដីខ្ពស់ជាប់តាមដងផ្លូវសំខាន់ៗ និងនៅក្នុងទីប្រជុំជន ដែលមិនលិចទឹកនៅរដូវវស្សា បានផ្តល់ភាពងាយស្រួលក្នុងការធ្វើដំណើរចេញ-ចូល និងងាយស្រួលក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត សម្រាប់បម្រើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំបានប្រកបដោយផាសុកភាព ព្រមទាំងដីប្រើប្រាស់សម្រាប់ប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តគឺជាការប្រើប្រាស់បានត្រឹមត្រូវផងដែរ ។

## ៣.២. ការបែងចែកដីទៅតាមតម្រូវការប្រើប្រាស់

### ៣.២.១. ការវិភាគអន្តរអំពើរវាងតំបន់ផ្សេងៗ

ជាទូទៅរាល់ការកំណត់តំបន់ប្រើប្រាស់ដី ត្រូវបានផ្តោតសំខាន់ទៅលើមុខងារនៃការប្រើប្រាស់ដី សម្រាប់គោលបំណងផ្សេងៗមានដូចជា ផ្លូវ កសិកម្ម លំនៅឋាន ពាណិជ្ជកម្ម សួនកំសាន្ត ព្រៃឈើ ។ល។ ទន្ទឹមនឹងនោះការប្រើប្រាស់ដីតែងតែមានការផ្លាស់ប្តូរមុខងាររបស់វា តែការផ្លាស់ប្តូរមុខងារប្រើប្រាស់ដីទាំងនេះ ត្រូវតែមានការគិតគូរពិចារណាឱ្យបានហ្មត់ចត់ ដើម្បីធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវទៅតាមស្ថានភាពច្បាប់ សេដ្ឋកិច្ច សង្គម និង បរិស្ថាន ហើយត្រូវតែប្រាកដថា ដីដែលក្រោយពីបានប្តូរមុខងារប្រើប្រាស់ហើយនោះ ត្រូវមានតម្លៃសេដ្ឋកិច្ច ឬផលប្រយោជន៍ខ្ពស់ជាងមុខងារប្រើប្រាស់ពីមុនតាមរយៈការរក្សានូវជំហរច្បាស់លាស់នៅក្នុងការបង្កើនធនធានប្រើប្រាស់ប្រកបទៅដោយប្រសិទ្ធិភាព ជាមួយនឹងផលប៉ះពាល់ដ៏តិចតួចបំផុត ចំពោះមនុស្សនៅជំនាន់ក្រោយ ។ ឧទាហរណ៍៖ ដូចជា ការផ្លាស់ប្តូរពីដីព្រៃឈើរេចរិលទៅជាដីសម្រាប់កសិកម្ម ដែលវានឹងនាំឱ្យមានការបាត់បង់បរិមាណដីព្រៃឈើ ដែលផ្តល់ប្រយោជន៍ច្រើនយ៉ាងទៅដល់សហគមន៍មូលដ្ឋាន តែជំនួសមកវិញដោយវាលស្រែសម្រាប់ផលិតកម្មស្រូវ ដែលជាចំណីអាហារដ៏សំខាន់ សម្រាប់ជិវិតរស់នៅមិនអាចខ្វះបាន ទាំងនេះជាការបង្ហាញឱ្យឃើញអំពីអន្តរអំពើរវាងមុខងារប្រើប្រាស់ដីមួយ ជាមួយមុខងារប្រើប្រាស់ដីមួយផ្សេងទៀត ស្ថិតនៅលើទីតាំងដីដដែល ។

យ៉ាងណាមិញក្នុងរយៈពេល១៥ឆ្នាំខាងមុខ រហូតទៅដល់ឆ្នាំ២០៣២ សម្រាប់ការប្រើប្រាស់ដីនៅក្នុងឃុំកំពង់ចិនជើង គឺត្រូវបានធ្វើការគិតគូរយ៉ាងយកចិត្តទុកដាក់ ដើម្បីដោះស្រាយ និងឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋ ដូចដែលបានរៀបរាប់ខាងលើ ជាពិសេសនោះ គឺការដោះស្រាយការបែងចែកការប្រើប្រាស់ដីថ្មីដើម្បីបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ តាមគោលការណ៍របស់រាជរដ្ឋាភិបាល និងដោយឈរលើស្មារតីនៅក្នុងការកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានសម្រាប់ការប្រើប្រាស់ដីថ្មីនៅក្នុងឃុំ ។ បញ្ហាដែលត្រូវ ដោះស្រាយខាងលើនេះ យើងសង្កេតឃើញថា មានការដោះស្រាយដី សម្រាប់តែការពង្រីកប្រព័ន្ធស្រោចស្រពប៉ុណ្ណោះ ហើយការដោះស្រាយនេះត្រូវបានសម្រេចចិត្តកំណត់យកទៅលើដីស្រែទៅតាមទីតាំងដែលសមស្របអាចមានលទ្ធភាពនាំ

ទឹកទៅស្រោចស្រព លើផ្ទៃដីស្រែបានគ្រប់គ្រាន់ ដែលនឹងនាំឱ្យមានការប្រែប្រួលពីបរិមាណផ្ទៃដីស្រែមួយភាគតូច ទៅជាដីសម្រាប់ការរៀបចំធ្វើប្រព័ន្ធប្រឡាយស្រោចស្រព គឺមានន័យថា៖ មានការថយចុះផ្ទៃដីស្រែ ដែលជាមូលដ្ឋានដ៏រឹងមាំនៃការអភិវឌ្ឍន៍ឃុំកំពង់ចិនជើង ធ្វើឱ្យមានការថយចុះផលិតផលស្រូវ ដែលនឹងនាំឱ្យមានការបាត់បង់ប្រាក់ចំណូល ប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ តែបរិមាណផ្ទៃដីសម្រាប់ប្រព័ន្ធស្រោចស្រពមានការកើនឡើងដែលជាតម្រូវការចាំបាច់សម្រាប់ការដោះស្រាយនៅក្នុងការស្រោចស្រពដំណាំកសិកម្មមិនអាចខ្វះបាន ដើម្បីធានាចីរភាពនៃផលិតកម្មកសិកម្មសម្រាប់ការអភិវឌ្ឍន៍ឃុំ ។

តារាង 37៖ ការប្រើប្រាស់ដីនាពេលអនាគត

| ប្រភេទដីប្រើប្រាស់ | ផ្ទៃដីបច្ចុប្បន្ន (ហិកតា) | ផ្ទៃដី១៥ឆ្នាំក្រោយ (ហិកតា) | បម្រែបម្រួល (ហិកតា) |
|---|---|---|---|
| **ក.ដីលំនៅឋាន ភូមិ** | **២៣៣,៩៣** | **២៣៣,៩៣** | **0** |
| -ដីលំនៅឋានក្នុងភូមិក្រៅតំបន់ជុំវិញបឹងទន្លេសាប | ៩៣,៩៣ | ៩៣,៩៣ | 0 |
| -ដីលំនៅឋានក្នុងភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ១៤០ | ១៤០ | 0 |
| **ខ.កន្លែងកប់ខ្មោច** | **0,៧0** | **0,៧0** | **0** |
| **គ.ដីស្រែវស្សា** | **២ ៣២៩,២** | **២ ៣២៩,២** | **0** |
| -ដីស្រែវស្សាក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប | ២១៩,៦ | ២១៩,៦ | 0 |
| -ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ១៩00 | ១៩00 | 0 |
| -ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ២១0 | ២១0 | 0 |
| **ឃ. ដីស្រែប្រាំងនិង ស្រែវស្សា** | **៩១៤,១៧** | **៩១៤,១៧** | **0** |
| -ដីស្រែប្រាំងនិង ស្រែវស្សាតំបន់១ជុំវិញបឹងទន្លេសាប | ៣0៤,១៧ | ៣0៤,១៧ | 0 |
| -ដីស្រែប្រាំងនិង ស្រែវស្សាតំបន់២ជុំវិញបឹងទន្លេសាប | ៦១0 | ៦១0 | 0 |
| **ង. ដីចម្ការ** | **១៤៧,៩៩** | **១៤៧,៩៩** | **0** |
| -ដីចម្ការក្រៅតំបន់ជុំវិញបឹងទន្លេសាប | ២៧,៤ | ២៧,៤ | 0 |
| -ដីចម្ការក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ១២0 | ១២0 | 0 |
| **ច. ព្រៃគុម្ពោត និងឈើដុះរាយប៉ាយ** | **២៤,១៣** | **២៤,១៣** | **0** |
| **ឆ. ព្រៃតាមដងស្ទឹង** | **៦៣,១៥** | **៦៣,១៥** | **0** |
| **ជ. ស្ទឹងមានទឹកតាមរដូវ** | **១១៥,៧៥** | **១១៥,៧៥** | **0** |
| **ឈ. អាងស្តុកទឹក** | **៤៩,៧៩** | **៤៩,៧៩** | **0** |
| **ញ. ស្រះ** | **១៤,៧៨** | **១៤,៧៨** | **0** |
| **ផ្ទៃដីឃុំសរុប** | **៣ ៨៩៣,៣** | **៣ ៨៩៣,៣** | **0** |

តារាង 38៖ តារាងផែនការផ្នែកហេដ្ឋារចនាសម្ព័ន្ធនាពេលអនាគត

| ប្រភេទហេដ្ឋារចនាសម្ព័ន្ធ | ប្រវែងផ្លូវឆ្នាំ២០១៧ (ម៉ែត្រ) | ប្រវែងផ្លូវឆ្នាំ២០៣២ (ម៉ែត្រ) | បម្រែបម្រួល (ម៉ែត្រ) |
|---|---|---|---|
| ផ្លូវក្រាលកៅស៊ូ | ៨ ៨៧២,៨៤ | ១៣ ៧២៩,៨២ | ៤៨ ៥៦,៩៨ |
| ផ្លូវក្រាលគ្រួសក្រហម | ១៩ ៨៩៧,២១ | ៤១ ៩៣៧,៩៦ | ២២ ០៤០,៧៥ |
| ផ្លូវលំដីស/ផ្លូវរទេះ | ៣៧ ६៤៦,៩៤ | ៤០ ៩០១,៥៨ | ៣ ២៥៤,६៤ |
| ប្រឡាយមេ | ៦ ០៣៣,៥៤ | ៦ ០៣៣,៥៤ | ០០ |
| ប្រឡាយរង | ១ ១៨៦,២៨ | ១ ១៨៦,២៨ | ០០ |
| ប្រឡាយតូច | ២៦ ៧១០,៦០ | ២៦ ៧១០,៦០ | ០០ |

តារាង 39៖ តារាងផែនការផ្នែកសេវាកម្មនាពេលអនាគត

| ហេដ្ឋារចនាសម្ព័ន្ធ | ចំនួនក្នុងឆ្នាំ២០១៧ | ចំនួនសម្រាប់១៥ឆ្នាំក្រោយ | បម្រែបម្រួល |
|---|---|---|---|
| សាលាមតេយ្យ | ០៤ អគារ/៤បន្ទប់ | ០៨អគារ/៤២បន្ទប់ | ០៦ អគារ/៣៨បន្ទប់ |
| សាលាបឋមសិក្សា | ០១ អគារ/៥បន្ទប់ | ០៧ អគារ/៤៤បន្ទប់ | ០៦ អគារ/៣៩បន្ទប់ |
| សាលាអនុវិទ្យាល័យ | ០១ អគារ/៥បន្ទប់ | ០២ អគារ/២១បន្ទប់ | ០១ អគារ/១៦បន្ទប់ |
| សាលាវិទ្យាល័យ | ០០ អគារ/០០បន្ទប់ | ០២ អគារ/២១បន្ទប់ | ០២ អគារ/២១បន្ទប់ |
| មណ្ឌលសុខភាព | ០០កន្លែង | ០១កន្លែង | ០១កន្លែង |

### ៣.២.២. ផែនទីប្រើប្រាស់ដីអនាគត

ការកំណត់ការប្រើប្រាស់ដីនាពេលអនាគតនៅក្នុងឃុំ គឺជាការសម្រេចចិត្តមួយដ៏ត្រឹមត្រូវបំផុតដោយពឹងផ្អែកទាំងស្រុងទៅលើការវិភាគដីសមស្របមួយ តាមរយៈការវាយតម្លៃបែបសាមញ្ញទៅលើធនធានដី រយៈកម្ពស់ទីជម្រាល ធនធានទឹក ការកាន់កាប់ដី និងសក្តានុពលនៃការប្រើប្រាស់ដីនៅក្នុងឃុំនេះ នាពេលបច្ចុប្បន្ន ដោយយកផែនទីប្រើប្រាស់ដីធ្លីបច្ចុប្បន្នធ្វើជាមូលដ្ឋានក្នុងការគិតពិចារណា ដូចមានរំលេចឱ្យឃើញនៅក្នុងតារាងទី៣៧ ខាងលើនេះ ដោយមានភ្ជាប់នូវផែនទីប្រើប្រាស់ដីនាពេលអនាគតមួយដូចខាងក្រោម ដែលសមស្របអាចទទួលយកបាននិងអាចប្រើប្រាស់មានប្រសិទ្ធិភាព តាមរយៈការបង្ហាញយ៉ាងពិស្តារពីជម្រើសដ៏ល្អសម្រាប់ការប្រើប្រាស់ដីនាពេលអនាគតរបស់ឃុំនេះ។ចំណែកនៅខាងក្រោមផែនទីប្រើប្រាស់ដីនាពេលអនាគត ក៏មានការអត្ថាធិប្បាយលម្អិតទៅលើតំបន់ប្រើប្រាស់ដីនីមួយៗដែលបានកំណត់នៅលើផែនទីនេះផងដែរ ។

ផែនទី 12៖ ផែនទីប្រើប្រាស់ដីពេលអនាគត ឃុំកំពង់ចិនជើង



### ៣.២.៣. សេចក្តីអត្ថាធិប្បាយអំពីការប្រើប្រាស់ដីនាពេលអនាគត

បើផ្អែកតាមផែនទីប្រើប្រាស់ដីអនាគតខាងលើ បានបង្ហាញឱ្យឃើញពីប្រភេទនៃការប្រើប្រាស់ដីនៅក្នុងឃុំកំពង់ចិនជើងមានដូចខាងក្រោម៖

#### ក. ដីលំនៅឋាន ភូមិ

ដីលំនៅឋាន ភូមិ គឺជាដីត្រូវបានប្រើប្រាស់សម្រាប់លំនៅឋានមានលាយសួនដំណាំ និងឈើហូបផ្លែ។ នៅពេលអនាគត ក្នុងឃុំកំពង់ចិនជើង ដីលំនៅឋានភូមិភាគច្រើនស្ថិតនៅសងខាងតាមបណ្តោយផ្លូវជាតិលេខ៦ និងផ្លូវគ្រួសក្រហម ដែលដីលំនៅឋាន ភូមិស្ថិតនៅខាងកើតផ្លូវជាតិលេខ៦ មានចំនួន២ភូមិ គឺភូមិត្នោត និងភូមិត្រាច មានផ្ទៃដីទំហំ ៩៣,៩៣ហិកតា គឺជាដីស្ថិតនៅក្រៅតំបន់ជុំវិញបឹងទន្លេសាប និងដីលំនៅឋាន ភូមិ ដែលបែកចេញពីផ្លូវជាតិលេខ៦ ផ្នែកខាងត្បូង ទៅភាគខាងលិចនៃឃុំមានចំនួនបីភូមិ គឺភូមិរកា ភូមិចេក និងភូមិចក ព្រមទាំងផ្លូវគ្រួសក្រហមមួយទៀតកាត់កណ្តាលភូមិ ឆ្ពោះទៅភាគលិចឆៀងខាងជើង ដែលមានភូមិនាងសល្ងាចតែមួយភូមិ មានផ្ទៃដីទំហំ ១៤០ ហិកតា គឺជាដីលំនៅឋាន ភូមិដែលស្ថិតក្នុងតំបន់១ជុំវិញបឹងទន្លេសាប ។ ដីលំនៅឋាន ភូមិ មានទំហំផ្ទៃដីសរុបចំនួន ២៣៣,៩៣ ហិកតា ដែលបច្ចុប្បន្នដីនេះ ត្រូវបានប្រើប្រាស់សម្រាប់ដីលំនៅឋានភូមិ ដោយពុំមានការពង្រីកបន្ថែម សម្រាប់ដោះស្រាយនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ២០៣២ នោះឡើយ ដោយសារបច្ចុប្បន្ននេះ ដីលំនៅឋានភូមិនៅមានភាពទូលាយ ដែលត្រូវបានប្រើប្រាស់ទំហំដីប្រមាណ ០,១៥ ហិកតា ក្នុងមួយគ្រួសារ ដែលអាចធ្វើការដោះស្រាយ សម្រាប់សាងសង់លំនៅឋានរហូតដល់ឆ្នាំ ២០៣២ បាន ដែលនឹងត្រូវប្រើប្រាស់ទំហំដីថយចុះតិចតួចនៅសល់ប្រមាណជា ០,០៩ ហិកតា ក្នុងមួយគ្រួសារ ។ ដីលំនៅឋានភូមិ ជាតំបន់ជម្រាលធម្យម និងមានកន្លែងខ្លះខ្ពស់មិនលិចទឹកនៅរដូវវស្សា (លើកលែងតែភូមិនាងសល្ងាច លិចទឹកនៅរដូវវស្សាជានិច្ច) មានប្រភេទដីកណ្តេងតដ្ឋ(ពណ៌លឿងភ្លាវ) ។ ដីលំនៅឋាន ភូមិទាំងនេះ ពឹងផ្អែកលើប្រភពទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ និងស្រោចស្រពដំណាំរួមផ្សំជុំវិញលំនៅឋាន បានមកពីស្ទឹងស្ទោងនិងស្ទឹងនាងសល្ងាច ទឹកភ្លៀង ទឹកអណ្តូងស្នប់ និងទឹកស្រះ ហើយត្រូវនាំទឹកមកប្រើប្រាស់ដោយម៉ូទ័របូម និងស្នប់សប់ដៃ ។ នាពេលអនាគតទីតាំងដីលំនៅឋាន ដែលមានស្រាប់នាពេលបច្ចុប្បន្ននេះ នឹងត្រូវរក្សាទុកជាដីសម្រាប់សាងសង់លំនៅឋានដដែល ដោយសារតែទីតាំងដីនេះមានស្ថានភាពជាដីខ្ពស់មិនលិចទឹកនៅរដូវវស្សា និងនៅជាប់ផ្លូវសំខាន់ៗនៅក្នុងឃុំ ធ្វើឱ្យងាយស្រួលក្នុងការចេញចូលប្រកបរបររកស៊ីរបស់ប្រជាពលរដ្ឋ ដែលសមស្របសម្រាប់ការតាំងលំនៅឋាន និងជាជម្រកដ៏កក់ក្តៅសម្រាប់ជិវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ។ ដីលំនៅឋាន ភូមិ នៅពេលអនាគត មានទីតាំងស្ថិតនៅតាមបីតំបន់ផ្សេងគ្នាដូចខាងក្រោម៖

**-ដីលំនៅឋាន ភូមិនៅក្រៅតំបន់ការពាជុំវិញបឹងទន្លេសាប**

ដីលំនៅឋាន ភូមិស្ថិតនៅក្រៅតំបន់ការពារជុំវិញបឹងទន្លេសាបមានផ្ទៃដីចំនួន ៩៣,៩៣ ហិកតា ស្ថិតនៅខាងកើតផ្លូវជាតិលេខ៦ មានពីរភូមិ គឺភូមិត្នោត និងភូមិត្រាច ។ ដីលំនៅឋាន ភូមិស្ថិតនៅក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប ជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់និងចាត់ចែងប្រើប្រាស់ដោយប្រជាពលរដ្ឋ ។

**-ដីលំនៅឋាន ភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

ដីលំនៅឋានភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាបមានផ្ទៃដីចំនួន ១៤០ហិកតា ស្ថិតនៅខាងលិចផ្លូវជាតិលេខ៦ មាន ០៤ភូមិ គឺភូមិរកា ភូមិចេក ភូមិចក និងភូមិនាងសល្ងាច ។ ដីលំនៅឋាន ភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាប ជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់និងចាត់ចែងប្រើប្រាស់ដោយប្រជាពលរដ្ឋ ។

### ខ. ដីកប់ខ្មោច

នាពេលអនាគត ឃុំកំពង់ចិនជើង មានដីកប់ខ្មោចចំនួន ០២កន្លែង មានផ្ទៃដីទំហំ ០,៧០ ហិកតា ស្ថិតនៅសងខាងផ្លូវគ្រួសក្រហមកាត់ចំកណ្ដាលឃុំ ដែលចេញពីផ្លូវជាតិលេខ៦ ទៅភូមិនាងសល្វាច ក្នុងដីតំបន់១ជុំវិញបឹងទន្លេសាប ក្នុងនោះមាន ០១កន្លែង ស្ថិតនៅខាងជើងផ្លូវគ្រួសក្រហម មានផ្ទៃដីទំហំ ០,១០ហិកតា និង មួយកន្លែងទៀតស្ថិតនៅខាងត្បូងផ្លូវគ្រួសក្រហម មានផ្ទៃដីទំហំ ០,៦០ ហិកតា ដែលបច្ចុប្បន្នត្រូវបានប្រើប្រាស់ជាដីកប់ខ្មោចដោយពុំមានការពង្រីកបន្ថែមសម្រាប់ការដោះស្រាយរហូតដល់ឆ្នាំ ២០៣២ នោះឡើយ ។ នាពេលអនាគត ទីតាំងដីកប់ខ្មោច ដែលមានស្រាប់នាពេលបច្ចុប្បន្ននេះ នឹងត្រូវរក្សាទុកជាដីសម្រាប់កប់ខ្មោចដដែល ដោយសារតែទីតាំងដីនេះ ជាដីសហគមន៍ ដែលគ្រប់គ្រងដោយរដ្ឋបាលឃុំ ហើយត្រូវបានប្រជាពលរដ្ឋនៅក្នុងឃុំប្រើប្រាស់ទុកជាកន្លែងបញ្ចុះសពតាំងពីយូរយារណាស់មកហើយ ។

### គ. ដីស្រែវស្សា

នៅក្នុងឃុំកំពង់ចិនជើង ដីស្រែវស្សាមានវិសាលភាពគ្របដណ្ដប់ស្ទើរតែពេញផ្ទៃដីឃុំ នៅពេលអនាគតភាគច្រើនមានលើសលប់ស្ថិតនៅប៉ែកខាងលិចផ្លូវជាតិលេខ៦ និងមានតិចតួចនៅប៉ែកខាងកើតផ្លូវជាតិលេខ៦ និងមានផ្ទៃដីសរុបចំនួន ២៣២៩,២ហិកតា ដែលបច្ចុប្បន្ននេះត្រូវបានប្រើប្រាស់ជាដីស្រែវស្សា ដោយពុំមានការពង្រីកបន្ថែមសម្រាប់ការដោះស្រាយទៅនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ២០៣២ នោះឡើយ ។ ដីដែលបានកំណត់ជាដីស្រែវស្សាទាំងអស់ខាងលើ ជាដីទំនាបមធ្យមរាបស្មើ និងទំនាបលិចនៅរដូវវស្សា (លិចទឹករយៈពេលខ្លី) ស្ថិតក្នុងតំបន់២ មានប្រភេទដីល្បាយខ្សាច់ (ក្រហមភ្លាវ និងកណ្ដេងល្បាប់លិចទឹកភ្លៀងពណ៌ទង់ដែង) ដីស្រែវស្សាតំបន់១ជុំវិញបឹងទន្លេសាប ជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់ដោយប្រជាពលរដ្ឋ លើលែងតែដីស្រែវស្សាតំបន់២ ជុំវិញបឹងទន្លេសាប ជាសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋមានសិទ្ធិត្រឹមតែអាស្រ័យផលប៉ុណ្ណោះ ។ ដីស្រែវស្សាទាំងនេះ ពឹងផ្អែកលើប្រភពមកពីទឹកជំនន់ទន្លេសាប ពីស្ទឹងសល្វាច ស្ទឹងគោល អាងស្តុកទឹកឯកជនសុង អាងស្តុកទឹកឯកជនចាន់ សីហា អាងស្តុកទឹកឯកជនអាន អាងស្តុកទឹកឯកជន សាយ គឹមឡម អាងស្តុកទឹកឯកជន គក រិត និងប្រឡាយចាស់ៗ ប្រភពទាំងនេះត្រូវប្រើប្រាស់មធ្យោបាយបូមដូចជាម៉ាស៊ីនបូមទឹក ដើម្បីនាំទឹកមកស្រោចស្រពក្នុងស្រែវស្សា ។ នាពេលអនាគតទីតាំងដីនេះ នឹងត្រូវរក្សាទុកជាដីស្រែដូចបច្ចុប្បន្នដដែល ដោយសារទីតាំងដីនេះមានស្ថានភាពជាដីទាបលិចទឹកនៅរដូវវស្សា សមស្របសម្រាប់ដំណាំ ស្រូវសម្រាប់ផ្គត់ផ្គង់ការហូបចុកសម្រាប់ជីវិតរស់របស់មនុស្ស និងនៅសល់លក់ទៅទីផ្សារក្នុងនិងក្រៅដើម្បីបង្កើនប្រាក់ចំណូលជាតិ និងគ្រួសារ ។ ដីស្រែវស្សា នៅពេលអនាគតមានទីតាំងស្ថិតនៅតាមតំបន់នីមួយៗដូចខាងក្រោម ៖

**-ដីស្រែវស្សាក្រៅតំបន់ការពាជុំវិញបឹងទន្លេសាប**

ដីស្រែវស្សាក្រៅតំបន់ការពាជុំវិញបឹងទន្លេសាប មានផ្ទៃដីចំនួន ២១៩,៦ហិកតា ស្ថិតនៅខាងកើតផ្លូវជាតិលេខ៦ ។ ដីស្រែវស្សាក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប គឺជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់និងចាត់ចែងប្រើប្រាស់ដោយប្រជាពលរដ្ឋ។

**-ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាបមានផ្ទៃដីចំនួន ១ ៩០០ ហិកតា ស្ថិតនៅខាងលិចផ្លូវជាតិលេខ៦ ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប ជាដីកម្មសិទ្ធិឯកជនត្រូវបានកាន់កាប់និងប្រើប្រាស់ដោយប្រជាពលរដ្ឋ ។

**-ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានផ្ទៃដីចំនួន ២១០ ហិកតា ស្ថិតនៅខាងលិចផ្លូវជាតិលេខ៦ បន្តជាប់ពីដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប ។ ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងលក់ដូរបានឡើយ ។

## ឃ. ដីស្រែប្រាំង និងស្រែវស្សា

ដីស្រែប្រាំងនិងស្រែវស្សា នៅក្នុងឃុំកំពង់ចិនជើង នាពេលអនាគត ស្ថិតនៅភាគខាងលិចនៃឃុំជាប់ស្ទឹងនាងសល្វាច មានផ្ទៃដីទំហំ ៩១៤,១៧ហិកតា ដែលបច្ចុប្បន្នត្រូវបានប្រើប្រាស់ជាដីស្រែប្រាំង និងស្រែវស្សា ដោយពុំមានការពង្រីកបន្ថែម សម្រាប់ការដោះស្រាយទៅនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ២០៣២នោះឡើយ ។ ដីស្រែប្រាំងនិងស្រែវស្សាទាំងនេះ ជាតំបន់ទំនាបមធ្យម និងទំនាបលិចទឹកនៅតាមរដូវ មានប្រភេទដីល្បាយខ្សាច់(ក្រហមភ្លាវ និងដីកណ្តេងល្បាប់លិចទឹកភ្លៀងពណ៌ទង់ដែង) ដែលបានប្រភពមកពីទឹកជំនន់ទន្លេសាប ពីស្ទឹងនាងសល្វាច និងអាងស្តុកទឹកមួយចំនួន ដោយប្រើប្រាស់ម៉ាស៊ីនបូមទឹក ដើម្បីនាំទឹកមកស្រោចស្រពក្នុងស្រែ។ នាពេលអនាគត ទីតាំងដីនេះនឹងត្រូវរក្សាទុកជាដីស្រែដូចបច្ចុប្បន្នដដែល ដោយសារតែទីតាំងដីនេះមានស្ថានភាពជាដីទាបលិចទឹកតាមរដូវ សមស្របសម្រាប់ដំណាំស្រូវផ្តល់ផលិតផលផ្គត់ផ្គង់ដល់ការបរិភោគសម្រាប់ជីវិតរស់របស់មនុស្ស និងនៅសល់លក់ទៅទីផ្សារក្នុង និងក្រៅស្រុកដើម្បីបង្កើនប្រាក់ចំណូលជាតិ និងគ្រួសារ ។ ដីស្រែប្រាំងនិងស្រែវស្សា នៅពេលអនាគតមានទីតាំងស្ថិតនៅតាមពីរតំបន់ផ្សេងគ្នាដូចខាងក្រោមៈ

**-ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំង និងស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាបមានផ្ទៃដីចំនួន ៣០៤,១៧ហិកតា ស្ថិតនៅខាងលិចផ្លូវជាតិលេខ៦ ។ ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប ជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់ និងចាត់ចែងប្រើប្រាស់ដោយប្រជាពលរដ្ឋ។

**-ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានផ្ទៃដីចំនួន ៦១០ហិកតា ស្ថិតនៅខាងលិចផ្លូវជាតិលេខ៦បន្តជាប់ពីដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប។ ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងលក់ដូរបានឡើយ ។

## ង. ដីចម្ការ

ដីចម្ការនៅក្នុងឃុំកំពង់ចិនជើង នាពេលអនាគត ភាគច្រើនស្ថិតនៅខាងត្បូងផ្លូវជាតិលេខ៦ និងមានតិចតួចស្ថិតនៅខាងជើងផ្លូវជាតិលេខ ៦ ដែលមានផ្ទៃដីទំហំ ១៤៧,៩៩ ហិកតា ជាដីកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋ ។ បច្ចុប្បន្ននេះត្រូវបានប្រើប្រាស់ជាដីចម្ការស្រោចស្រព ដោយពុំមានការពង្រីកបន្ថែមសម្រាប់ការដោះស្រាយទៅនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ២០៣២នោះឡើយ។ ដីចម្ការទាំងនេះជាតំបន់ទំនាប មានស្ថានភាពជាដីមិនរាបស្មើ មានប្រភេទដីកណ្តេងឥដ្ឋ(ពណ៌លឿងភ្លាវ) និងពឹងផ្អែកលើទឹកភ្លៀង ស្ទឹងស្ទោង និងស្ទឹងគោលសម្រាប់ការស្រោចស្រព ដោយប្រើប្រាស់ម៉ូទ័របូម។ នាពេលអនាគត ទីតាំងដីនេះនឹងត្រូវរក្សាទុកជាដីចម្ការដដែល ដោយសារតែមាន

ស្ថានភាពជាដីខ្ពស់ និងមិនលិចទឹកនៅរដូវវស្សា សមស្របសម្រាប់ដំណាំរួមផ្សំនិងដំណាំឧស្សាហកម្ម និងដំណាំឈើហូបផ្លែដែលអាចលក់ទៅទីផ្សារក្នុងនិងក្រៅប្រទេស ដើម្បីបង្កើនប្រាក់ចំណូលជួយជីវភាពក្នុងគ្រួសារ។ ដីចម្ការនេះ នៅពេលអនាគតមានទីតាំងស្ថិតនៅពីរតំបន់ផ្សេងពីគ្នា៖

**-ដីចម្ការក្រៅតំបន់ជុំវិញបឹងទន្លេសាប**

ដីចម្ការក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប មានផ្ទៃដីទំហំ ២៧,៤ ហិកតា ស្ថិតនៅខាងជើងផ្លូវជាតិលេខ៦ ដីចម្ការក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប គឺជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់និងចាត់ចែងប្រើប្រាស់ដោយប្រជាពលរដ្ឋ ។

**-ដីចម្ការក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

ដីចម្ការក្នុងតំបន់១ជុំវិញបឹងទន្លេសាប មានផ្ទៃដីទំហំ ១២០ហិកតាស្ថិតនៅខាងត្បូងផ្លូវជាតិលេខ៦នៅតាមបណ្ដោយស្ទឹងនាងសល្ងាច ។ ដីចម្ការក្នុងតំបន់១ជុំវិញបឹងទន្លេសាប ជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់និងចាត់ចែងប្រើប្រាស់ដោយប្រជាពលរដ្ឋ ។

### ច. ព្រៃគម្ពោត និងឈើដុះរាយប៉ាយ

នៅក្នុងឃុំកំពង់ចិនជើង នៅពេលអនាគត មានព្រៃគុម្ពោតនិងដើមឈើដុះរាយប៉ាយចំនួន ២៤,១៣ហិកតា ស្ថិតនៅក្បែរផ្លូវគ្រួសក្រហម និងជាប់ស្ទឹងនាងសល្ងាច ។ ដីព្រៃនេះ គឺជាដីសាធារណៈរបស់រដ្ឋ នៅពេលអនាគត ដីព្រៃគុម្ពោត និងឈើដុះរាយប៉ាយនេះ នៅតែរក្សាជាដីព្រៃគុម្ពោតដដែល ដោយសារតែព្រៃនេះ មានប្រយោជន៍ច្រើនយ៉ាងរបស់ប្រជាពលរដ្ឋ និងត្រូវធ្វើការការពារនិងថែរក្សាបន្ថែមទៀត សម្រាប់ជួយក្នុងកិច្ចការបរិស្ថាននៅក្នុងឃុំឱ្យមានភាពបៃតង ។

### ឆ. ព្រៃតាមដងស្ទឹង

ព្រៃតាមដងស្ទឹងនៅក្នុងឃុំកំពង់ចិនជើង នាពេលអនាគត មាននៅតាមដងស្ទឹងស្ទោង និងស្ទឹងនាងសល្ងាច មានផ្ទៃដីសរុបទំហំ ៦៣,១៥ហិកតា ស្ថិតនៅតាមបណ្ដោយព្រំប្រទល់សងខាងឃុំ ក្នុងនោះព្រៃតាមដងស្ទឹងស្ទោង មានផ្ទៃដីទំហំ ៤,១៩ ហិកតា ស្ថិតនៅភាគខាងកើតឃុំជាប់ព្រំប្រទល់ឃុំកំពង់ចិនត្បូង និងឃុំទ្រា ចំណែកព្រៃតាមដងស្ទឹងនាងសល្ងាច មានផ្ទៃដីទំហំ ៥៨,៨៨ហិកតា ស្ថិតនៅភាគខាងលិចឆៀងខាងជើងជាប់ព្រំប្រទល់ឃុំប្រឡាយ ដែលបច្ចុប្បន្នត្រូវបានប្រើប្រាស់ជាដីព្រៃតាមដងស្ទឹងដោយពុំមានការកែប្រែអ្វីឡើយ ដែលសម្បូរទៅដោយដើមឈើចម្រុះដូចជាដើមភ្នំភ្លើង ត្រស់ កប្បាសព្រៃ ស្មាច់ និងដើមរាំងជាដើម ។ល ។ តំបន់នេះ គឺជាដីសាធារណៈរបស់រដ្ឋ មានស្ថានភាពជាដីខ្ពស់តាមមាត់ស្ទឹង មានប្រភេទដីល្បាប់ ដីកណ្ដោង ដីពពាយកណ្ដុរ និងដីឥដ្ឋ ។ នាពេលអនាគត តំបន់នេះនឹងត្រូវរក្សាទុកជាដីព្រៃតាមដងស្ទឹងដដែលដើម្បីជាប្រយោជន៍ក្នុងការជួយការពារការហូរច្រោះបាក់ដីមាត់ស្ទឹង ជាជម្រកត្រីពងកូន ផ្ដល់ឈើសម្រាប់ប្រើប្រាស់ផ្សេងៗ ធ្វើឱ្យដីនៅក្នុងតំបន់នោះមានជីជាតិ ជួយផ្ដល់ឧស្ម័នអុកស៊ីសែនទៅដល់មនុស្សនិងស្រូបយកឧស្ម័នកាបូនិក ជាជម្រកសត្វព្រៃ ផ្ដល់ខ្យល់អាកាសបរិសុទ្ធ ជួយទប់ទល់ខ្យល់ព្យុះនិងទឹកជំនន់ ជួយទាក់ទាញទឹកភ្លៀង ជួយរក្សាលំនឹងអាកាសធាតុ ។ល។

### ជ. ស្ទឹងមានទឹកតាមរដូវ

ស្ទឹងមានទឹកតាមរដូវ ក្នុងឃុំកំពង់ចិនជើង នៅពេលអនាគត មានស្ទឹងស្ទោង និងស្ទឹងនាងសល្ងាច ដែលជាប្រភពទឹកស្រោចស្រពយ៉ាងសំខាន់នៅក្នុងឃុំ ហើយសម្បូរទៅដោយមច្ឆជាតិជាច្រើន ដែលមានទំហំផ្ទៃដីចំនួន

១០៦,៩៨ហិកតា ជាដីសាធារណៈរបស់រដ្ឋ ជាប្រភពទឹកដ៏សំខាន់សម្រាប់ស្រោចស្រពដំណាំស្រូវនិងដំណាំផ្សេងៗទៀតរបស់ប្រជាពលរដ្ឋក្នុងឃុំ ព្រមទាំងជាប្រភពធនធានជលផលផងដែរ ។ ស្ទឹងទាំងនេះ ហូរកាត់តាមព្រំប្រទល់រវាងឃុំកំពង់ចិនត្បូង និងឃុំប្រឡាយ ពីជើងទៅត្បូងចាក់ចូលទៅបឹងទន្លេសាប ។ នាពេលអនាគតស្ទឹងទាំងពីរនេះ ជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់នៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានជលផលសម្រាប់ជាអាហារ ផ្តល់ប្រូតេអ៊ីនជាប្រយោជន៍យ៉ាងសំខាន់ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ។

**ឈ. អាងស្តុកទឹក**

ដីអាងស្តុកទឹកនៅក្នុងឃុំកំពង់ចិនជើង នាពេលអនាគត មានចំនួន ០៤អាងធំៗ មានទំហំផ្ទៃដីសរុបចំនួន ៤៩,៧៩ ហិកតា ស្ថិតនៅភាគខាងត្បូងឃុំ នៅក្នុងតំបន់ស្រែប្រាំងនិងស្រែវស្សា ត្រូវបានប្រើប្រាស់ជាអាងស្តុកទឹកសម្រាប់ជាប្រភពទឹកស្រោចស្រពយ៉ាងសំខាន់នៅក្នុងឃុំសម្រាប់ធ្វើស្រែប្រាំងនិងស្រែវស្សា ។

នាពេលអនាគតអាងស្តុកទឹកនេះ នឹងនៅតែជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល និងព្រមទាំងជាប្រភពធនធានជលផល សម្រាប់ជាអាហារផ្តល់ប្រូតេអ៊ីន ជាប្រយោជន៍យ៉ាងសំខាន់ នៅក្នុងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ។ អាងស្តុកទឹកទាំងនេះ នាពេលអនាគ ស្ថិតនៅតាមពីរតំបន់ផ្សេងគ្នាដូចខាងក្រោម៖

**-អាងស្តុកទឹកក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

អាងស្តុកទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានចំនួន ១កន្លែង មានផ្ទៃដីសរុប ០,១៧ហិកតា ។ អាងស្តុកទឹកនេះ ជាដីកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋ ហើយក្នុងពេលបច្ចុប្បន្ន ត្រូវបានប្រើប្រាស់សម្រាប់ការស្រោចស្រព និងប្រើប្រាស់ផ្សេងៗទៀតតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផងដែលអាចប្រើប្រាស់បានពេញមួយឆ្នាំ ។ នាពេលអនាគតអាងស្តុកទឹកនេះ នឹងនៅតែជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល ព្រមទាំងជាប្រភពធនធានជលផល សម្រាប់ជាអាហារផ្តល់ប្រូតេអ៊ីន ជាប្រយោជន៍យ៉ាងសំខាន់ នៅក្នុងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ហើយក៏ជាទីតាំងមានទេសភាពប្រណិតគួរឱ្យទាក់ទាញសម្រាប់ជាតំបន់ទេសចរណ៍ផងដែរ ។

**-អាងស្តុកទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

អាងស្តុកទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានចំនួន ៣កន្លែង មានផ្ទៃដីសរុប ៤៩,៦ហិកតា ។ អាងស្តុកទឹកនេះ គឺជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋមានសិទ្ធិត្រឹមតែកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងអ្វីឡើយ ហើយក្នុងពេលបច្ចុប្បន្ននេះត្រូវបានប្រើប្រាស់សម្រាប់ការស្រោចស្រព និងប្រើប្រាស់ផ្សេងៗទៀតតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង ដែលអាចប្រើប្រាស់បានពេញមួយឆ្នាំ ។ នាពេលអនាគតអាងស្តុកទឹកទាំងនេះ នឹងនៅតែជាប្រភពទឹកស្រោចស្រពនិងប្រើប្រាស់នៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែលនិងព្រមទាំងជាប្រភពធនធានជលផល សម្រាប់ជាអាហារផ្តល់ប្រូតេអ៊ីន ជាប្រយោជន៍យ៉ាងសំខាន់ នៅក្នុងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ហើយក៏ជាទីតាំងមានទេសភាពប្រណិតគួរឱ្យទាក់ទាញសម្រាប់ជាតំបន់ទេសចរណ៍ផងដែរ ។

ញ. ស្រះ

ស្រះទឹកនៅក្នុងកំពង់ចិនជើង នាពេលអនាគត មានច្រើនកន្លែងស្ថិតនៅរាយប៉ាយទូទាំងឃុំ ដែលមានទំហំផ្ទៃដីចំនួន ១៤,៧៨ហិកតា ដែលបច្ចុប្បន្ននេះ ត្រូវបានប្រើប្រាស់ជាស្រះទឹក ដោយពុំមានការពង្រីកបន្ថែមសម្រាប់ដោះស្រាយទឹកស្រោចស្រពរហូតឆ្នាំ២០៣២ នោះឡើយ ។ នាពេលអនាគតស្រះទឹកទាំងអស់នេះ នឹងនៅតែជាប្រភពទឹកស្រោចស្រព និង ប្រើប្រាស់ច្រើនយ៉ាងក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល ព្រមទាំងជាប្រភពធនធានជលផល សម្រាប់ជាអាហារផ្តល់ប្រូតេអ៊ីនយ៉ាងសំខាន់ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ។

## ៣.៣. ដំណោះស្រាយផ្សេងៗ ក្នុងករណីខ្វះខាតដីធ្លី

ជាការពិត ពេលបច្ចុប្បន្ននេះយើងបានរកឃើញថា នៅក្នុងឃុំកំពង់ចិនជើង មានប្រជាពលរដ្ឋ ក្រីក្រខ្វះខាតដីលំនៅឋានចំនួន៦៧គ្រួសារ និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារពិតប្រាកដ មានចំនួន ២៤៦គ្រួសារ ដូចបានអធិប្បាយនៅក្នុងជំពូក១នៃរបាយការណ៍នេះ ដែលប្រជាពលរដ្ឋមួយចំនួនកំពុងរស់នៅលើដីចិញ្ចើមផ្លូវ ដីចំណីប្រឡាយ និងលើដីចំណីស្ទឹង និងមួយចំនួនទៀតរស់នៅក្នុងខ្ទមលើដីរបស់អ្នកដទៃ ដែលពួកគាត់កំពុងស៊ីឈ្នួលធ្វើការឱ្យគេ ដើម្បីចិញ្ចឹមជីវិត ។ ដូច្នេះដើម្បីដោះស្រាយដី សម្រាប់សាងសង់លំនៅឋាន និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ដែលអាចផ្តល់ឱកាសឱ្យពួកគាត់ មានជម្រកសម្រាប់រស់នៅសមរម្យ និងបង្កើតឱកាសការងារដើម្បីទទួលបានប្រាក់ចំណូលជូនពួកគាត់បាន អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ត្រូវខិតខំដោះស្រាយតាម រយៈកម្មវិធីសម្បទានដីសង្គមកិច្ចនៅថ្នាក់ក្រោមជាតិ ដែលត្រូវផ្តួចផ្តើមឡើងដោយក្រុមប្រឹក្សាឃុំកំពង់ចិនជើង។ ដីធ្លីដែលត្រូវដោះស្រាយជូនពួកគាត់ ដូចបាន ធ្វើការវិភាគដោះស្រាយនៅក្នុងជំពូកទី២ នៅត្រង់ចំណុច ២.១.៣ ខាងលើគឺដីសម្រាប់លំនៅឋានមានទំហំ ១៦,៧៥ហិកតា និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារទំហំ ៤៩២ ហិកតា ។

## ៣.៤. កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព

និរន្តរភាពនៃការប្រើប្រាស់ដី ជាការធានាឱ្យបាននូវគោលដៅនិងអត្ថប្រយោជន៍នៃការប្រើប្រាស់ដីទាំងនោះ ហើយការធានាទាំងអស់នេះត្រូវតែកើតមានឡើងជាបន្តបន្ទាប់ជារៀងរហូតដោយពុំមានឈប់ឈរ។ និរន្តរភាពគឺជាចំណុចស្នូលសម្រាប់ការប្រើប្រាស់ដីនៅគ្រប់តំបន់គោលដៅទាំងអស់តាមរយៈការកំណត់កត្តាចាំបាច់នានាសម្រាប់ការអនុវត្តឱ្យមានប្រសិទ្ធិភាព និងធានាឱ្យមាននិរន្តរភាព ។

### ៣.៤.១. កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព

ដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍ សេដ្ឋកិច្ច សង្គម ព្រមទាំងថែរក្សាការពារបរិស្ថាន និងធនធានធម្មជាតិប្រកបដោយចីរភាព ។ ដោយធាធានបានការផ្តត់ផ្តង់នូវសេចក្តីត្រូវការ និងការទទួលខុសត្រូវចំពោះផលប្រយោជន៍របស់ប្រជាពលរដ្ឋនាពេលបច្ចុប្បន្ន និងបន្តដល់កូនចៅរបស់ពួកគាត់ទៅជំនាន់ក្រោយទៀត ត្រូវតែយកចិត្តទុកដាក់ដល់ការគ្រប់គ្រងទៅលើការប្រើប្រាស់ដីទាំងអស់នៅក្នុងឃុំ ដែលបានកំណត់រួចតាមរយៈការខិតខំប្រឹងប្រែងអនុវត្តឱ្យសម្រេចបានទៅលើកត្តាចាំបាច់មួយចំនួនដូចខាងក្រោម៖

### ក. ការគ្រប់គ្រងប្រព័ន្ធកសិកម្ម

បើពិនិត្យទៅលើលក្ខណៈភូមិសាស្ត្រ និងសក្តានុពលនៃធនធានដែលមាននៅក្នុងឃុំ ដែលក្រុមការងារបាន ធ្វើការសិក្សាស្រាវជ្រាវរកឃើញ បានកំណត់ច្បាស់ថា ឃុំនេះមានគោលដៅអភិវឌ្ឍទៅថ្ងៃអនាគតពឹងផ្អែកទៅលើ វិស័យកសិកម្មជាចម្បង ក្នុងនោះបានផ្តោតសំខាន់ទៅលើដំណាំស្រូវ ។ ដូចនេះឃុំកំពង់ចិនជើងនឹងមាន តួនាទី សំខាន់មួយក្នុងការធ្វើឱ្យសម្រេចបាននូវគោលនយោបាយជំរុញផលិតកម្មស្រូវ និងនាំចេញអង្ករបស់រាជរដ្ឋាភិបាល ដែលត្រូវចាំបាច់ទាមទារឱ្យមានការគ្រប់គ្រងប្រព័ន្ធកសិកម្មនៅក្នុងឃុំឱ្យបានរឹងមាំ និងមាននិរន្តរភាពទៅថ្ងៃអនាគត ដោយត្រូវយកចិត្តទុកដាក់ជំរុញផលិតកម្មស្រូវ ដើម្បីបង្កើននូវទិន្នផលស្រូវឱ្យបានខ្ពស់អស់សក្តានុពល អាចមាន លទ្ធភាពនាំស្រូវចេញបានច្រើនសល់ពីការហូបចុកឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋ ។

ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ឃុំដូចខាងលើត្រូវមានការគ្រប់គ្រងដីស្រែនៅក្នុងឃុំឱ្យបានម៉ត់ចត់ ដោយរាល់ការសម្រេចចិត្តប្តូរមុខងារប្រើប្រាស់ដីពីកសិកម្មទៅបម្រើឱ្យការសាងសង់ និងបម្រើឱ្យការប្រើប្រាស់ផ្សេង ទៀតត្រូវតែមានការចូលរួមពីប្រជាពលរដ្ឋ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ប្រកបដោយតម្លាភាព ដោយអនុលោម តាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងត្រូវមានការផ្សព្វផ្សាយជាចំហ ។ ទន្ទឹមនឹងការគ្រប់គ្រងដីស្រែ ត្រូវគិតគូរពីទឹក ស្រោចស្រពដំណាំស្រូវ ដោយធ្វើយ៉ាងណាអាចធ្វើស្រែបង្កើនរដូវ និងស្រែប្រាំងឱ្យបានបីដងក្នុងមួយឆ្នាំ តាមរយៈ ការស្តារប្រព័ន្ធប្រឡាយចាស់ៗដែលមានស្រាប់អាចនាំទឹកទៅស្រោចស្រពដីស្រែបានគ្រប់គ្រាន់ ដើម្បីអាចផ្តល់ទឹក មកតាមប្រព័ន្ធប្រឡាយទាំងនោះ ដើម្បីធ្វើស្រែវស្សា និងស្រែប្រាំងនិងស្រែវស្សាបានផែនការ១ឆ្នាំ៣ដង ដោយត្រូវ កសាង និងស្តារប្រឡាយថ្មីបន្ថែមចំនួន ១៥ ខ្សែ ប្រវែង ២៣ ៨៤៣,១៣ម៉ែត្រ សម្រាប់ជាមធ្យោបាយនាំទឹកស្រោច ស្រពដីស្រែបានគ្រប់គ្រាន់។ បន្ទាប់ពីកត្តាដី និងទឹកនៅមានកត្តាបច្ចេកទេសដាំដុះថែមទៀត ដោយត្រូវគិតគូរជំរុញ ការធ្វើស្រែបែបប្រពលវប្បកម្មទំនើប ដូចមានលើកឡើងតាមការវិភាគនៅក្នុងជំពូកទី២ ត្រង់ចំណុចការផ្តល់ឱកាស ដោយបច្ចេកវិទ្យាទំនើបដែលកត្តានេះនឹងលើកទឹកចិត្តឱ្យយុវជនចូលរួមក្នុងការងារកសិកម្មបានច្រើនផងដែរពីព្រោះ យុវជនតែងគិតថាការធ្វើស្រែនាំឱ្យមានការនឿយហត់ ប្រឡាក់ប្រឡូសដីភក់ មិនស្អាតបាត ដែលជាការយល់ខុស គឺតាមពិតការធ្វើស្រែ តាមបែបប្រពលវប្បកម្មទំនើបកសិករក៏អាចពាក់ក្រវ៉ាត់កប្រើប្រាស់កុំព្យូទ័រនៅក្នុងបន្ទប់ម៉ាស៊ីន ត្រជាក់បានដូចគ្នា។ក្នុងការគ្រប់គ្រងប្រព័ន្ធកសិកម្មនៅឃុំកំពង់ចិនជើងមិនមែនយកចិត្តទុកដាក់តែនៅលើការជំរុញ ផលិតកម្មកសិកម្មដូចខាងលើប៉ុណ្ណោះទេ តែត្រូវខិតខំពង្រឹងការប្រមូលគ្នាចងក្រងជាសហគមន៍កសិករ ដើម្បីជ្រើស រើសតំណាងអាចទៅចូលរួមតស៊ូមតិក្នុងការចចារកទីផ្សារ ក៏ដូចជាមួយឈ្មួញ ដោយធានាការធ្វើស្រែបានផលស្រូវ មានគុណភាព តាមស្តង់ដារតម្រូវទីផ្សារ និងធានាលំនឹងតម្លៃក្នុងទីផ្សារផងដែរ ។

បើតាមការគណនា ដែលផ្អែកលើការការគិតគូរក្នុងជំពូក២ ត្រង់ចំណុច ២.១.៣ អាចអោយយើងរំពឹងទុកពី បរិមាណផលស្រូវនាំចេញនាពេលអនាគតក្នុងអំឡុងពេល១៥ខាងមុខដូចខាងក្រោមៈ

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ ប្រជាពលរដ្ឋកើនឡើងដល់ ៨ ០៤១នាក់

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ ដីស្រែកើនដល់ ៦ ២៧៤,៨ហិកតា

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ កំណត់ទិន្នផលស្រូវ ៤តោន ក្នុងមួយហិកតា

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ កំណត់ធ្វើស្រែបាន៣ដងក្នុងមួយឆ្នាំ

-ដូច្នេះក្នុងកំឡុងពេល១៥ឆ្នាំ (២០១៧-២០៣២)ផលិតផលស្រូវទទួលបានក្នុងមួយឆ្នាំជាមធ្យមៈ

៦ ២៧៤,៨ហិកតា x ៤តោន/ហិកតា x ៣ដង = ៧៥ ២៨៨តោន/ឆ្នាំ

-ប្រជាពលរដ្ឋ១នាក់ ត្រូវការអង្ករសម្រាប់ហូបក្នុងមួយឆ្នាំមានចំនួន ១៤៣គីឡូក្រាម ដែលបើគិតជាស្រូវ ត្រូវការចំនួន ២២៤ គីឡូក្រាម (ផ្អែកតាមរបាយការណ៍ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)

-ក្នុងអំឡុងពេល១៥ឆ្នាំខាងមុខត្រូវការបរិមាណស្រូវសម្រាប់ផ្គត់ផ្គង់ការហូបចុកក្នុងមួយឆ្នាំជាមធ្យមៈ

១៨ ១៦៩នាក់ x ២២៤គីឡូក្រាម = ៤ ០៦៩ ៨៥៦គីឡូក្រាម/ឆ្នាំ

ស្មើប្រហាក់ប្រហែល ៤ ០៦៩,៨៦តោន /ឆ្នាំ

-ក្នុងអំឡុងពេល១៥ឆ្នាំខាងមុខ ត្រូវការបរិមាណពូជស្រូវក្នុងមួយឆ្នាំជាមធ្យមៈ

៦ ២៧៤,៨ហិកតា x ៣០០គីឡូក្រាម =១ ៨៨២ ៤៤០គីឡូក្រាម/ឆ្នាំ

ស្មើប្រហាក់ប្រហែល ១ ៨៨២,៤៤តោន/ឆ្នាំ

ឆ្នាំខាងមុខ១៥ដូច្នេះក្នុងអំឡុងពេល-ផលិតផលស្រូវទទួលបានសម្រាប់ការនាំចេញក្នុងមួយឆ្នាំជាមធ្យមៈ

៧៥ ២៨៨តោន/ឆ្នាំ -៤ ០៦៩,៨៦តោន/ឆ្នាំ - ១ ៨៨២,៤៤តោន/ឆ្នាំ = ៦៩ ៣៣៥,៧តោន/ឆ្នាំ

-តែបើគិតជាអង្ករវិញអាចនាំចេញបានក្នុងមួយឆ្នាំជាមធ្យមៈ

៦៩ ៣៣៥,៧តោន/ឆ្នាំ x ៦០% = ៤១ ៦០១,៤២តោន/ឆ្នាំ

## ខ. ការគ្រប់គ្រងព្រៃឈើ ជលផល និងធនធានសំខាន់ៗផ្សេងៗទៀត

នៅពេលអនាគត ទោះបីបច្ចុប្បន្ននេះនៅក្នុងឃុំកំពង់ចិនជើង ពុំមានព្រៃឈើធម្មជាតិធំៗក៏ដោយ ក៏ឃុំមានព្រៃគុម្ពោត និងដើមឈើដុះរាយប៉ាយ និងព្រៃតាមដងស្ទឹងតិចតួច និងមានដីទំនេរដែលសមស្របអាចដាំដើមឈើបានដូចជាដីនៅតាមទីសាធារណៈ តាមដងផ្លូវ ប្រឡាយទឹក ទីទួល ទីធ្លាសាលាឃុំ ទីធ្លាសាលារៀន ទីធ្លាមណ្ឌលសុខភាព ទីធ្លានៅតាមវត្តអារាម និងតាមលំនៅឋានជាដើម ដើម្បីឱ្យមានដើមឈើពណ៌បៃតងនៅពាសពេញទូទាំងឃុំបម្រើផលប្រយោជន៍ ដូចបានលើកឡើងនៅក្នុងជំពូកទី២នៃរបាយការណ៍នេះ ហើយត្រូវបន្តថែទាំដើមឈើទាំងនោះឱ្យបាននៅគង់វង្ស និងលូតលាស់បានល្អ។

ចំណែកធនធានជលផលនៅក្នុងឃុំវិញ បច្ចុប្បន្ននេះ មានតែតាមបែបធម្មជាតិនៅតាមស្ទឹងស្ទោង ស្ទឹងនាងសល្វាច ស្រះទឹក អាងស្តុកទឹក ប្រឡាយទឹក និងក្នុងស្រែនារដូវវស្សា ដែលអាចឱ្យប្រជាពលរដ្ឋក្នុងឃុំអាចទទួលផលជាលក្ខណៈគ្រួសារតែប៉ុណ្ណោះ។ ទៅថ្ងៃអនាគតក៏ត្រូវតែខិតខំយកចិត្តទុកដាក់ក្នុងការចិញ្ចឹមត្រីថែមទៀតតាមស្រះក្តីបែរក្តី និងតាមបច្ចេកទេសប្រើថង់កៅស៊ូក្តី ដើម្បីបានផលគ្រប់គ្រាន់ផ្គល់ជាប្រភពប្រូតេអ៊ីនសាច់ដ៏សំខាន់ សម្រាប់ប្រជាពលរដ្ឋនៅក្នុងឃុំកំពង់ចិនជើង ។ ការចិញ្ចឹមត្រីតាមបែបលក្ខណៈគ្រួសារ និងតាមបែបកសិដ្ឋាន ឬតាមបែបកសិកម្មចម្រុះចិញ្ចឹមត្រីក្នុងស្រែ ដែលជាបច្ចេកទេសមួយជួយឲ្យស្រូវដុះលូតលាស់ល្អប្រសើរចៀសផុតពីការបំផ្លាញពីសត្វល្អិតចង្រៃ និងជួយឱ្យត្រីឆាប់ធំ និងជួយបង្កើនផលិតផលស្រូវ និងជីវភាពនៅក្នុងគ្រួសារទៀតផង ។ ចំណែកធនធានសំខាន់ៗ ក្រៅពីការរៀបរាប់នៅខាងលើនេះ នៅក្នុងឃុំពុំមានឃើញធនធានអ្វីផ្សេង ដែលគួរឱ្យកត់សម្គាល់ឡើយ ។

## ៣.៤.២. គម្រោងគាំទ្រចាំបាច់ សម្រាប់គាំទ្រនិរន្តរភាព

ដើម្បីមានមធ្យោបាយអាចធ្វើឱ្យសម្រេចបាននូវការគ្រប់គ្រងប្រព័ន្ធកសិកម្ម និងធនធានសំខាន់ៗ សម្រាប់ការគាំទ្រដល់និរន្តរភាពនៃការអភិវឌ្ឍ និងអភិរក្ស ដីធ្លីនិងធនធានធម្មជាតិក្នុងឃុំចាំបាច់ត្រូវបង្កើតឱ្យមានគម្រោងគាំទ្រជាអាទិភាពមួយចំនួនដូចខាងក្រោមៈ

-ជួសជុល និងស្តារប្រព័ន្ធធារាសាស្ត្រ

-ការជួសជុល និងថែទាំផ្លូវ

-កសាងផ្លូវក្រាលកៅស៊ូ

-បណ្តុះបណ្តាលផលិតជីកំប៉ុស្ត

-បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី
-បណ្តុះបណ្តាលពីការដាំដំណាំស្រូវ
-តបណ្តាញទឹកស្អាតឱ្យបានដល់គ្រប់ភូមិ
-តបណ្តាញអគ្គិសនីឱ្យបានដល់គ្រប់ភូមិ
-បង្កើតទីតាំងចាក់សំរាម
-គម្រោងចុះបញ្ជីដីធ្លីដែលមានលក្ខណៈជាប្រព័ន្ធ
-គម្រោងកៀរដីដោយប្រព័ន្ធឡាស៊ែ
-ស្តារបឹង ស្ទឹង អូរ សាងសង់ប្រឡាយជើងក្អែបនិងប្រព័ន្ធធារាសាស្រ្ត
- ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម(ផលិតកម្មដំណាំស្រូវ ) ដល់ប្រជាពលរដ្ឋ
- ដាំដើមឈើតាមមាត់ស្ទឹងបន្ថែមនិងការពារព្រៃមាត់ស្ទឹងដែលមានស្រាប់
-ធ្វើការផ្សព្វផ្សាយពីច្បាប់ជលផលឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ
-បង្កើតសហគមន៍នេសាទ
-បំផុសការចិញ្ចឹមត្រីតាមលក្ខណៈគ្រួសារ
-លែងកូនត្រីចូលក្នុងបឹងធម្មជាតិ
-ជម្រុញភូមិ១ ផលិតផល១
-ពង្រឹងក្រុមផលិតពូជស្រូវ
-ដាក់លូបង្ហូរទឹកតាមមុខផ្ទះនៅជាប់ផ្លូវ
-ដោះស្រាយដីសម្បទានសង្គមកិច្ច
-ជំរុញធ្វើប័ណ្ណក្រីក្រឱ្យដល់ស្ត្រីគ្រប់គ្នា
-ការផ្តល់អាហាររូបត្ថម្ភដល់ស្ត្រី និងកុមារ
-ផ្សព្វផ្សាយពីការចាក់វ៉ាក់សាំងការពារជម្ងឺដល់ស្ត្រីមានផ្ទៃពោះ កុមារ
-ពង្រឹងសេវាថែទាំសុខភាព និងព្យាបាលជម្ងឺជូនដល់ប្រជាពលរដ្ឋឱ្យបានល្អប្រសើរឡើង
-ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ
-ផ្សព្វផ្សាយពីច្បាប់ភូមិបាល និងច្បាប់ បទដ្ឋានគតិយុត្តនានា ជូនដល់ប្រជាពលរដ្ឋ

## ៣.៥. សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់ ២០៣២)

ផ្អែកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ សម្រាប់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់ចិនជើងក្នុងឆ្នាំ២០១៧ នេះបានឱ្យដឹងថា ជាឃុំមួយក្នុងចំណោមឃុំទាំង១៣ របស់ស្រុកស្ទោងខេត្តកំពង់ធំ មានភូមិចំនួន៦ និងមានផ្ទៃដីសរុបចំនួន ៣ ៨៨៩,៥ហិកតា ។ ក្នុងឆ្នាំ២០១៧ ឃុំកំពង់ចិនជើងមានប្រជាពលរដ្ឋរស់នៅ ១០ ១២៨នាក់ ក្នុងនោះស្ត្រី ៥ ០៧៧នាក់ ស្មើនឹង ១ ៥៤៧ គ្រួសារ ហើយមានដង់ស៊ីតេប្រជាជនជាមធ្យម ៤៦៧នាក់/គ.ម$^{២}$ ។ ឃុំមានសណ្ឋានភាពដី ជាវាលទំនាបលិចទឹកនៅរដូវវស្សានៅភាគខាងលិច ហើយមានប្រភេទដីឥដ្ឋ(ពណ៌លឿនភ្លាវ) សម្រាប់ដំណាំចម្រុះ និងមានប្រភេទដីល្បាយខ្សាច់(ក្រហមភ្លាវ)សម្រាប់ដំណាំស្រូវ និងជាប្រភេទដីកណ្តោងល្បាប់លិចទឹកភ្លៀង (ពណ៌ទង់ដែង) ត្រូវបានប្រើប្រាស់ជាដីស្រែវស្សា ស្រែប្រាំងនិងស្រែវស្សា ដែលបានផ្តល់នូវមុខរបរសំខាន់ដល់ប្រជាពលរដ្ឋភាគច្រើនរហូតដល់ប្រមាណជា ៧៩,១ភាគរយ ចំណែកឯមុខរបរសំខាន់លើការផ្តល់សេវាមានត្រឹម ២០,៥ភាគរយ និងសិប្បកម្ម ០,៤ភាគរយ ដែលជាចំនួនតិចតួចប៉ុណ្ណោះ ។

ក្នុងឃុំមានទឹកស្ទឹងចំនួន២គឺ ឈ្មោះថាស្ទឹងស្ទោង និងស្ទឹងនាងសល្វាច ដែលជាប្រភពទឹកមួយដ៏សំខាន់សម្រាប់ចែកចាយទឹក និងនាំទឹកសម្រាប់ធ្វើការស្រោចស្រពតាមរយៈប្រឡាយក្នុងពេលរដូវវស្សាដែលមានប្រឡាយសរុបចំនួន ១៨ខ្សែ ប្រវែង ៣៣ ៩៣០,៤២ម៉ែត្រ ។ ដែលនៅក្នុងនោះប្រឡាយមេ២ខ្សែប្រវែង ៦ ០៣៣,៥៤ម៉ែត្រ ប្រឡាយរង ០១ខ្សែ ប្រវែង ១ ១៨៦,២៨ម៉ែត្រ និងប្រឡាយផ្សេងៗ ១៥ខ្សែ មានប្រវែង ២៦ ៧១០,៦០ម៉ែត្រ ដែលអាចនាំទឹក ដើម្បីស្រោចស្រពដីស្រែពេលជួបគ្រោះរាំងស្ងួតនៅរដូវវស្សា តាមរយៈប្រឡាយទាំងនេះ ដែលជាចំនួនច្រើនល្មមគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ស្រោចស្រពដីស្រែក្នុងឃុំបាន ។ បន្ថែមពីលើនេះឃុំមានផ្លូវជាតិលេខ៦ដែលជាអ័ក្សច្រកផ្លូវសេដ្ឋកិច្ច គឺជាការផ្តល់ឱកាសឱ្យឃុំកំពង់ចិនជើង អាចទាញយកប្រយោជន៍ពីការអភិវឌ្ឍតាមផ្លូវនេះទៅថ្ងៃអនាគតបាន ។ ទន្ទឹមនេះឃុំ នៅមានផ្លូវផ្សេងទៀតគ្រប់គ្រាន់អាចភ្ជាប់ទំនាក់ទនងពីភូមិមួយទៅភូមិមួយក្នុងឃុំ និងអាចភ្ជាប់ទំនាក់ទំនងទៅឃុំ និងស្រុកផ្សេងរួមទាំងទីរួមខេត្តកំពង់ធំ និងខេត្តសៀមរាបបានដោយងាយស្រួល ។ ចំពោះកំណើនប្រជាជនវិញបានរកឃើញថា នៅក្នុងរយៈពេល១៥ឆ្នាំទៅមុខរហូតដល់ឆ្នាំ២០៣២ នឹងមានប្រជាជនកើនឡើងរហូតដល់ ១៨១៦៩នាក់ ដែលនឹងត្រូវយកចិត្តទុកដាក់គិតគូររកដំណោះស្រាយអំពីការប្រើប្រាស់ដី ដើម្បីឆ្លើយតបបានទៅនឹងតម្រូវការរបស់ប្រជាជន ។ ទន្ទឹមនេះក៏បានរកឃើញអំពីបញ្ហាប្រឈមមួយចំនួនលើសកម្មភាពនៃការអភិវឌ្ឍន៍ឃុំកំពង់ចិនជើងបច្ចុប្បន្នផងដែរ ដូចជា ការធ្វើស្រែដែលមានសក្តានុពលក្នុងការអភិវឌ្ឍន៍ឃុំមិនទាន់ទទួលបាននូវទិន្នផលស្រូវសមស្របអស់លទ្ធភាពនៅឡើយ ដោយសារតែដីស្រែទាំងនេះកាន់តែខ្សត់ជីជាតិ ខ្វះទឹកស្រោចស្រពសម្រាប់ផ្គត់ផ្គង់ដល់ការធ្វើស្រែបង្កើនរដូវ ខ្វះចំណេះដឹងអំពីបច្ចេកទេសនៃការដាំដុះ ខ្វះចំណេះដឹងពីបច្ចេកទេសការប្រើប្រាស់ជីគីមី និងថ្នាំពុលកសិកម្ម ប្រព័ន្ធប្រឡាយដែលមានស្រាប់បានរាក់ ខ្វះកម្លាំងពលកម្មដោយសារចំណាកស្រុកច្រើន គឺបាត់កម្លាំងពលកម្មជិតពាក់កណ្តាលនៃកម្លាំងពលកម្មដែលមាន និងតម្លៃកសិផលមិនមានស្ថេរភាព ដោយឈ្មួញជាអ្នកកំណត់តម្លៃ ។ល។ ទន្ទឹមការរកឃើញបញ្ហាមួយចំនួនលើសកម្មភាពអភិវឌ្ឍន៍ឃុំ ក៏បានរកឃើញថា ជាទូទៅការប្រើប្រាស់ដីនៅក្នុងឃុំកំពង់ចិនជើងបច្ចុប្បន្នបានចំទិសដៅនិងមានភាពសមស្រប ដូចជាការប្រើប្រាស់ដីសម្រាប់លំនៅឋាន ភូមិ កសិកម្ម ប្រព័ន្ធផ្លូវគមនាគមន៍ ប្រព័ន្ធធារាសាស្ត្រជាដើម ដែលទៅថ្ងៃអនាគត ក៏នៅតែរក្សាមុខងារប្រើប្រាស់ដីទាំងនោះឱ្យនៅដដែល ។ បន្ថែមពីលើនេះ ក៏បានរកឃើញវិធីដោះស្រាយបញ្ហាផ្សេងៗទៀតផងដែរសម្រាប់អនាគត ដូចជាត្រូវសាងសង់បន្ទប់រៀនបន្ថែម ពង្រឹងការផ្តល់សេវាសុខាភិបាលឱ្យបានប្រសើរឡើង ជំរុញឱ្យប្រជាពលរដ្ឋហូបទឹកស្អាត និងប្រើប្រាស់បង្គន់អនាម័យ ជួសជុលផ្លូវ ស្តារប្រឡាយទឹក ដាំដើមឈើនៅតាមទីសាធារណៈ ជំរុញការចិញ្ចឹមត្រីតាមស្រែ។ល។ ជាពិសេសការដោះស្រាយដីសម្រាប់លំនៅឋានដែលមិនតម្រូវឱ្យមានការពង្រីកបន្ថែមទៀតនោះទេ គឺឱ្យប្រើប្រាស់ដីភូមិដែលមានស្រាប់ដែល បច្ចុប្បន្ននៅទូលាយអាចផ្គត់ផ្គង់ការសាងសង់លំនៅឋានបាន ជៀសវាងការពង្រីកថែមនាំឱ្យប៉ះពាល់ដល់ ដីស្រែ ចំណែកដីស្រែដែលមិនអាចពង្រីកបានដើម្បីដោះស្រាយទៅនឹងកំណើនប្រជាជន ត្រូវពង្រឹងការ ធ្វើស្រែឱ្យបាន៣ដងក្នុងមួយឆ្នាំ និងធ្វើស្រែតាមបែបប្រពលវប្បកម្ម ដើម្បីបង្កើនទិន្នផលស្រូវឱ្យបានខ្ពស់អស់សក្តានុពលដែលមានសម្រាប់ផ្គត់ផ្គង់ការហូបចុកនិងនាំស្រូវចេញបានចំនួន ៦៩ ៣៣៥,៧តោន/ឆ្នាំ ដើម្បីជួយផ្គត់ផ្គង់ដល់ជីវភាពរបស់ប្រជាពលរដ្ឋនៅក្នុងឃុំឱ្យបានកាន់តែប្រសើរឡើង សមស្របទៅនឹងកំណើនប្រជាពលរដ្ឋ ព្រមទាំងជួយជំរុញកំណើនសេដ្ឋកិច្ចនៅក្នុងឃុំ ។ ការរកឃើញភាពសមស្រប និងជម្រើសនៃការប្រើប្រាស់ដីនៅក្នុងឃុំនាពេលអនាគតនេះ បានមកពីការវាយតម្លៃដ៏ត្រឹមត្រូវមួយ ដោយផ្អែកទៅលើធនធាន រយៈកម្ពស់ដី ទីជម្រាល ធនធានទឹក ការកាន់កាប់ដី និងសក្តានុពលនៃការប្រើប្រាស់ដីនៅក្នុងឃុំនេះជាដើម ដើម្បីធានាថាការប្រើប្រាស់ដីនៅក្នុងឃុំកំពង់ចិនជើងទៅអនាគតប្រកបទៅដោយចីរភាព និងសមធម៌ ។

ដូច្នេះដើម្បីសម្រេចបាននូវផលិតភាពខ្ពស់នៃការប្រើប្រាស់ដីនៅក្នុងឃុំស្របទៅតាមស្ថានភាពដីជាក់ស្តែង និងសក្តានុពលនៃធម្មជាតិ សម្រាប់ការគាំទ្រកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមប្រកបដោយចីរភាព និងសមធម៌ រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនាពេលអនាគត ដូចបានរកឃើញមានចែងលម្អិតនៅក្នុងរបាយការណ៍បច្ចេកទេសនេះ រដ្ឋបាលនៅថ្នាក់ក្រោមជាតិពាក់ព័ន្ធ ជាពិសេសក្រុមប្រឹក្សាឃុំ ដែលជាតំណាងប្រជាពលរដ្ឋក្នុងឃុំ ហើយមានបេសកកម្មបម្រើផលប្រយោជន៍ទូទៅក្នុងឃុំកំពង់ចិនជើង ត្រូវខិតខំអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់ចិនជើង ដែលបានអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការរួច ដោយបញ្ជ្រាបទៅនិងផែនការអភិវឌ្ឍន៍ឃុំ ប្រកបដោយប្រសិទ្ធិភាពខ្ពស់បំផុត ដើម្បីធានាភាពជោគជ័យនៃផែនការនេះ ៕

លេខ៖ 811/20

បានពិនិត្យ និង សូមគោរពជូន

**លោកអភិបាលនៃគណៈអភិបាលស្រុក និង ជាប្រធានគណៈកម្មាធិការ**

**រៀបចំដែនដី និងនគរូបនីយកម្មស្រុកស្ទោង មេត្តាពិនិត្យ និង សម្រេច។**

ថ្ងៃ [illegible] ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

កំពង់ចិនជើង ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០២០

**មេឃុំកំពង់ចិនជើង**

ឈុន ឆាត

លេខ÷ ០២៧/២០

បានពិនិត្យ និង សូមគោរពជូន

**ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និង ជាប្រធានគណៈកម្មាធិការ**

**រៀបចំដែនដី និង នគរូបនីយកម្មខេត្តកំពង់ធំ មេត្តាពិនិត្យ និង សម្រេចដ៏ខ្ពង់ខ្ពស់ ។**

ថ្ងៃ ច័ន្ទ ១៣ រោច ខែ ស្រាពណ៍ ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤

ស្ទោង ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២០

**អភិបាលនៃគណៈអភិបាលស្រុក និង ជាប្រធាន**

**គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកស្ទោង**

លេខ៖ ៥៤៨៧/...

បានឃើញ និងឯកភាពសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ

ថ្ងៃ ព្រហស្បតិ៍ ៣កើត ខែ ភទ្របទ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

កំពង់ធំ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០២១

**អភិបាលនៃគណៈអភិបាលខេត្ត និងជា**

**ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ**

# ឯកសារឧបសម្ព័ន្ធ

# ផែនទីហេដ្ឋារចនាសម្ព័ន្ធ ឃុំកំពង់ចិនជើង



# ផែនទីប្រព័ន្ធធារាសាស្ត្រ ឃុំកំពង់ចិនជើង



# ផែនទីប្រើប្រាស់ដីសាមញ្ញ ឃុំកំពង់ចិនជើង



# ផែនទីគម្រោងវិនិយោគ ឃុំកំពង់ចិនជើង



# ឯកសារឧបសម្ព័ន្ធ




សកម្មភាពក្រុមការងារចូលរួមប្រជុំទទួលការណែនាំពីនីតិវិធីរៀបចំផែនការប្រើប្រាស់ដីថ្នាក់ឃុំ
ពីប្រធានគ្រប់គ្រងគម្រោងរបស់ក្រុមហ៊ុន




សកម្មភាពប្រមូលទិន្នន័យនៅតាមមន្ទីរជុំវិញខេត្តរបស់ក្រុមការងារក្រុមហ៊ុន SBK




កិច្ចប្រជុំពិភាក្សាអំពីផែនទីប្រើប្រាស់ដីបច្ចុប្បន្នឃុំកំពង់ចិនជើង



សកម្មភាពក្រុមការងារចុះទីវាលស្រង់ទិន្នន័យបំពេញបន្ថែមលើ
ផែនទីប្រើប្រាស់ដីបច្ចុប្បន្ន ដែលមានស្រាប់ឃុំកំពង់ចិនជើង



សកម្មភាពចូលរួមត្រួតពិនិត្យ ណែនាំ ការអនុវត្តគម្រោងរបស់អង្គភាពអនុវត្តន៍គម្រោងថ្នាក់ជាតិ (NIO)



កិច្ចប្រជុំក្រុមប្រឹក្សាឃុំកំពង់ចិនជើង ដើម្បីពិនិត្យ និងឯកភាពទៅលើ
សេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់ចិនជើង




កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកស្ទោង ដើម្បីពិនិត្យ និងឯកភាពទៅលើ សេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់ចិនជើង




កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ ដើម្បីពិនិត្យ និងឯកភាពទៅលើ សេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់ចិនជើង






ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលស្រុកស្ទោង
ក្រុមប្រឹក្សាឃុំកំពង់ចិនជើង

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
[illegible] ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០[illegible]

**សេចក្តីជូនដំណឹង**

**ស្តីពីការបិទផ្សាយជាសាធារណៈផែនការប្រើប្រាស់ដីអនាគតឃុំកំពង់ចិនជើង**

យោង: - កិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB )។

- កិច្ចសន្យាលេខ CON-LUP/RICE-SDP/CLUP/MUMUPC/CS/09 ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៧ រវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាមួយក្រុមហ៊ុន SBK Research & Development Co.,Ltd។
- អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី០៥ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ។
- តម្រូវការចាំបាច់នៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។

ខ្ញុំយើងបាទជម្រាបជូនក្នុងសេចក្តីយោងខាងលើ និងស្របតាមការរៀបចំផែនការប្រើប្រាស់ដី និងលទ្ធផលការងារ ដែលសម្រេចបានទៅតាមនីតិវិធីនាពេលកន្លងមកក្រុមប្រឹក្សាឃុំកំពង់ចិនជើង ស្រុកស្ទោង ខេត្តកំពង់ធំ សូមគោរពជម្រាបជូនដល់គ្រប់ស្ថាប័ន អង្គការសង្គមស៊ីវិល ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់មេត្តាជ្រាបថា÷ នៅថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២០.. ដល់ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២០..ឃុំកំពង់ចិនជើង ធ្វើការរៀបចំបិទផ្សាយជាសាធារណៈនូវឯកសារ និងផែនការប្រើប្រាស់ដីអនាគត ដែលសម្រេចបាន នៅទីតាំងសាលាឃុំខាងលើ ដើម្បីធ្វើការពិនិត្យ កែសម្រួល និងផ្តល់យោបល់។

អាស្រ័យហេតុនេះ សូមបងប្អូនប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ មេត្តាជួយផ្សព្វផ្សាយ និងចូលរួមពិនិត្យ ផ្តល់យោបល់អោយបានកុះករ កុំបីអាក់ខានឡើយ ។

សូមបងប្អូនជនរួមជាតិ មេត្តាទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ ។

ប្រធានក្រុមប្រឹក្សាឃុំ និងជា
មេឃុំកំពង់ចិនជើង

ឈុន_ឆាត



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលស្រុកស្ទោង
ក្រុមប្រឹក្សាឃុំ កំពង់ចិនជើង

**របាយការណ៍ការបូកសរុប**
**លទ្ធផល នៃការបិទផ្សាយជាសាធារណៈ នូវឯកសារផែនទី និង**
**សៀវភៅផែនការប្រើប្រាស់ដីនៅក្នុងឃុំ កំពង់ចិនជើង**

យោង: - កិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០១៣ រវាង រាជរដ្ឋាភិបាលកម្ពុជានិងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

- កិច្ចសន្យាលេខ CON-LUP/RICE-SDP/CLUP/MUMUPC/CS/ ០១ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០១៧ រវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាមួយក្រុមហ៊ុន SBK Research & Development Co.,Ltd។
- អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០០៩ ស្តីពីនិតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។
- ក្រុមប្រឹក្សាឃុំកំពង់ចិនជើង បានបិទផ្សាយជាសាធារណៈនៅទីតាំង សាលាឃុំកំពង់ចិនជើង នូវឯកសារផែនទី និងសៀវភៅព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់ចិនជើង (បានប្រជុំអនុម័តថ្នាក់ស្រុកស្ទោង រួចរាល់ជាស្ថាពរ) ចាប់ពីថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ ២០២០ ដល់ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ ២០២០ មានរយៈពេល ៤៥ ថ្ងៃជាលទ្ធផលមានដូចខាងក្រោម៖

**១. ផែនទីប្រើប្រាស់ដីនៅក្នុងឃុំ កំពង់ចិនជើង**

- បានធ្វើការបិទផ្សាយផែនទីប្រើប្រាស់ដីលម្អិតបច្ចុប្បន្ន មានទំហំជាខ្នាត A0
- បានធ្វើការបិទផ្សាយផែនទីប្រើប្រាស់ដីអនាគតសម្រាប់រយៈពេល ១៥ឆ្នាំ ២០១៧ ដល់ ២០៣២ មានទំហំជាខ្នាត A0
- **ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន**

**២. សៀវភៅផែនការប្រើប្រាស់ដីនៅក្នុងឃុំ កំពង់ចិនជើង**

- ជំពូក ១ ៖ ព័ត៌មានស្តីពី ស្ថានភាពឃុំកំពង់ចិនជើង



- ចាប់ពី ១.១. ស្ថានភាពទូទៅនៃឃុំ ១.១.១. ទីតាំងរដ្ឋបាលឃុំ រហូតដល់ ១.៤. ទីផ្សារ និង ខ្សែសង្វាក់ផលិតផល ១.៤.៣. ឧបសគ្គ និង ឱកាស។
- **ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន**

- ជំពូក ២ ៖ ការវិភាគតម្រូវការ សក្តានុពល និង ឧបសគ្គសម្រាប់អនាគត
  - ចាប់ពី ២.១. តម្រូវការសម្រាប់អនាគត់ ២.១.១. ផែនការអភិវឌ្ឍន៍ឃុំ រហូតដល់ ២.៥. បញ្ហា មូលហេតុ និង ដំណោះស្រាយ។
  - **ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន**
- ជំពូក ៣ ៖ ផែនការប្រើប្រាស់ដីសម្រាប់ពេលអនាគត ឆ្នាំ២០១៧ ដល់ ២០៣២
  - ចាប់ពី ៣.១. តម្រូវការ ស្ថានភាព និង សក្តានុពលជាក់ស្តែង ៣.១.១. តម្រូវការដីទៅតាមប្រភេទ រហូតដល់ ៣.៥. សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់ ២០៣២)
  - **ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន**

- **ការវាយតម្លៃ** : ផ្អែកតាមឯកសារភស្តុតាង និងទិន្នន័យជាក់ស្តែង ដែលប្រមូលបាន លទ្ធផលនៃការបិទផ្សាយសាធារណៈនូវឯកសារ ផែនទី និង សៀវភៅព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ កំពង់ចិនជើង សម្រាប់ឆ្នាំ ២០១៧ ដល់ ២០៣២ ជាយោបល់គួរដាក់ជូនគណៈកម្មាធិការរៀបចំដែនដី និង នគរូបនីយកម្មខេត្តកំពង់ធំ ដើម្បីពិនិត្យ និង សម្រេចដ៏ខ្ពង់ខ្ពស់។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំ[illegible] ស័ក ព.ស. ២៥៦[illegible]
កំពង់ចិនជើង ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ ២០២០

ប្រធានក្រុមប្រឹក្សាឃុំ និងជា
មេឃុំកំពង់ចិនជើង

ឈុន_ឆាត

សកម្មភាពផ្សព្វផ្សាយជាសាធារណៈសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់ចិនជើង

# ឯកសារយោង

# ឯកសារយោង

១. ឯកសារព័ត៌មានស្ថានភាពឃុំកំពង់ចិនជើងស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៣ របស់មន្ទីរផែនការខេត្ត
២. ឯកសារព័ត៌មានស្ថានភាពឃុំកំពង់ចិនជើងស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៤ របស់មន្ទីរផែនការខេត្ត
៣. ឯកសារព័ត៌មានស្ថានភាពឃុំកំពង់ចិនជើងស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៥ របស់មន្ទីរផែនការខេត្ត
៤. ឯកសារព័ត៌មានស្ថានភាពឃុំកំពង់ចិនជើងស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៦ របស់មន្ទីរផែនការខេត្ត
៥. ឯកសារព័ត៌មានស្ថានភាពឃុំកំពង់ចិនជើងស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៧ របស់មន្ទីរផែនការខេត្ត
៦. ផែនការអភិវឌ្ឍន៍ឃុំរយៈពេលប្រាំឆ្នាំ(២០១៨-២០២២)របស់ឃុំកំពង់ចិនជើង ស្រុកស្ទោង ខេត្តកំពង់ធំ
៧. ផែនការអភិវឌ្ឍន៍ស្រុករយៈពេលប្រាំឆ្នាំ(២០១៨-២០២២)របស់ ស្រុកស្ទោង ខេត្តកំពង់ធំ
៨. កម្មវិធីវិនិយោគឃុំកំពង់ចិនជើង ឆ្នាំ២០១៧ របស់ឃុំកំពង់ចិនជើង ស្រុកស្ទោង ខេត្តកំពង់ធំ
៩. របាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ឃុំកំពង់ចិនជើង ស្រុកស្ទោង ខេត្តកំពង់ធំ ឆ្នាំ២០១៧
១០. អនុក្រឹត្យស្តីពីការកំណត់ដែនព្រៃលិចទឹក ៦៤៧,៤០៦ហិកតា ស្ថិតនៅក្នុងខេត្តទាំង៦ជុំវិញបឹងទន្លេសាប (កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប)
១១. អនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ៨៨.អនក្រ.បក ស្តីពីការបង្កើតតំបន់ការពារទេសភាពទំនាបខាងជើងទន្លេសាប ។